ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកិច្ចការនារី
MINISTRY OF WOMEN'S AFFAIRS

# នារីរតនៈទី៥

## ផែនការយុទ្ធសាស្ត្រដើម្បីជំរុញការបញ្ជ្រាបយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី

ឆ្នាំ២០១៩-២០២៣

ក្រសួងកិច្ចការនារី
MINISTRY OF WOMEN'S AFFAIRS

# នារីរតនៈទី៥

## ផែនការយុទ្ធសាស្ត្រដើម្បីជំរុញការបញ្ជ្រាបយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី

ឆ្នាំ២០១៩-២០២៣

# អារម្ភកថា

រាជរដ្ឋាភិបាល បានប្រកាសដាក់ឱ្យអនុវត្តនូវ**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤** ក្នុងកិច្ចប្រជុំ ពេញអង្គរបស់គណៈរដ្ឋមន្ត្រីដែលជាក្របខណ្ឌគោលនយោបាយដ៏មានប្រសិទ្ធភាព និងមានភាពប្រាកដប្រជា ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព ក្នុងការកសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០។

**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤** និង**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣** បានបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការពង្រឹងសមភាពយេនឌ័រនៅគ្រប់កម្រិត និងគ្រប់វិស័យ និងការពង្រឹងតួនាទីស្ត្រីដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចនិងសង្គមជាតិ។ ឈរលើមូលដ្ឋាននេះ ក្រសួងកិច្ចការនារី ដែលជាយន្តការជាតិក្នុងការដឹកនាំការសម្របសម្រួលជំរុញ និងតាមដានការអនុវត្តការបញ្ជ្រាបយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី បានរៀបចំ**ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ២០១៩-២០២៣** ដោយផ្អែកលើវឌ្ឍនភាពក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ (២០១៤-២០១៨) ព្រមទាំងផ្សារភ្ជាប់ជាមួយគោលការណ៍គ្រឹះ និងអនុសាសន៍នៃការអនុវត្តអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី ច្បាប់ គោលនយោបាយជាតិ ក្របខណ្ឌកំណែទម្រង់របស់រាជរដ្ឋាភិបាល និងតាមវិស័យ របៀបវារៈសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ***ដោយមិនទុកអ្នកណាម្នាក់ឱ្យនៅឯកោ*** និងការវិវត្តថ្មីៗរបស់សង្គមជាសកល និងនៅក្នុងថ្នាក់តំបន់ ។

**នារីរតនៈទី៥** ផ្តោតលើការជំរុញការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍គ្រប់វិស័យ និងគ្រប់កម្រិត និងមានយុទ្ធសាស្ត្រតាមវិស័យពាក់ព័ន្ធនឹងសេដ្ឋកិច្ច ការអប់រំ សុខភាព កិច្ចការពារផ្លូវច្បាប់ អភិបាលកិច្ច និងការប្រែប្រួលអាកាសធាតុ។ ក្របខណ្ឌយុទ្ធសាស្ត្រនេះ ទ្រទ្រង់ដោយកម្មវិធីពង្រឹងសមត្ថភាព និងអភិវឌ្ឍស្ថាប័នដែលជាកត្តាចាំបាច់នៃភាពជោគជ័យក្នុងការអនុវត្ត **នារីរតនៈទី៥** ។ ក្នុងបរិការណ៍នេះ កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្ថាប័នត្រូវធ្វើឡើងដោយឆ្លុះបញ្ចាំង និងឆ្លើយតបនឹងការប្រែប្រួលយ៉ាងឆាប់រហ័សនៃការវិវត្តន៍ និងបរិបទថ្មីៗរបស់សកលលោក និងនៅក្នុងប្រទេស ក៏ដូចជាការឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤ និងការធ្វើឌីជីថលភាវូបនីយកម្ម។

**នារីរតនៈទី៥** បានរៀបចំឡើង ស្របគ្នាជាមួយដំណើរការរៀបចំសេចក្តីព្រាង **គោលនយោបាយជាតិ ស្តីពីសមភាពយេនឌ័រ** ដែលជាផែនការយុទ្ធសាស្ត្រគន្លឹះក្នុងការចូលរួមការអនុវត្តគោលនយោបាយជាតិ ជាពិសេសក្នុងការសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន និងជំរុញការអនុវត្តនៅគ្រប់វិស័យ និងគ្រប់កម្រិត ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ក្រសួង-ស្ថាប័ន និងដៃគូពាក់ព័ន្ធនឹងបន្តចូលរួម និងកិច្ចសហប្រតិបត្តិការក្នុងស្មារតីខ្ពស់ដើម្បីសម្រេចសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី រួមទាំងការអនុវត្ត**នារីរតនៈទី៥** ប្រកបដោយជោគជ័យ និងប្រសិទ្ធភាពសម្រាប់ជាឧត្តមប្រយោជន៍ដល់សង្គមជាតិទាំងមូល ។

ថ្ងៃ ពុធ ៤កើត ខែ អាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០២០

**រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី**

**អ៊ឹង កន្ថាផាវី**

# មាតិកា


**សេចក្តីផ្តើម** ........ ១

**ផ្នែកទី១. វឌ្ឍនភាពចម្បងៗ បញ្ហាប្រឈម និងការអនុវត្តភាព** ........ ២

**ផ្នែកទី២. ចក្ខុវិស័យ និងបេសកកម្ម** ........ ១៥

**ផ្នែកទី៣. គោលបំណង** ........ ១៦

**ផ្នែកទី៤. ក្របខណ្ឌយុទ្ធសាស្ត្រ** ........ ១៧

យុទ្ធសាស្ត្រស្នូល. ក្របខណ្ឌបញ្ជ្រាបយេនឌ័រ ........ ១៧

យុទ្ធសាស្ត្រ ទី១. ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី ........ ១៩

យុទ្ធសាស្ត្រ ទី២. ការលើកកម្ពស់ការអប់រំរបស់ស្ត្រីនិងក្មេងស្រី ........ ២០

យុទ្ធសាស្ត្រ ទី៣. ការលើកកម្ពស់សុខភាពរបស់ស្ត្រីនិងក្មេងស្រី ........ ២១

យុទ្ធសាស្ត្រ ទី៤. កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រីនិងក្មេងស្រី ........ ២២

យុទ្ធសាស្ត្រ ទី៥. ស្ត្រីក្នុងវិស័យសាធារណៈ នយោបាយនិងភាពជាអ្នកដឹកនាំ ........ ២៤

យុទ្ធសាស្ត្រ ទី៦. ការបញ្ជ្រាបយេនឌ័រ ក្នុងកម្មវិធីប្រែប្រួលអាកាសធាតុ ........ ២៥

យុទ្ធសាស្ត្រគាំទ្រស្ថាប័ន. ការពង្រឹងសមត្ថភាព និងប្រសិទ្ធភាពស្ថាប័ន ........ ២៥

**ផ្នែកទី៥. ផែនការសកម្មភាព** ........ ២៧

**ផ្នែកទី៦. ប្រភពធនធានហិរញ្ញវត្ថុ** ........ ៧៥

**ផ្នែកទី៧. ការពិនិត្យតាមដាន និងវាយតម្លៃ** ........ ៧៦

**សន្ទានុក្រម** ........ ៨៣

# សេចក្តីផ្តើម

**ផែនការយុទ្ធសាស្ត្រនារីរតនៈទី៤** ឆ្នាំ២០១៤-២០១៨ បានអនុវត្តកន្លងមក ក្នុងការជំរុញការបញ្ជ្រាបយេនឌ័រនិងបង្កើនភាពអង់អាចដល់ស្ត្រីនៅក្នុងវិស័យអាទិភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤** ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពៈ កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ បានចង្អុលបង្ហាញអំពីការពង្រឹងសមភាពយេនឌ័រ នៅក្នុងមុំទី៤នៃចតុកោណទី១ស្តីពីការអភិវឌ្ឍធនធានមនុស្ស ដែលរាជរដ្ឋាភិបាលផ្តោតលើការពង្រឹងតួនាទីស្ត្រីដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចនិងសង្គមជាតិ ដោយដាក់ចេញជាយុទ្ធសាស្ត្រ ទី១-ការបន្តលើកកម្ពស់តួនាទីស្ត្រីតាមរយៈការបង្កើនសមាមាត្រ និងការពង្រឹងសមត្ថភាពស្ត្រី ក្នុងជួរថ្នាក់ដឹកនាំទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ទាំងកម្រិតនយោបាយនិងកម្រិតជំនាញ និងទី២-ការធ្វើបច្ចុប្បន្នភាព និងអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈ ដោយបន្តជំរុញការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ និងផែនការអភិវឌ្ឍ គ្រប់ផ្នែក គ្រប់វិស័យ និងគ្រប់កម្រិត បន្តលើកកម្ពស់សហគ្រិនភាពរបស់ស្ត្រី តាមរយៈការពង្រីកកម្មវិធីអប់រំនិងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ស្ត្រី ព្រមទាំងបន្តលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ តាមរយៈការបង្កើនការវិនិយោគលើសមភាពយេនឌ័រ និងពង្រឹងភាពជាដៃគូរវាងស្ថាប័នពាក់ព័ន្ធ សំដៅទប់ស្កាត់ការជួញដូរនិងអំពើហិង្សាលើស្ត្រី និងកុមារ ។

ការតាក់តែង**នារីរតនៈទី៥** ឆ្លើយតបនឹងការចង្អុលបង្ហាញរបស់ការសិក្សា និងប៉ាន់ប្រមាណការអនុវត្ត**ផែនការយុទ្ធសាស្ត្រនារីរតនៈទី៤** ការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា ព្រមទាំងផ្សារភ្ជាប់នឹងគោលការណ៍គ្រឹះ និងអនុសាសន៍នៃការអនុវត្តអនុសញ្ញា ស៊ី-ដ ច្បាប់ គោលនយោបាយជាតិ និងអន្តរជាតិ ការវិវត្តថ្មីៗរបស់សង្គម ជាសកល និងនៅក្នុងថ្នាក់តំបន់ ។ ផ្អែកតាមការចង្អុលបង្ហាញខាងលើ និងស្របតាមអាណត្តិរបស់ក្រសួងកិច្ចការនារី ដែលជាយន្តការជាតិដឹកនាំការសម្របសម្រួលលើការងារបញ្ជ្រាបយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីនៅគ្រប់វិស័យ និងគ្រប់កម្រិត ក្រសួងកិច្ចការនារីរៀបចំនិងសម្របសម្រួលការអនុវត្ត**ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥** ជាមួយក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ។

**នារីរតនៈទី៥** បានតាក់តែងស្របគ្នាជាមួយដំណើរការរៀបចំសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីសមភាពយេនឌ័រ ដែលមានគោលដៅដើម្បីក្លាយជាផែនការយុទ្ធសាស្ត្រគន្លឹះ ក្នុងការចូលរួមការអនុវត្តគោលនយោបាយជាតិនេះ ជាពិសេសក្នុងការសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន និងជំរុញការអនុវត្តនៅគ្រប់វិស័យ និងគ្រប់កម្រិត ។

# ផ្នែកទី១

## វឌ្ឍនភាពចម្បងៗ បញ្ហាប្រឈម និងកាលានុវត្តភាព

នៅកម្ពុជា សមភាពយេនឌ័រ និងស្ថានភាពស្ត្រីត្រូវបានលើកកម្ពស់ជាបន្តបន្ទាប់។ ជាក់ស្តែងយោងតាមរបាយការណ៍ **វេទិកាសេដ្ឋកិច្ចពិភពលោក** (World Economic Forum) បានបង្ហាញថាការកាត់បន្ថយគម្លាតយេនឌ័រនៅកម្ពុជាមានភាពប្រសើរឡើង ដោយកម្ពុជាស្ថិត**លំដាប់ទី៨៩** នៅឆ្នាំ២០១៩ (ក្នុងចំណោម ១៥៣ប្រទេស) ធៀបនឹងឆ្នាំ២០១៤ ដែលមាន**លំដាប់ទី១០៨** (ក្នុងចំណោម១៤២ប្រទេស)។

ការអនុវត្ត**ផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ ២០១៤-២០១៨** បានចូលរួមក្នុងការបញ្ជ្រាបយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី នៅក្នុងដំណើរការតាក់តែង អនុវត្ត និងតាមដានការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងការងារកំណែទម្រង់របស់រាជរដ្ឋាភិបាល ព្រមទាំងនៅតាមវិស័យនានា។

វឌ្ឍនភាព និងលទ្ធផលគន្លឹះៗ ដែលសម្រេចបានមានដូចខាងក្រោម៖

### ១. ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី

១.១. កម្ពុជាមានភាពរីកចម្រើនខ្លាំងលើការពង្រីកកាលានុវត្តភាព និងសកម្មភាពស្ត្រីក្នុងវិស័យសេដ្ឋកិច្ច។ របាយការណ៍ **វេទិកាសេដ្ឋកិច្ចពិភពលោក** បានបង្ហាញថា នៅឆ្នាំ២០១៩ កម្ពុជាស្ថិតនៅ**លំដាប់ទី២៥** (ក្នុងចំណោម១៥៣ប្រទេស) បើធៀបកាលពីឆ្នាំ២០១៤ ដែលស្ថិតនៅ**លំដាប់ទី៧៧** (ក្នុងចំណោម១៤២ប្រទេស) លើការចូលរួមនិងកាលានុវត្តភាពផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ។

១.២. ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីត្រូវបានយកចិត្តទុកដាក់ និងឆ្លើយតបជាបន្តបន្ទាប់ នៅក្នុងរបៀបវារៈគោលនយោបាយនិងកម្មវិធីជាតិនានា ក្នុងអំឡុងឆ្នាំ២០១៤-២០១៨នេះ ជាអាទិ៍**ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ២០១៧-២០២៥ គោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ២០១៤-២០២៥ ក្របខណ្ឌគោលនយោបាយអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យមកម្ពុជា កម្មវិធីអភិវឌ្ឍន៍កសិកម្មនិងជនបទ** និង**កម្មវិធីកំណែទម្រង់ដីធ្លី**ជាដើម។

១.៣. បរិយាកាសសង្គមក្នុងការគាំទ្រ និងលើកកម្ពស់សហគ្រិនភាពស្ត្រីនិងភាពជាអ្នកដឹកនាំក្នុងវិស័យធុរកិច្ចបានពង្រីកជាបន្តបន្ទាប់ តាមរយៈការកើនឡើងនូវព្រឹត្តិការណ៍សាធារណៈ បណ្តាញទំនាក់ទំនង និងការផ្សព្វផ្សាយតាមបណ្តាញសង្គម ដែលបានរៀបចំឡើងក្នុងភាពជាដៃគូរវាងវិស័យសាធារណៈ ឯកជន និងដៃគូពាក់ព័ន្ធ។ **សមាគមសហគ្រិនស្ត្រីកម្ពុជា** (CWEA) និង**សហព័ន្ធស្ត្រីអ្នកជំនួញកម្ពុជា** (CWBF) មានសមាជិកសរុបប្រមាណជាង៥០០នាក់ បាននិងកំពុងដំណើរការយ៉ាងសកម្ម ក្នុងការអនុវត្តមុខងាររបស់ខ្លួន ជាពិសេសលើការគាំទ្រដល់ការអភិវឌ្ឍមុខរបរ រកទីផ្សារសម្រាប់លក់ផលិតផល ការអភិវឌ្ឍសហគ្រិនភាពនិងភាពជាអ្នកដឹកនាំរបស់ស្ត្រី និងដោះស្រាយបញ្ហានានា ព្រមទាំងលើកឡើងនូវសម្លេង និងភាពជាតំណាងរបស់ស្ត្រី

សហគ្រិនក្នុងវិស័យសេដ្ឋកិច្ច នៅក្នុងស្រុក និងក្នុងតំបន់ ។ នៅក្នុងនោះ សហគ្រិនស្ត្រីកម្ពុជា បានចូលរួមយ៉ាងសកម្មក្នុង**បណ្តាញសហគ្រិនស្ត្រីអាស៊ាន**(AWEN) ហើយស្ត្រីសហគ្រិនកម្ពុជាចំនួន៣៨នាក់ ទទួលបានពានរង្វាន់សហគ្រិនស្ត្រីឆ្នើមអាស៊ាន (គិតត្រឹមឆ្នាំ២០១៨)។

១.៤. ការថយចុះគួរឱ្យកត់សម្គាល់នៃការចូលរួមរបស់ស្ត្រី នៅក្នុងប្រភេទការងារដែលងាយរងគ្រោះពី៧០% នៅឆ្នាំ២០១២ និង៥៤,៨% នៅឆ្នាំ២០១៧ ដោយសារការទទួលបានការងារសមរម្យកើនឡើង និងការទទួលបានឱកាសកាន់តែច្រើន ក្នុងការប្រកបមុខរបរ និងសកម្មភាពរកប្រាក់កម្រៃនានា ។

១.៥. ក្រសួងកិច្ចការនារី តាមរយៈមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី ចំនួន១៤ រួមទាំងមន្ទីរកិច្ចការនារីបានផ្តល់ជំនាញវិជ្ជាជីវៈដល់ស្ត្រី ចំនួន៣.៧៤០នាក់ ក្នុង១ឆ្នាំ គិតចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨។ ជាមួយគ្នានេះ ក្រសួងបានចងក្រងជាក្រុមផលិតនិងក្រុមសន្សំ ចំនួន២១១ក្រុម (៥.០៨០គ្រួសារ) លើមុខរបរក្រៅពីកសិកម្ម រួមទាំងសិប្បកម្ម ផលិតកម្មមាន់ ការកែច្នៃចំណីអាហារ និងការអភិវឌ្ឍជំនាញគ្រប់គ្រងអាជីវកម្ម និងការអប់រំបំណិនជីវិត ព្រមទាំងគាំទ្រដល់ខ្សែចង្វាក់ផលិតកម្ម នៅក្នុងខេត្តគោលដៅចំនួន៥ (ព្រៃវែង ស្វាយរៀង តាកែវ កំពត និងកណ្តាល)។

**បញ្ហាប្រឈម និងកាលានុវត្តភាព៖**

- ស្ត្រីភាគច្រើនកំពុងធ្វើការងារក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងក្នុងការងារវិស័យឧស្សាហកម្មដែលផ្តល់ប្រាក់ចំណូលទាប ដែលតម្រូវឱ្យមានការគាំទ្របន្ថែម លើសមត្ថភាព និងការគិតគូរអំពីសុវត្ថិភាពនៅកន្លែងការងារ និងផ្នែកគាំពារសង្គម។
- សមត្ថភាពក្នុងការប្រកួតប្រជែងរបស់ស្ត្រី ដែលចូលរួមនៅក្នុងសកម្មភាពវិស័យសេដ្ឋកិច្ច នៅមានកម្រិតនៅឡើយ ហើយលទ្ធភាពក្នុងការទទួលបានឱកាសនិងការគ្រប់គ្រងធនធាន នៅទាបជាងបុរស រួមទាំងពេលវេលា ព័ត៌មាន ធនធានផលិតកម្ម ហិរញ្ញវត្ថុ និងបច្ចេកវិទ្យាជាដើម។
- ផលិតផលដែលផលិតនៅតាមសហគមន៍ ជាពិសេសរបស់ក្រុមស្ត្រីនៅមិនទាន់ឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងមិនទាន់អាចប្រកួតប្រជែងទីផ្សារក្នុង និងក្រៅស្រុក ។
- ស្របពេលដែលសកម្មភាពនិងពេលវេលារបស់ស្ត្រី បាននិងកំពុងចូលរួមយ៉ាងសកម្ម ទាំងលើការងារមានប្រាក់កម្រៃ និងការងារថែទាំគ្រួសារ តម្រូវការនេះ ត្រូវការជាចាំបាច់ ក្នុងការគិតគូរនិងចែករំលែកការងារទទួលខុសត្រូវពីគ្រួសារ ជាពិសេសពីបុរសលើការងារថែទាំគ្រួសារ និងការគិតគូរអំពីវិធានការតុល្យភាពជីវិតនិងការងារនៅកន្លែងការងារ។

## ២. ការលើកកម្ពស់ការទទួលបានការអប់រំរបស់ស្ត្រី និងក្មេងស្រី និងការផ្លាស់ប្តូរឥរិយាបថ

២.១. គម្លាតយេនឌ័រក្នុងវិស័យអប់រំត្រូវបានកាត់បន្ថយនៅគ្រប់កម្រិត ដោយមានការកើនឡើងនូវកម្មវិធីអាហារូបករណ៍ដល់សិស្ស និស្សិតក្រីក្រ ជាពិសេសនារី ការបង្កើនគ្រឹះស្ថានសិក្សានៅមូលដ្ឋាន ការបង្កើនអន្តេវាសិកដ្ឋាន ដែលផ្តល់សេវាសមរម្យនិងសុវត្ថិភាពសម្រាប់សិស្សនិងនិស្សិតនារី។ គោលនយោបាយ និងកម្មវិធីនៅក្នុងវិស័យអប់រំ ជាវិស័យលេចធ្លោដែលបានឆ្លើយតបនឹងសមភាពយេនឌ័រ និងបរិយាបន្ន រួមទាំងការដាក់បញ្ចូលប្រធានបទស្តីពីយេនឌ័រក្នុងកម្មវិធីសិក្សា និងសូចនាករសំខាន់ៗក្នុងវិស័យអប់រំ ។

២.២. ក្រសួងកិច្ចការនារី បានចូលរួមចំណែកបង្កើតថ្នាក់អក្ខរកម្មសម្រាប់កម្មករកម្មការិនីរោងចក្រ ស្នាក់នៅតាមផ្ទះសរុបចំនួន១.៩២៦នាក់ (ស្រី១.៥៥៩នាក់) គិតត្រឹមឆ្នាំ២០១៨ និងបំផុសចលនាសហគមន៍ ក្នុងការរៀបចំនិងពង្រឹងដំណើរការមត្តេយ្យសិក្សាសហគមន៍នៅខេត្តគោលដៅចំនួន១២ នៅក្នុងភូមិចំនួន១៣៧ សម្រាប់ថ្នាក់មត្តេយសិក្សាសហគមន៍ចំនួន១៩៦ថ្នាក់ ដែលទទួលបានកុមារចូលរៀនសរុបចំនួន១.៣៨៦នាក់ កុមារីចំនួន៧៤៩នាក់ (ពិការចំនួន៥នាក់)។

២.៣. ឆ្លើយតបនឹង**ផែនការសកម្មភាពស្តីពីការបង្ការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ** នៅកម្ពុជា ក្រសួងកិច្ចការនារីបានដឹកនាំក្រុមការងារបច្ចេកទេសអន្តរក្រសួង រៀបចំនិងអនុវត្ត**យុទ្ធសាស្ត្រស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន ២០១៧-២០២១** រួមទាំងឧបករណ៍និងសម្ភារៈពាក់ព័ន្ធ និងបានរៀបចំនិងអនុវត្តសាកល្បងផែនការសកម្មភាពស្តីពីការទប់ស្កាត់អាពាហ៍ពិពាហ៍កុមារ និងការមានផ្ទៃពោះក្នុងវ័យជំទង់ ២០១៧-២០២២ នៅខេត្តរតនគិរី ។

២.៤. កម្មវិធី និងសម្ភារៈអប់រំផ្សព្វផ្សាយក្នុងការផ្លាស់ប្តូរឥរិយាបថជាវិជ្ជមាននិងលើកកម្ពស់តម្លៃស្ត្រី បានផលិត និងដំណើរការផ្សព្វផ្សាយ មានជាអាទិ៍ **កម្មវិធីវិទ្យុនារីរតនៈ** ចំនួន៣០០ប្រធានបទ ល្ខោនអប់រំ ចំនួន១២០ភាគ ព្រឹត្តិប័ត្រនារីរតនៈចំនួន៣០.០០០ច្បាប់ វេទិកាផ្សព្វផ្សាយជាសាធារណៈ ចំនួន២០៤លើក និងកិច្ចសហការជាមួយវិទ្យុជាតិកម្ពុជា ចំនួន៤៨០លើក និងវិទ្យុឯកជន ចំនួន២.៨៨០លើក ។

**បញ្ហាប្រឈម និងកាលានុវត្តភាព ៖**

- ផ្នត់គំនិត និងឥរិយាបថរបស់សង្គមនិងគ្រួសារ នៅបន្តបែងចែកការងារតាមភេទ ដែលជាកត្តារារាំងដល់ការវិវឌ្ឍតួនាទីរបស់ស្ត្រីក្នុងសង្គមទំនើប។ ស្ត្រីនៅបន្តមានទំនោរចាប់យកជំនាញនិងការងារទៅតាមផ្នត់គំនិត និងទស្សនៈរបស់សង្គមនិងគ្រួសារ ដែលធ្វើឱ្យស្ត្រីមិនបានជ្រើសរើសយកជំនាញដែលឆ្លើយតបតម្រូវការទីផ្សារការងារ និងធ្វើឱ្យស្ត្រីដែលជ្រើសរើសការសិក្សា ឬការងារក្នុងវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិតនិងគណិតវិទ្យានៅមានចំនួនតិចតួចនៅឡើយ។ ក្រសួងកិច្ចការនារី ចាំបាច់ត្រូវស្វែងរកលទ្ធភាពថ្មីៗបន្ថែមទៀត ក្នុងការលើកកម្ពស់ការចូលរួមរបស់

ស្ត្រីនិងក្មេងស្រីក្នុងវិស័យអប់រំកម្រិតខ្ពស់ និងជំនាញដែលស្របតាមទីផ្សារការងារនិងបរិបទសង្គម ជាពិសេសពាក់ព័ន្ធការអប់រំផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិតនិងគណិតវិទ្យា។

- ប្រព័ន្ធបច្ចេកវិទ្យានិងបណ្តាញទំនាក់ទំនងសង្គមជានិន្នាការថ្មីនៃការប្រឈមក្នុងការផ្តល់ផលប៉ះពាល់អវិជ្ជមានលើតម្លៃស្ត្រី ។
- ផ្នត់គំនិតនិងឥរិយាបថរើសអើងក្នុងគ្រួសារ កន្លែងការងារ និងទីសាធារណៈនៅបន្តកើតមានលើក្រុមអ្នកស្រលាញ់ភេទដូចគ្នា (LGBTI) និងក្រុមងាយរងគ្រោះផ្សេងៗទៀត នឹងបន្តរារាំងដល់ការអនុវត្តសិទ្ធិ និងសក្តានុពលរបស់ពួកគេ។

## ៣. លើកកម្ពស់សុខភាពស្ត្រីនិងក្មេងស្រី បង្ការនិងទប់ស្កាត់ការឆ្លងមេរោគអេដស៍ និងអាហារូបត្ថម្ភ

៣.១. ក្នុងឆ្នាំ២០១៥ កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសទាំង១០ នៅក្នុងពិភពលោក ដែលសម្រេចបានមុនកាលកំណត់នូវ**គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍** (MDGs) ពាក់ព័ន្ធសុខភាពមាតានិងទារក ដែលក្នុងនោះអត្រាមរណភាពមាតាមានការថយចុះជាបន្តបន្ទាប់ ពី៤៣៧ ក្នុង១០០០០០កំណើតរស់ ក្នុងឆ្នាំ២០០០ មកនៅត្រឹម១៧០ ក្នុង១០០០០០កំណើតរស់ ក្នុងឆ្នាំ២០១៤។ អត្រាប្រេវ៉ាឡង់នៃមេរោគអេដស៍ក្នុងចំណោមប្រជាជនទូទៅអាយុពី១៥-៤៩ឆ្នាំ មានការថយចុះពីកម្រិតខ្ពស់បំផុត ១,៦% នៅឆ្នាំ១៩៩៧ មកត្រឹម០,៥% នៅឆ្នាំ២០១៩ និងទទួលបាន**ពានរង្វាន់កិត្តិយសពីអង្គការសហប្រជាជាតិនៅឆ្នាំ២០១៧** សម្រេចទៅលើគោលដៅ ៩០-៩០-៩០ (៩០% នៃអ្នកផ្ទុកមេរោគអេដស៍ទាំងអស់បានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ពួកគេ ៩០%នៃអ្នកផ្ទុកមេរោគអេដស៍ដែលបានធ្វើរោគវិនិច្ឆ័យហើយ បានទទួលការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ជាប់ជាប្រចាំ និង៩០%នៃអ្នកទាំងអស់ដែលបានទទួលការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ ទទួលបានប្រសិទ្ធភាពខ្ពស់ក្នុងការកាត់បន្ថយចំនួនមេរោគអេដស៍នៅក្នុងខ្លួនដែលលែងជាគ្រោះគំរាមកំហែងដល់អ្នកផ្ទុកមេរោគអេដស៍)។

៣.២. ក្រសួងកិច្ចការនារី បានសហការជាមួយក្រសួងសុខាភិបាល កម្មវិធីជាតិសុខភាពបន្តពូជ មាតានិងទារក អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ កម្មវិធីជាតិសុខភាពភ្នែក ក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ និងដៃគូពាក់ព័ន្ធ អនុវត្តនិងលើកកម្ពស់ការឆ្លើយតបយេនឌ័រនៅក្នុងផែនការយុទ្ធសាស្ត្រ និងកម្មវិធីជាតិពាក់ព័ន្ធនឹងសុខភាព ដូចជា សុខភាពមាតា សុខភាពបន្តពូជនិងសុខភាពផ្លូវភេទ ការបង្ការនិងទប់ស្កាត់ការឆ្លងមេរោគអេដស៍ កម្មវិធីសុខភាពភ្នែក សន្តិសុខស្បៀង អាហារូបត្ថម្ភ អនាម័យនិងទឹកស្អាតជាដើម។

៣.៣. ក្រសួងនិងមន្ទីរកិច្ចការនារី បានចូលរួមបង្កើនការយល់ដឹងដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារថ្នាក់ឃុំ សង្កាត់ ភូមិ និងប្រជាពលរដ្ឋអំពីសុខភាពបន្តពូជ សុខភាពផ្លូវភេទ អាហារូបត្ថម្ភ ជំងឺគ្រុនចាញ់ និងសុខភាពភ្នែក ជាលទ្ធផល ១២៧នាក់ (ស្ត្រី១២៦នាក់) បានទទួលការយល់ដឹងពីសារៈសំខាន់នៃការកសាងទំនាក់ទំនងរវាងមាតានិងយុវតី ទាក់ទងនឹង

សុខភាពបន្តពូជនិងផ្លូវភេទ ចំនួន២.៤៨០នាក់ (ស្ត្រី២៤៥នាក់) បានទទួលការយល់ដឹងមូលដ្ឋានពីសុខភាពបន្តពូជ ការបង្ការនិងទប់ស្កាត់ការឆ្លងមេរោគអេដស៍ ចំនួន១៨៥៨នាក់ (ស្ត្រី១៧១៩នាក់) ទទួលបានការយល់ដឹងអំពីអាហារូបត្ថម្ភ អនាម័យនិងទឹកស្អាត ចំនួន២៤៩.០៤៤នាក់ (ស្ត្រី១៥៣.៣១៨នាក់) ទទួលបានការយល់ដឹងពីជំងឺគ្រុនចាញ់ និងចំនួន៥៩.៧៦២នាក់(ស្ត្រី៤៨.៧៩៦នាក់) ទទួលបានការយល់ដឹងពីយេនឌ័រ និងសុខភាពភ្នែក ។

**បញ្ហាប្រឈម និងកាលានុវត្តភាពៈ**

- ស្ត្រីនិងក្មេងស្រីនៅតែពុំទាន់ទទួលព័ត៌មាន ចំណេះដឹង និងការអនុវត្តបានពេញលេញនូវសិទ្ធិស្តីពីសុខភាពបន្តពូជនិងសុខភាពផ្លូវភេទ ដែលតម្រូវឱ្យមានការជំរុញ ការពង្រឹងនិងពង្រីកវិធានការបន្ថែមឱ្យបានទូលំទូលាយ ជាពិសេសនៅក្នុងចំណោមក្រុមស្ត្រីនិងក្មេងស្រីដែលងាយរងគ្រោះ។
- សុខភាពស្ត្រីនិងក្មេងស្រីនៅតែត្រូវការយកចិត្តទុកដាក់បន្ថែមទៀត ជាពិសេសនៅតំបន់ដាច់ស្រយាល ដោយផ្តោតលើការពង្រីកព័ត៌មាននិងការយល់ដឹងអំពីសារៈសំខាន់នៃការថែទាំសុខភាព អនាម័យ និងអាហារូបត្ថម្ភ។
- តម្រូវការក្នុងការស្វែងរកនិងពង្រីកបន្ថែមទៀត នូវវិធានការក្នុងការទប់ស្កាត់និងដោះស្រាយបញ្ហាពាក់ព័ន្ធជំងឺឆ្លង និងជំងឺមិនឆ្លង ជាពិសេសជំងឺមហារីកមាត់ស្បូន និងមហារីកសុដន។
- ពង្រឹងនូវយន្តការ និងវិធីសាស្ត្រគាំទ្រការរៀបចំ និងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងផែនការពាក់ព័ន្ធវិស័យសុខាភិបាលឱ្យឆ្លើយតបយេនឌ័រ តាមរយៈការអភិវឌ្ឍសមត្ថភាពជាប្រចាំ។

## ៤. កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី

៤.១. លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយនិងផែនការសកម្មភាពជាតិ ដើម្បីទប់ស្កាត់និងឆ្លើយតបគ្រប់ទម្រង់នៃអំពើហិង្សាលើស្ត្រីនិងក្មេងស្រី និងលើកកម្ពស់ប្រសិទ្ធភាពនិងគុណភាពនៃការផ្តល់សេវាពហុវិស័យនៅថ្នាក់ក្រោមជាតិ តាមរយៈការបង្កើត និងដំណើរការក្រុមការងារពហុវិស័យឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដោយមានការចូលរួមពីស្ថាប័នពាក់ព័ន្ធសំខាន់ៗ ដូចជាវិស័យសុខភាព សង្គមកិច្ច យុត្តិធម៌ សេវាផ្នែកច្បាប់ និងមានកិច្ចសហការល្អពីអង្គការដៃគូជាតិ និងអន្តរជាតិ ព្រមទាំងការបង្កើត និងដាក់ឱ្យអនុវត្តសាកល្បងកន្លែងផ្តល់សេវាចម្រុះ ជួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងយេនឌ័រនៅក្នុងខេត្តចំនួន២ ។

៤.២. **ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី លើកទី២ ២០១៤-២០១៨** បានអនុម័តដោយរាជរដ្ឋាភិបាល និងបានអនុវត្តដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ តាមរយៈផែនការប្រតិបត្តិរបស់ក្រសួង-ស្ថាប័ន និងមុខងាររបស់យន្តការនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិគ្រប់កម្រិត ។

៤.៣. ក្រសួងបានសម្របសម្រួល និងគាំទ្រក្នុងការបង្កើត និងអនុវត្តក្រុមការងារពហុវិស័យឆ្លើយតបអំពើហិង្សាទាក់ទងយេនឌ័រ ក្នុងខេត្តចំនួន០៨ និងគ្រោងពង្រីកគ្រប់រាជធានី ខេត្ត។ ជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារចំនួន១.១៩១ករណី បានទទួលអត្ថប្រយោជន៍ពីសេវាចម្រុះនេះ។ មន្ត្រីក្រសួងកិច្ចការនារីចំនួន៩៨រូប(ស្ត្រី៨៥រូប) បានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌និងបន្តអភិវឌ្ឍសមត្ថភាពជាបន្តបន្ទាប់។

៤.៤. ក្រសួងកិច្ចការនារី និងក្រសួងព័ត៌មាន បានបង្កើតនិងដាក់ឱ្យប្រើប្រាស់**ក្រុមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់រាយការណ៍ព័ត៌មានអំពើហិង្សាលើស្ត្រី** និងផ្សព្វផ្សាយដល់បណ្ដាញសារព័ត៌មាន និងអ្នកពាក់ព័ន្ធ។

៤.៥. ក្រសួង បានបង្កើតនិងប្រកាសឱ្យប្រើប្រាស់**គោលការណ៍ណែនាំ ស្តីពី កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រីនិងកុមារ** បទដ្ឋានអប្បបរមាសម្រាប់ការប្រឹក្សាយោបល់មូលដ្ឋានជួយដល់ស្ត្រីនិងក្មេងស្រី **គោលការណ៍ណែនាំស្តីពីការប្រមូលទិន្នន័យនិងគ្រប់គ្រងករណីហិង្សា** និង**គោលការណ៍ណែនាំស្តីពីការបញ្ជូនស្ត្រីនិងក្មេងស្រីដែលជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ** ព្រមទាំងបានអភិវឌ្ឍសមត្ថភាពរបស់អ្នកផ្តល់សេវាឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អំពីឧបករណ៍ទាំងនេះ។

៤.៦. ក្រុមការងារកម្ពុជាប្រឆាំងការជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ (COMMIT) បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ក្នុងការប្រឆាំងអំពើជួញដូរមនុស្ស (កម្ពុជា ចិន ឡាវ មីយ៉ាន់ម៉ា និងវៀតណាម) និងបានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍រួមលើកទី៣ ស្តីពីការប្តេជ្ញាចិត្តក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។ ក្រុមការងារសហប្រតិបត្តិការអន្តរជាតិនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ត្រូវបានបង្កើត និងដឹកនាំដោយក្រសួងកិច្ចការនារី។

**បញ្ហាប្រឈម និងកាលានុវត្តភាព៖**

- ស្ត្រីនិងក្មេងស្រី នៅតែប្រឈមនឹងអំពើហិង្សាផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត និងផ្នែកជីវភាពសេដ្ឋកិច្ច ដែលអំពើហិង្សាទាំងនោះអាចកើតមានទាំងនៅក្នុងផ្ទះ នៅកន្លែងធ្វើការ និងក្នុងសហគមន៍ ហើយគ្រប់ប្រភេទនៃអំពើហិង្សាទាំងនេះអាចកើតឡើងចំពោះស្ត្រីនិងក្មេងស្រី ដោយមិនគិតពីកម្រិតនៃប្រាក់ចំណូល កម្រិតវប្បធម៌ និងចំណេះដឹងនោះឡើយ។
- ក្រសួងកិច្ចការនារី ត្រូវការចាំបាច់ក្នុងការពិនិត្យលើវិធីសាស្ត្រ និងពង្រឹងការអនុវត្តកម្មវិធីចិញ្ចឹមកូនបែបវិជ្ជមាន វប្បធម៌អហិង្សា ជំរុញការអនុវត្តច្បាប់និងផែនការយុទ្ធសាស្ត្រក្នុងការទប់ស្កាត់គ្រប់ទម្រង់នៃអំពើហិង្សាលើស្ត្រីនិងក្មេងស្រី រួមទាំងលើកកម្ពស់សុខុមាលភាពគ្រួសារ ក៏ដូចជាកិច្ចគាំពារសង្គមសម្រាប់ស្ត្រីនិងក្មេងស្រី ។

- ភាពចាំបាច់ក្នុងការពង្រឹង និងពង្រីកយន្តការភាពជាដៃគូជាមួយវិស័យឯកជន និងដៃគូពាក់ព័ន្ធ រួមទាំងការចូលរួមការទទួលខុសត្រូវពីបុរស និងបណ្ដាញអ្នកសារព័ត៌មានក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងលើកកម្ពស់សមភាពយេនឌ័រ ។
- កន្លែងផ្ដល់សេវាចម្រុះជួយស្ត្រីរងគ្រោះដោយអំពើហិង្សា កំពុងក្លាយជាយន្តការដ៏មានប្រសិទ្ធភាពមួយក្នុងការឆ្លើយតប និងដោះស្រាយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ។
- បន្តពង្រឹង និងពង្រីកការឆ្លើយតបទៅនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅថ្នាក់ក្រោមជាតិ ដែលផ្ដោតទៅលើយន្តការដែលមានស្រាប់នៅថ្នាក់ក្រោមជាតិ (ខេត្ត ស្រុក)។

## ៥. ស្ត្រី ក្នុងវិស័យសាធារណៈ និងនយោបាយ

៥.១. ការលើកកម្ពស់ស្ត្រីនៅក្នុងវិស័យសាធារណៈនិងថ្នាក់ធ្វើសេចក្ដីសម្រេចនៅគ្រប់កម្រិត ត្រូវបានចាត់ទុកជាចំណុចអាទិភាពក្នុងកម្មវិធីនយោបាយ **យុទ្ធសាស្ត្រចតុកោណ** គោលនយោបាយតាមវិស័យការងារកំណែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីវិមជ្ឈការនិងវិសហមជ្ឈការ រួមទាំងនៅក្នុងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៅតាមវិស័យ នៅតាមក្រសួង-ស្ថាប័ន។

៥.២. ក្រសួង-ស្ថាប័នភាគច្រើន បានអនុវត្តគោលការណ៍ជ្រើសរើសមន្ត្រីរាជការថ្មី ដែលយកចិត្តទុកដាក់បង្កើនចំនួនមន្ត្រីរាជការជាស្ត្រី ជាពិសេសលើ**ការកំណត់ជ្រើសរើសមន្ត្រីរាជការជាស្ត្រី ពី២០% ទៅ៥០%** ក្នុងក្របខណ្ឌថ្មី ការអនុវត្ត**ព្រះរាជក្រឹត្យស្ដីពីការពន្យារអាយុនៃការចូលនិវត្តន៍របស់មន្ត្រីរាជការជាស្ត្រី ដល់អាយុ ៦០ឆ្នាំ** និងវិធានការតែងតាំងស្ត្រីនៅក្នុងរចនាសម្ព័ន្ធដឹកនាំនិងគ្រប់គ្រង យ៉ាងតិច១រូប នៅក្នុងក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់កម្រិត។ ជាក់ស្ដែង គិតត្រឹមឆ្នាំ២០១៨ នៅកម្ពុជាមានមន្ត្រីរាជការជាស្ត្រី មាន ៤១% ក្នុងចំណោមមន្ត្រីរាជការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងស្ត្រីជាថ្នាក់ដឹកនាំដែលមានតួនាទីចាប់ពីអនុប្រធានការិយាល័យ ដល់អគ្គនាយក មាន២៤% ។ នៅក្នុងគណៈអភិបាលរាជធានី ខេត្ត ស្ត្រី ១រូប ជាអភិបាលខេត្ត (ស្មើ ៤%) អភិបាលរង ២៦រូប (ស្មើ ១៧,៤៤%)។ នៅក្នុងគណៈអភិបាលក្រុង ស្រុក ខណ្ឌ មានអភិបាលក្រុង ស្រុក ខណ្ឌ ចំនួន៦រូប ជាស្ត្រី (ស្មើ ៣,០៦%) និងអភិបាលរងក្រុង ស្រុក ខណ្ឌ ជាស្ត្រី មានចំនួន១៩៤រូប (ស្មើ ២៥,៥២%) ។

៥.៣. ក្រសួងកិច្ចការនារី ក្នុងភាពជាដៃគូជាមួយសាលាភូមិន្ទរដ្ឋបាល ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាលាជាតិរដ្ឋបាលមូលដ្ឋាន បានរៀបចំ និងអនុវត្តកម្មវិធីអភិវឌ្ឍភាពជាអ្នកដឹកនាំរបស់ស្ត្រី ជាអាទិ៍ក្នុងឆ្នាំ២០១៦ សាលាភូមិន្ទរដ្ឋបាល បានបណ្ដុះបណ្ដាលថ្នាក់ដឹកនាំជាស្ត្រី មកពីគ្រប់ក្រសួង-ស្ថាប័ន សរុប៨៣រូប មានឋានៈជារដ្ឋលេខាធិការ ៣៣រូប និងអនុរដ្ឋលេខាធិការ ៥០រូប ប្រកបដោយជោគជ័យ។ ក្រសួងកិច្ចការនារី បានពង្រឹងបណ្ដាញ និងអភិវឌ្ឍសមត្ថភាពស្ត្រីជាសមាជិកាក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អភិបាល និង

អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងថ្នាក់ដឹកនាំមន្ទីរកិច្ចការនារី ដែលមានចំនួនសរុប៩៣៣រូប ។

៥.៤. កម្មវិធីលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការជំរុញការគាំទ្រការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យនយោបាយនិងភាពជាអ្នកដឹកនាំ បានរៀបចំនិងផ្សព្វផ្សាយនៅក្នុងបណ្តាញសង្គមនិងតាមសហគមន៍ ដោយមានការចូលរួមភាពជាដៃគូជាមួយសង្គមស៊ីវិល និងដៃគូពាក់ព័ន្ធនៅគ្រប់កម្រិត ។

៥.៥. ក្រសួង បានបង្កើតក្រុមការងារបច្ចេកទេសស្តីពីស្ត្រីក្នុងភាពជាអ្នកដឹកនាំនិងអភិបាលកិច្ច (TWGG-WLG) នៅឆ្នាំ២០១៥ ដែលជាផ្នែកមួយនៃក្រុមការងារបច្ចេកទេសយេនឌ័រ (TWG-G) ក្នុងគោលបំណងសម្របសម្រួលការលើកកម្ពស់ស្ត្រីក្នុងថ្នាក់ធ្វើសេចក្តីសម្រេច និងពង្រឹងសមភាពយេនឌ័រនៅក្នុងដំណើរការអភិបាលកិច្ច ដែលមានសមាសភាពមកពីក្រសួង-ស្ថាប័ន (ក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ ក្រសួងអប់រំ យុវជននិងកីឡា លេខាធិការដ្ឋាន គ.ជ.អ.ប អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ ក.ជ.ក.ស និងសាលាភូមិន្ទរដ្ឋបាល) តំណាងដៃគូអភិវឌ្ឍន៍ (UNDP, UN Women, Oxfam) និងតំណាងសង្គមស៊ីវិល។ ក្រុមការងារបានរៀបចំកិច្ចប្រជុំរៀងរាល់ត្រីមាស ដើម្បីពិនិត្យលើវឌ្ឍនភាពក្នុងការអនុវត្តការងារ និងចែករំលែកបទពិសោធន៍ទាក់ទងភាពជាអ្នកដឹកនាំរបស់ស្ត្រីនិងការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធីកំណែទម្រង់នានា។

៥.៦. ក្នុងភាពជាដៃគូរវាងក្រសួងកិច្ចការនារី និងលេខាធិការដ្ឋាន គ.ជ.អ.ប បានរៀបចំនិងអនុវត្តផែនការយុទ្ធសាស្ត្របង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាវិធានការជំរុញ និងធានាថារាល់ការយកចិត្តទុកដាក់ពាក់ព័ន្ធការលើកកម្ពស់សមភាពយេនឌ័រ ដែលកំណត់ក្នុងក្របខណ្ឌកម្មវិធីជាតិ ត្រូវបានអនុវត្ត និងធ្វើស្ថាប័ននីយកម្មឱ្យកាន់តែពេញលេញ និងប្រកបដោយប្រសិទ្ធភាព។

**បញ្ហាប្រឈម និងកាលានុវត្តភាព៖**

- និន្នាការនៃការកើនឡើងតំណាងស្ត្រី ក្នុងវិស័យនយោបាយនៅមានកម្រិតនៅឡើយ បើធៀបនឹងការចូលរួមនៅក្នុងវិស័យសេដ្ឋកិច្ច និងសាធារណៈ។
- ផ្នត់គំនិតរបស់សង្គមដែលបន្តចាត់ទុកការងារផ្ទះសម្បែងនិងការមើលថែទាំគ្រួសារជាកាតព្វកិច្ចរបស់ស្ត្រី បានរារាំងជាចម្បងដល់ស្ត្រី មិនអាចអនុវត្តសិទ្ធិ និងប្រើប្រាស់សក្តានុពលពេញលេញលើកិច្ចការក្នុងវិស័យសាធារណៈ និងភាពជាអ្នកដឹកនាំ ។
- ការគាំទ្រនៅកន្លែងធ្វើការងារដែលមានលក្ខណៈទន់ភ្លន់និងបត់បែន ដែលលើកកម្ពស់តុល្យភាពជីវិតនិងការងារ ជាកត្តាលើកទឹកចិត្តស្ត្រី ចូលបំពេញការងារប្រកបដោយផលិតភាពនិងប្រសិទ្ធផល។
- បន្តលើកកម្ពស់ការចូលរួមរបស់ស្ត្រីជាតំណាងក្នុងការអនុវត្តមុខងារតាមវិស័យរបស់ខ្លួនទាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន និងអភិវឌ្ឍសមត្ថភាពពួកគេជាប្រចាំទៅតាមតម្រូវការ ។

- អភិវឌ្ឍសមត្ថភាព និងអនុវត្តគំនិតផ្តួចផ្តើមនានាសម្រាប់យុវជន និងស្ត្រីវ័យក្មេងស្តីពីភាពជាអ្នកដឹកនាំអភិបាលកិច្ច ឆ្លើយតបនឹងយេនឌ័រនិងបរិយាបន្ន ។

## ៦. យេនឌ័រ និងការប្រែប្រួលអាកាសធាតុ

៦.១. ក្រសួងកិច្ចការនារី និងក្នុងនាមសមាជិកក្រុមប្រឹក្សាជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានចូលរួមជំរុញការយកចិត្តទុកដាក់ និងឆ្លើយតបបញ្ហាស្ត្រី កុមារី និងយេនឌ័រនៅក្នុងរបៀបវារៈតាក់តែងនិងអនុវត្តគោលនយោបាយឆ្លើយតបការអភិវឌ្ឍបៃតង ការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងការកាត់បន្ថយហានិភ័យ និងផលប៉ះពាល់នៃគ្រោះមហន្តរាយ។

៦.២. គណៈកម្មាធិការដឹកនាំ និងសម្របសម្រួលការងារយេនឌ័រនិងការប្រែប្រួលអាកាសធាតុនៃក្រសួងកិច្ចការនារី បាននិងកំពុងអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរាជការ ដៃគូពាក់ព័ន្ធនៅថ្នាក់ជាតិ និងក្រោមជាតិ ដែលជាលទ្ធផល មន្ត្រីចំនួន៣៥៧រូប (ស្ត្រី៥៣%) បានទទួលការបណ្តុះបណ្តាលពាក់ព័ន្ធការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធីប្រែប្រួលអាកាសធាតុ។ សេចក្តីព្រាងគោលការណ៍ស្តីពីការបញ្ជ្រាបយេនឌ័រទៅក្នុងការវិនិយោគដែលឆ្លើយតបការបន្សាំនិងការប្រែប្រួលអាកាសធាតុក្នុងវិស័យជាអាទិភាព ចំនួន៥ (កសិកម្ម អភិវឌ្ឍន៍ជនបទ សុខាភិបាល ធនធានទឹក និងសាធារណៈការនិងដឹកជញ្ជូន)។

៦.៣. **ផែនការយុទ្ធសាស្ត្រស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ២០១៤-២០២៣ ផែនការមេស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ២០១៨-២០៣០ និងផែនការសកម្មភាពស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ២០១៩-២០២៣** បានរៀបចំនិងដាក់ជាផែនទីតម្រង់ទិសសម្រាប់រៀបចំផែនការសកម្មភាពគម្រោងកម្មវិធី។ គម្រោងសាកល្បង ចំនួន៤ ស្តីពីការវិភាគយេនឌ័រនិងការគិតគូរផលចំណេញផ្នែកសេដ្ឋកិច្ច ការបង្កើនសមត្ថភាពស្ត្រីក្នុងការបន្សាំនិងកសាងភាពធន់នឹងអាកាសធាតុ ការគ្រប់គ្រងទឹកស្អាតនិងអនាម័យ ការកាត់បន្ថយហានិភ័យនៃទឹកជំនន់និងគ្រោះរាំងស្ងួត នៅក្នុងខេត្តកំពង់ធំ បាត់ដំបង ព្រៃវែង និងខេត្តកំពត ត្រូវបានអនុវត្តប្រកបដោយជោគជ័យ។

**បញ្ហាប្រឈម និងកាលានុវត្តភាព៖**

- កង្វះព័ត៌មាន និងទិន្នន័យបែងចែកតាមភេទ និងការសិក្សាស្រាវជ្រាវស៊ីជម្រៅពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើស្ត្រី កុមារ និងក្រុមជនដែលងាយរងគ្រោះ។
- ធនធានសម្រាប់កម្មវិធីថ្មីៗពាក់ព័ន្ធបញ្ជ្រាបយេនឌ័រ ក្នុងការបន្សាំនិងកសាងភាពធន់ដើម្បីកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយបណ្តាលមកពីការប្រែប្រួលអាកាសធាតុនៅមានកម្រិត។

- ភាពចាំបាច់ក្នុងការលើកកម្ពស់ការចូលរួម និងតំណាងរបស់ស្ត្រីបន្ថែមទៀត ជាពិសេសស្ត្រីនៅតំបន់ជនបទ ស្ត្រីជនជាតិដើមភាគតិច នៅក្នុងការរៀបចំនិងអនុវត្តគោលនយោបាយ និងផែនការសកម្មភាពដែលឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ ។
- ការពង្រឹងយន្តការសម្របសម្រួលនៅគ្រប់កម្រិត ភាពជាដៃគូជាមួយអ្នកពាក់ព័ន្ធ និងតម្រូវការអភិវឌ្ឍសមត្ថភាពបច្ចេកទេសលើការវិភាគយេនឌ័រក្នុងបរិបទការប្រែប្រួលអាកាសធាតុ ព្រមទាំងស្វែងរកសក្តានុពលបន្ថែមទៀតក្នុងការបង្កើនភាពអង់អាចដល់ស្ត្រី និងការបញ្ជ្រាបយេនឌ័រនៅក្នុងកម្មវិធីប្រែប្រួលអាកាសធាតុ ។

## ៧. ការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ និងកម្មវិធីកំណែទម្រង់រាជរដ្ឋាភិបាល

៧.១. គោលនយោបាយជាតិជាច្រើនបានដាក់ចេញនូវការការពារសិទ្ធិរបស់ស្ត្រី និងការឆ្លើយតបសមភាពយេនឌ័រ មានដូចជា **គោលនយោបាយអភិវឌ្ឍយុវជនកម្ពុជា គោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត គោលនយោបាយជាតិប្រជាជន ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម គោលនយោបាយជាតិស្តីពីអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ មុខរបរនិងការងារ ការអភិវឌ្ឍបៃតង** រួមទាំងកម្មវិធី និងលិខិតបទដ្ឋានគតិយុត្តលើការងារកំណែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីវិមជ្ឈការនិងវិសហមជ្ឈការ ។

៧.២. យេនឌ័របានបញ្ជ្រាបនិងជំរុញការអនុវត្តនៅក្នុងកម្មវិធីកំណែទម្រង់ជាតិសំខាន់ៗ ដូចជា**កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** និង**កម្មវិធីជាតិ១០ឆ្នាំ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** និងផែនការអនុវត្តជាបន្តបន្ទាប់ ។

៧.៣. ការរីកចម្រើនគួរឱ្យកត់សម្គាល់ ក្នុងការពង្រឹងយន្តការបញ្ជ្រាបយេនឌ័រ រួមបញ្ចូលទាំងក្រុមការងារបច្ចេកទេសយេនឌ័រ ដែលជាផ្នែកមួយនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ និងដំណើរការរបស់ក្រុមការងារយេនឌ័រតាមក្រសួង-ស្ថាប័នពាក់ព័ន្ធ។ គិតត្រឹមឆ្នាំ២០១៨ ក្រសួង-ស្ថាប័នចំនួន២៨ក្នុងចំណោម៣០ បានរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រតាមវិស័យ។ នៅថ្នាក់ក្រោមជាតិ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ បាននិងកំពុងអនុវត្តកម្មវិធីលើកកម្ពស់ស្ថានភាពស្ត្រីនិងកុមារនៅថ្នាក់មូលដ្ឋាន។

**បញ្ហាប្រឈម និងកាលានុវត្តភាព៖**

- គណនេយ្យភាពរបស់ក្រសួង-ស្ថាប័ន ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងការធ្វើទំនើបកម្មស្ថាប័ននីយកម្មផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រមិនទាន់បានពេញលេញ និងទូទាំងវិស័យ។

- ភាពចាំបាច់ក្នុងការអភិវឌ្ឍសមត្ថភាព និងការអនុវត្តមុខងាររបស់យន្តការបញ្ជ្រាបយេនឌ័រគ្រប់កម្រិត និងពង្រឹងក្របខណ្ឌត្រួតពិនិត្យតាមដាន និងវាយតម្លៃតាមវិស័យ។
- តម្រូវការពង្រឹង និងពង្រីកប្រព័ន្ធចងក្រង ចែករំលែកបទពិសោធន៍ និងលើកទឹកចិត្តដល់កិច្ចការដែលមានឧត្តមានុវត្តន៍ ។
- តម្រូវការរៀបចំឯកសារគោលការណ៍ណែនាំជាតិស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យ ដែលជាជំនួយបច្ចេកទេសដល់ក្រសួង-ស្ថាប័ន លើការងារបញ្ជ្រាបយេនឌ័រទៅក្នុងវិស័យ និងអង្គភាពរបស់ខ្លួន។
- ការថយចុះ**ជំនួយផ្លូវការសម្រាប់ការអភិវឌ្ឍ** (ODA) លើគ្រប់វិស័យ រួមទាំងការងារយេនឌ័រ ដែលចាំបាច់ត្រូវការស្វែងរកកាលានុវត្តភាពថ្មីៗបន្ថែមទៀត រួមទាំងលើកកម្ពស់ការចូលរួមពីវិស័យឯកជន និងថវិកាជាតិ។

## ៨. ការអភិវឌ្ឍស្ថាប័ន និងសមត្ថភាពសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី៤

៨.១. ក្រសួងកិច្ចការនារីបានចូលរួមយ៉ាងយកចិត្តទុកដាក់ ក្នុងការអនុវត្តការងារកំណែទម្រង់សាធារណៈរបស់ជាតិ ជាពិសេសលើ**កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ** ក្នុងការពង្រឹងសមត្ថភាពស្ថាប័ននិងការបង្កើនប្រសិទ្ធភាពសេវាសាធារណៈរបស់ក្រសួង **កម្មវិធីវិមជ្ឈការនិងវិសហមជ្ឈការ** ក្នុងការផ្ទេរមុខងារទៅរដ្ឋបាលនៅថ្នាក់ក្រោមជាតិ និង**កម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ** ក្នុងការអនុវត្តនិងគ្រប់គ្រងថវិកាប្រកបដោយប្រសិទ្ធភាព ។

៨.២. មន្ត្រីរាជការក្រសួងកិច្ចការនារីទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ត្រូវបានតែងតាំង ប្រគល់ភារកិច្ចសម្រួលភារកិច្ច និងបានពិនិត្យនីត្យានុកូលភាពសរុបចំនួន២៣៦នាក់ ស្ត្រី១៨២នាក់ តម្លើងឋានន្តរស័ក្តិ ថ្នាក់ និងធ្វើនិយ័តកម្មសរុបចំនួន២.៤៥៧នាក់ ស្ត្រី២.១២១នាក់ និងជាការលើកទឹកចិត្តដល់មន្ត្រីរាជការតាមរយៈការផ្តល់គ្រឿងឥស្សរិយយសចំនួន៥៨៣នាក់ ស្ត្រី៤៩៧នាក់។ ជាមួយនឹងការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍សរុបចំនួន១៦២នាក់ ស្ត្រី១៤៨នាក់ ក្រសួងក៏បានធ្វើការជ្រើសរើសក្របខណ្ឌមន្ត្រីរាជការចំនួន១៣៩នាក់ ស្ត្រី១០៣នាក់ និងបានអភិវឌ្ឍសមត្ថភាពលើការងារគ្រប់គ្រងរដ្ឋបាលដល់មន្ត្រី រាជការសរុបចំនួន៦៦៦នាក់ ស្ត្រី៥០៧នាក់។

៨.៣. តាមរយៈ**ថវិកាតាមកម្មវិធី**(PB) និងការគាំទ្រពីដៃគូពាក់ព័ន្ធ ក្រសួងកិច្ចការនារីបានផ្តោតជាអាទិភាពលើការអភិវឌ្ឍសមត្ថភាពថ្នាក់ដឹកនាំនិងមន្ត្រីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី លើជំនាញនិងចំណេះដឹងតាមវិស័យ រួមទាំងអភិវឌ្ឍភាពជាអ្នកដឹកនាំ ការគ្រប់គ្រងរដ្ឋបាលសាធារណៈ ការរៀបចំផែនការ ការត្រួតពិនិត្យនិងវាយតម្លៃឆ្លើយតបយេនឌ័រ កិច្ចការស្ត្រីនិងអាស៊ាន និងការរៀបចំកិច្ចព្រមព្រៀងរវាងក្រសួងនិងអង្គការជាតិនិងអន្តរជាតិ។ ជាមួយគ្នានេះ ក្រសួងបានបញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ

ក្រសួងនិងមន្ទីរកិច្ចការនារី ទៅចូលរួមព្រឹត្តិការណ៍អន្តរជាតិនិងវគ្គបណ្តុះបណ្តាលនៅក្រៅប្រទេសសរុបចំនួន ២៨៦នាក់ ស្ត្រី២០៩នាក់ ។

៨.៤. ក្រសួងកិច្ចការនារីបានផ្តួចផ្តើមរៀបចំនិងដាក់ឱ្យដំណើរការទារកដ្ឋានក្នុងការមើលថែទាំទារកនិងកុមារតូចៗ សម្រាប់ជួយសម្រាលបន្ទុកដល់មន្ត្រី ដើម្បីមានឱកាសនិងពេលវេលាក្នុងការបំពេញតួនាទីនិងភារកិច្ចឱ្យកាន់តែមានប្រសិទ្ធភាព។

៨.៥. ក្រុមការងារសកម្មភាពជនពិការរបស់ក្រសួងកិច្ចការនារី បានបង្កើតនៅឆ្នាំ២០១៥ ដែលជាយន្តការសម្របសម្រួលនិងពិគ្រោះយោបល់លើបញ្ហាពិការភាពក្នុងក្របខណ្ឌក្រសួង។ នៅឆ្នាំ២០១៥-២០១៨ ក្រុមការងារ បានចូលរួមយ៉ាងសកម្មក្នុងការលើកកម្ពស់ការឆ្លើយតបបញ្ហារបស់ជនដែលមានពិការភាពដែលជាមន្ត្រីក្រសួង និងនៅក្នុងយុទ្ធសាស្ត្ររបស់នារីរតនៈទី៤។ ជាមួយគ្នានេះ ក្រុមការងារបានរៀបចំ និងអនុវត្តផែនការអភិវឌ្ឍសមត្ថភាពស្តីពីយេនឌ័រនិងពិការភាព និងជំនាញក្នុងការស្វែងរកការគាំទ្រមតិ ដើម្បីសមភាពយេនឌ័រនិងពិការភាព ដល់ថ្នាក់ដឹកនាំ និងមន្ត្រីក្រសួងកិច្ចការនារី និងក្រសួង-ស្ថាប័នពាក់ព័ន្ធ សរុបចំនួន ៥៤០នាក់ (ស្ត្រី៥២០នាក់)។ តំណាងក្រសួងកិច្ចការនារី បានចូលរួមយ៉ាងសកម្មក្នុងក្រុមប្រឹក្សាសកម្មភាពជនពិការ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ឆ្នាំ២០១៤-២០១៨ ជាពិសេសលើទិសដៅយុទ្ធសាស្ត្រទី៩ ស្តីពីការធានាសមភាពយេនឌ័រនិងការលើកកម្ពស់សមត្ថភាពស្ត្រីនិងកុមារមានពិការភាព។

៨.៦. បណ្តាញមន្ត្រីវ័យក្មេងរបស់ក្រសួងកិច្ចការនារី បានដំណើរការក្នុងការពង្រឹងភាពអង់អាចនិងអភិវឌ្ឍសមត្ថភាពដល់មន្ត្រីវ័យក្មេង និងការពង្រឹងភាពជាដៃគូជាមួយនឹងក្រុមយុវជន នៅខាងក្រៅ រួមទាំងនៅតាមបណ្តាគ្រឹះស្ថានសិក្សា ក្នុងការចូលរួមលើការងារលើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិស្ត្រី។ នៅក្នុងនោះ មន្ត្រីវ័យក្មេងរបស់ក្រសួងកិច្ចការនារី បានចូលរួមវគ្គកាតព្វកិច្ចលើមូលដ្ឋានគ្រឹះនៃការងារអនុវត្ត ការងារបញ្ជ្រាបយេនឌ័រ និងមុខងារគន្លឹះៗរបស់ក្រសួងកិច្ចការនារី និងកាអភិវឌ្ឍលើភាពជាអ្នកដឹកនាំ និងជំនាញទន់ ដែលមានចំនួនសរុប១២៧រូប ស្ត្រី៨៥រូប ។

៨.៧. ក្នុងក្របខណ្ឌនៃ**ផែនការយុទ្ធសាស្ត្រនារីរតនៈទី៤** ការអនុវត្តអភិក្រមទូទាំងកម្មវិធីចំនួនពីរ បានដំណើរការ ដែលក្រសួងកិច្ចការនារីដើរតួក្នុងភាពជាម្ចាស់ ហើយមានការចូលរួមពីដៃគូអភិវឌ្ឍនិងអ្នកពាក់ព័ន្ធគឺ ក្របខណ្ឌនៃផែនការប្រតិបត្តិសម្រាប់អនុវត្ត **ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកម្មវិធីដំណើរឆ្ពោះទៅមុខដើម្បីសមភាពយេនឌ័រ** ។

៨.៨. ក្រសួងបានពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការនិងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការជាតិ អន្តរជាតិ ដើម្បីចូលរួមចំណែកអនុវត្ត**ផែនការយុទ្ធសាស្ត្រនារីរតនៈទី៤**។ ដៃគូអភិវឌ្ឍន៍សំខាន់ៗអនុវត្តកម្មវិធីនិងគម្រោង ក្នុងអំឡុងឆ្នាំ២០១៤-២០១៨ មានជាអាទិ៍ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) មូលនិធិអន្តរជាតិអភិវឌ្ឍន៍វិស័យកសិកម្ម (IFAD), រដ្ឋាភិបាលអូស្ត្រាលី ស្ថានទូតឥណ្ឌា មូលនិធិសកល (Global Fund),

Fred Hollow Foundation, DFAT, GIZ, UNFPA, JICA, UNICEF, UNDP, UN Women, Oxfam, Save the children, CHEC, HEIFER, CARE, GVC, PYD, KWDI, APHEDAជាដើម។

៨.៩. ក្រសួងបានចូលរួមក្នុងគណៈកម្មាធិការអាស៊ានដើម្បីស្ត្រី(ACW) និងគណៈកម្មការអាស៊ានដើម្បីលើកកម្ពស់និងការពារសិទ្ធិស្ត្រីនិងកុមារ (ACWC) ជាពិសេសតាមរយៈកិច្ចប្រជុំសំខាន់ៗ ចំនួន២០លើក ។

៨.១០. ប្រព័ន្ធបណ្ដាញសង្គមរបស់ក្រសួងកិច្ចការនារី ជាមធ្យោបាយថ្មីសម្រាប់ក្រសួង ក្នុងការទំនាក់ទំនង និងផ្សព្វផ្សាយដល់សាធារណជនតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល។ គិតត្រឹមឆ្នាំ២០១៨ ទំព័រហ្វេសប៊ុកក្រសួងកិច្ចការនារី មានសមាជិកជាង៧ម៉ឺននាក់ និងមានអ្នកចូលមើលប្រមាណចំនួន១លាននាក់ក្នុងមួយឆ្នាំ ។

**បញ្ហាប្រឈម និងកាលានុវត្តភាពៈ**

- ការអភិវឌ្ឍធនធានមនុស្សរបស់ក្រសួងកិច្ចការនារី ត្រូវមានក្របខណ្ឌផែនការច្បាស់លាស់ ត្រូវការពេលវេលាក្នុងការអនុវត្ត និងបន្លាស់ប្ដូរតាមលំដាប់លំដោយ ជាពិសេសដើម្បីឱ្យស្របតាមតម្រូវការ និងនិន្នាការរបស់សង្គម ។
- ការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ គឺជាជំហានថ្មីមួយ ក្នុងការផ្លាស់ប្ដូរមុខងាររបស់ក្រសួងកិច្ចការនារី ពីរបៀបអនុវត្តន៍ការងារ ទៅរកការគ្រប់គ្រងទូទាំងកម្មវិធី និងឈានទៅរកអ្នកជំនាញ ក្នុងការផ្ដល់ប្រឹក្សាបច្ចេកទេសជាអ្នកឯកទេសយេនឌ័រតាមវិស័យ ។
- ការធ្វើបរិយាបន្នឆ្លើយតបចំពោះស្ត្រីដែលស្ថិតក្នុងក្រុមជនងាយរងគ្រោះមួយចំនួន នៅក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី៤នៅមានកម្រិត ដែលតម្រូវឱ្យមានការពង្រឹងសមត្ថភាព ស្របទៅតាមតម្រូវការជាក់លាក់និងបរិបទថ្មីៗរបស់សង្គម ព្រមទាំងកំណត់ឱ្យវិធានការជាក់លាក់ក្នុងការជំរុញនិងតាមដាននៅតាមអង្គភាពនានា និងក្នុងកិច្ចសហការជាមួយដៃគូពាក់ព័ន្ធគ្រប់កម្រិត ។
- ប្រព័ន្ធតាមដាននិងវាយតម្លៃរបស់ផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ មិនទាន់អនុវត្តបានពេញលេញ ដែលតម្រូវឱ្យមានការកំណត់យន្តការ និងប្រព័ន្ធការងារឱ្យបានច្បាស់លាស់ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។
- មូលនិធិដៃគូអភិវឌ្ឍន៍សម្រាប់គាំទ្រនាយកដ្ឋាន និងអង្គភាពជំនាញរបស់ក្រសួងកិច្ចការនារី មានការថយចុះ ដែលតម្រូវឱ្យមានការស្វែងរកប្រភពថ្មីៗ ពង្រឹងភាពជាដៃគូប្រកបដោយយុទ្ធសាស្ត្រ និងពង្រីកប្រសិទ្ធភាពក្នុងការអនុវត្តកម្មវិធីដែលគាំទ្រដោយថវិកាជាតិ។

# ផ្នែកទី ២.

# ចក្ខុវិស័យ និងបេសកកម្ម

## ចក្ខុវិស័យ

ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិស្មើគ្នាស្របតាមច្បាប់ ជាពិសេសស្ត្រី និងក្មេងស្រី ទទួលបានសុវត្ថិភាពផ្ទាល់ខ្លួន ព្រមទាំងអាចចូលរួមយ៉ាងពេញលេញនៅក្នុងកិច្ចការសង្គម មានភាពអង់អាចនិងការធ្វើសេចក្ដីសម្រេចនៅគ្រប់កម្រិតនិងគ្រប់វិស័យ ដោយស្មើគ្នាជាមួយបុរស និងក្មេងប្រុស ដើម្បីធានាបាននូវភាពម្ចាស់ការលើខ្លួនឯង និងមានសុខុមាលភាពពេញលេញក្នុងគ្រួសារ សហគមន៍ និងសង្គមជាតិ ។

## បេសកកម្ម

ក្រសួងកិច្ចការនារី មានបេសកកម្ម ក្នុងការដឹកនាំ ភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័ន និងដៃគូពាក់ព័ន្ធ ក្នុងដំណើរឆ្ពោះទៅសម្រេចសមភាពយេនឌ័រ និងលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី និងក្មេងស្រីគ្រប់រូបភាពនៅក្នុងសង្គម តាមរយៈ៖

- ការបញ្ជ្រាបយេនឌ័រទៅក្នុងដំណើរការតាក់តែង និងអនុវត្តច្បាប់ គោលនយោបាយ កម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រជាតិ និងគោលនយោបាយតាមវិស័យ។
- ការដឹកនាំកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូជាមួយក្រសួង-ស្ថាប័ន និងដៃគូពាក់ព័ន្ធ រួមទាំងដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល វិស័យឯកជននិងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំ អនុវត្ត និងពិនិត្យតាមដានការអនុវត្តកម្មវិធី ផែនការសកម្មភាព និងគោលនយោបាយជាក់លាក់ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ។
- ការពង្រឹងសមត្ថភាព និងប្រសិទ្ធភាពក្នុងការអនុវត្តមុខងាររបស់យន្តការ ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការជំរុញការបញ្ជ្រាបយេនឌ័រ និងលើកកម្ពស់ស្ថានភាពស្ត្រី ។
- ការជំរុញ និងលើកទឹកចិត្តក្នុងការអនុវត្តវិធានការជាក់លាក់ និងគំនិតផ្តួចផ្តើមនានា សំដៅលើកកម្ពស់សមធម៌យេនឌ័រ ការបង្កើនភាពអង់អាចដល់ស្ត្រី និងបរិយាបន្ននៅក្នុងរបៀបវារៈកំណើនសេដ្ឋកិច្ច កិច្ចគាំពារសង្គម និងអភិបាលកិច្ចល្អ ។
- ពង្រីកកម្មវិធីសិក្សាស្រាវជ្រាវអំពីផលប៉ះពាល់យេនឌ័រតាមវិស័យ និងក្រុមគោលដៅដែលឆ្លើយតបបរិយាបន្ន និងស្របតាមបរិបទថ្មីៗរបស់សង្គម ដើម្បីស្វែងរកលទ្ធភាពនិងវិធានការឆ្លើយតប។

# ផ្នែកទី ៣.

## គោលបំណង

ផែនការយុទ្ធសាស្ត្រ**នារីរតនៈទី៥** មានគោលបំណងចម្បងៗ ដូចខាងក្រោម៖

១. ពង្រឹងសមត្ថភាពរបស់ស្ថាប័ន និងយន្តការនៅថ្នាក់ជាតិនិងក្រោមជាតិ ក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងដំណើរការតាក់តែង និងអនុវត្តន៍ច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធីជាតិ និងតាមវិស័យនៅគ្រប់កម្រិត ប្រកបដោយសមធម៌ និងបរិយាបន្ន ។

២. ពង្រីកកម្មវិធីផ្លាស់ប្តូរឥរិយាបថនិងផ្នត់គំនិតសង្គម ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីនិងក្មេងស្រីគ្រប់រូបនៅក្នុងគ្រួសារ សហគមន៍និងសង្គម។

៣. ជំរុញការឆ្លើយតបយេនឌ័រទៅក្នុងក្របខណ្ឌគោលនយោបាយ ផែនការយុទ្ធសាស្ត្រនិងកម្មវិធីជាតិពាក់ព័ន្ធវិស័យសេដ្ឋកិច្ច និងអភិវឌ្ឍសហគ្រិនភាពនិងសក្តានុពលរបស់ស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ច ប្រកបដោយបរិយាបន្ន ។

៤. ពង្រឹង និងពង្រីកការឆ្លើយតបយេនឌ័រនៅក្នុងគោលនយោបាយនិងកម្មវិធីជាតិពាក់ព័ន្ធវិស័យអប់រំ និងយុវជន ជាពិសេសការអប់រំសម្រាប់ស្ត្រីនិងក្មេងស្រីនៅកម្រិតខ្ពស់ និងការអប់រំដែលស្របតាមតម្រូវការសង្គម ព្រមទាំងពង្រីកកម្មវិធីអប់រំស្តីពីការចិញ្ចឹមកូនតាមបែបវិជ្ជមានឆ្លើយតបយេនឌ័រ។

៥. ពង្រីកការឆ្លើយតបយេនឌ័រនៅក្នុងគោលនយោបាយ ផែនការយុទ្ធសាស្ត្រនិងកម្មវិធីពាក់ព័ន្ធសុខភាព ជាពិសេសលើកកម្ពស់សុខភាពស្ត្រីនិងក្មេងស្រីពាក់ព័ន្ធអាហារូបត្ថម្ភ សុខភាពបន្តពូជ និងសុខភាពផ្លូវភេទ។

៦. ដឹកនាំ និងសម្របសម្រួលក្នុងការអនុវត្ត និងតាមដានការអនុវត្តផែនការសកម្មភាពនិងយុទ្ធសាស្ត្រជាតិពាក់ព័ន្ធនឹងការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ។

៧. ជំរុញការចូលរួមរបស់ស្ត្រី នៅក្នុងថ្នាក់ធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិត និងការលើកកម្ពស់សមភាពយេនឌ័រក្នុងភាពជាអ្នកដឹកនាំនៅគ្រប់កម្រិត ។

៨. លើកកម្ពស់ភាពអង់អាចរបស់ស្ត្រី ក្នុងការបន្សាំនិងកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងការបញ្ជ្រាបយេនឌ័រនៅក្នុងគោលនយោបាយ ផែនការអភិវឌ្ឍ និងកម្មវិធីពាក់ព័ន្ធ។

៩. លើកកម្ពស់សមត្ថភាពក្រសួងកិច្ចការនារី និងអង្គភាពចំណុះ ការពង្រឹងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ បរិយាកាសមេត្រីភាព និងពង្រឹងប្រសិទ្ធភាពក្នុងការតាមតាននិងវាយតម្លៃការអនុវត្តការងារ ព្រមទាំងពង្រីកយន្តការគ្រប់គ្រងនិងផ្សព្វផ្សាយព័ត៌មានឆ្លើយតបយេនឌ័រនិងបរិយាបន្ន។

# ផ្នែកទី ៤.
# ក្របខណ្ឌយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ២០១៩-២០២៣ ផ្តោតលើកម្មវិធីបញ្ជ្រាបយេនឌ័រ ជាយុទ្ធសាស្ត្រស្នូលអន្តរវិស័យ និងមានយុទ្ធសាស្ត្រតាមវិស័យ ចំនួន៦៖ ១).**ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី** ២).ការលើកកម្ពស់ការអប់រំរបស់ស្ត្រីនិងក្មេងស្រី ៣).ការលើកកម្ពស់សុខភាពរបស់ស្ត្រីនិងក្មេងស្រី ៤).កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រីនិងក្មេងស្រី ៥).ស្ត្រីក្នុងវិស័យសាធារណៈ នយោបាយនិងភាពជាអ្នកដឹកនាំ និង៦).ការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធីប្រែប្រួលអាកាសធាតុ និងគាំទ្រដោយយុទ្ធសាស្ត្រពង្រឹងសមត្ថភាពនិងអភិវឌ្ឍស្ថាប័ន។




## យុទ្ធសាស្ត្រស្នូល. ក្របខណ្ឌបញ្ជ្រាបយេនឌ័រ

រាជរដ្ឋាភិបាលកម្ពុជា បន្តជំរុញការបញ្ជ្រាបយេនឌ័រនៅក្នុងគោលនយោបាយនិងផែនការអភិវឌ្ឍន៍គ្រប់ផ្នែក គ្រប់វិស័យ និងគ្រប់កម្រិត ។ ផ្អែកតាមមូលដ្ឋាននេះ ក្របខណ្ឌបញ្ជ្រាបយេនឌ័រ គឺជាយុទ្ធសាស្ត្រស្នូលអន្តរវិស័យរបស់**ផែនការយុទ្ធសាស្ត្រនារីរតៈទី៥** ដែលផ្តោតលើការបញ្ជ្រាបយេនឌ័រទៅក្នុងដំណើរការតាក់តែង អនុវត្ត និងតាមដានការអនុវត្តច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធី និងតាមវិស័យនៅគ្រប់កម្រិតប្រកបដោយសមធម៌និងបរិយាបន្ន និងលើកកម្ពស់ផ្លាស់ប្តូរឥរិយាបថ និងផ្នត់គំនិតសង្គម

ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី នៅក្នុងគ្រួសារ សហគមន៍ និងសង្គម។

ការបញ្ជ្រាបយេនឌ័រ ត្រូវយកចិត្តទុកដាក់ និងឆ្លើយតបនៅក្នុងក្របខណ្ឌ និងវិស័យជាយុទ្ធសាស្ត្ររបស់**នារីរតនៈទី៥** រួមទាំងវិស័យសេដ្ឋកិច្ច អប់រំ សុខភាព កិច្ចការពារផ្លូវច្បាប់ និងអភិបាលកិច្ច ព្រមទាំងការពង្រឹងសមត្ថភាព និងប្រសិទ្ធភាពការអនុវត្តការងាររបស់ក្រសួងកិច្ចការនារី ក្នុងការដឹកនាំភាពជាដៃគូ និងសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន និងដៃគូពាក់ព័ន្ធ។

ក្នុងបរិការណ៍នេះ **នារីរតនៈទី៥** ផ្ដោតលើអាទិភាព ដូចខាងក្រោម៖

១. ពង្រីកកម្មវិធីសិក្សាស្រាវជ្រាវនិងប៉ាន់ប្រមាណស្ថានភាពយេនឌ័រ ព្រមទាំងការរៀបចំនិងអនុវត្តគោលនយោបាយជាតិស្ដីពីសមភាពយេនឌ័រ និងកម្មវិធីតាមវិស័យ។

២. ជំរុញ និងសម្របសម្រួលការបញ្ជ្រាបយេនឌ័រ នៅក្នុងក្របខណ្ឌផែនការយុទ្ធសាស្ត្រតាមវិស័យ និងកម្មវិធីជាតិ រួមទាំងការងារកំណែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីវិមជ្ឈការនិងវិសហមជ្ឈការ និងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

៣. ពង្រឹងសមត្ថភាពរបស់យន្តការបញ្ជ្រាបយេនឌ័រនៅគ្រប់កម្រិត រួមទាំងការគាំទ្រដល់ក្រុមការងារបញ្ជ្រាបយេនឌ័រតាមក្រសួង-ស្ថាប័ន ក្រុមការងារបច្ចេកទេសយេនឌ័រ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ និងដៃគូពាក់ព័ន្ធ។

៤. ពង្រឹងប្រព័ន្ធ និងយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការបញ្ជ្រាបយេនឌ័រ និងបង្កើនភាពអង់អាចរបស់ស្ត្រីតាមវិស័យ។

៥. បង្កើនការយល់ដឹងជាសាធារណៈ និងការគាំទ្រលើការលើកកម្ពស់សមភាពយេនឌ័រ រួមទាំងការអនុវត្តកម្មវិធីការផ្លាស់ប្ដូរឥរិយាបថ និងផ្នត់គំនិតអវិជ្ជមានរបស់សង្គមដែលរើសអើងលើស្ត្រី និងក្មេងស្រីគ្រប់រូបភាព។

៦. ចងក្រងមេរៀនបទពិសោធន៍ និងឧត្តមានុវត្តន៍នានាលើការអនុវត្តការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ កម្មវិធី និងតាមវិស័យ ព្រមទាំងចែករំលែកនិងផ្លាស់ប្ដូរបទពិសោធន៍ ។

## យុទ្ធសាស្ត្រ ទី១. ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី

រាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី ជាយុទ្ធសាស្ត្រអាទិភាពនិងអភិក្រមមូលដ្ឋានដ៏សំខាន់សម្រាប់ឆ្នាំ២០១៩-២០២៣។ **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤** របស់រាជរដ្ឋាភិបាលកម្ពុជា បានណែនាំឱ្យបន្តលើកកម្ពស់សហគ្រិនភាពរបស់ស្ត្រី តាមរយៈការពង្រីកកម្មវិធីអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលជំរុញការអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំ និងគោលនយោបាយជាតិស្តីពីបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ព្រមទាំងការជំរុញការអនុវត្តមូលនិធិជាតិសម្រាប់ការអភិវឌ្ឍជំនាញ និងការបង្កើនគំនិតសហគ្រិនភាពក្នុងកម្មវិធីអប់រំ។

ម្យ៉ាងវិញទៀត ក្នុងការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងការឆ្លើយតបបដិវត្តន៍ឧស្សាហកម្មទី៤ រាជរដ្ឋាភិបាល នឹងជំរុញការអភិវឌ្ឍសហគ្រិនភាព និងរៀបចំប្រព័ន្ធអេកូឡូស៊ីឌីជីថល ដែលជាបរិយាកាសអំណោយផលដល់ការបង្កើតធុរកិច្ចថ្មីៗ ការជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងធុរកិច្ច និងការបង្កើតយន្តការប្រតិបត្តិការសហគ្រិនភាពក្នុងក្របខណ្ឌរាជរដ្ឋាភិបាល និងជាមួយវិស័យឯកជន។ រាជរដ្ឋាភិបាលនឹងដាក់ចេញការអនុវត្តគោលនយោបាយគាំទ្រសហគ្រាសធុនតូចនិងមធ្យម បង្កើតមូលនិធិសហគ្រិនភាព និងមជ្ឈមណ្ឌលអភិវឌ្ឍសហគ្រិន រួមទាំងជំរុញគុណភាព និងផលិតផលនៃសហគ្រាសធុនតូចនិងមធ្យម ។

របៀបវារៈសំខាន់ៗទាំងនេះ ជាកាលានុវត្តភាពនិងសក្តានុពលដើម្បីលើកកម្ពស់សមភាពយេនឌ័រនៅក្នុងការទទួលបានការងារ ការអភិវឌ្ឍធនធានមនុស្ស និងការធ្វើពិពិធកម្មសេដ្ឋកិច្ច រួមទាំងការលើកកម្ពស់សហគ្រិនភាពរបស់ស្ត្រី ឱ្យស្របតាមយុគសម័យឌីជីថល។ ក្រសួងកិច្ចការនារី នឹងពង្រឹងមុខងារក្នុងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញការឆ្លើយតបយេនឌ័រទៅក្នុងក្របខណ្ឌគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីជាតិពាក់ព័ន្ធវិស័យសេដ្ឋកិច្ច និងអភិវឌ្ឍសហគ្រិនភាព និងសក្តានុពលរបស់ស្ត្រី នៅក្នុងវិស័យសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន និងស្របតាមស្ថានភាពសង្គម។

ក្នុងបរិការណ៍នេះ **នារីរតនៈទី៥** ផ្តោតលើអាទិភាពដូចខាងក្រោម៖

១. ពង្រឹង និងពង្រីកបរិយាកាសការគាំទ្រផ្នែកគោលនយោបាយ និងការវិនិយោគប្រកបដោយបរិយាបន្ន ក្នុងការគាំទ្រការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី។

២. ពង្រីកកាលានុវត្តភាព និងបរិយាកាសសម្រាប់ការអភិវឌ្ឍសហគ្រិនភាព និងធុរកិច្ចរបស់ស្ត្រីប្រកបដោយនវានុវត្តន៍ និងបរិយាបន្ន។

៣. ពង្រីកបរិយាកាសសម្រាប់ស្ត្រី ក្នុងការទទួលបានជំនាញវិជ្ជាជីវៈ ជាពិសេសស្របតាមតម្រូវការសេដ្ឋកិច្ចឌីជីថល និងប្រកបដោយបរិយាបន្ន។

៤. លើកកម្ពស់ការយកចិត្តទុកដាក់និងគាំទ្រដល់ស្ត្រី ដែលកំពុងមានសកម្មភាពក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ។

៥. លើកកម្ពស់កម្មវិធីតុល្យភាពជីវិត គ្រួសារនិងការងារ បរិយាកាសមេត្រីភាព និងសុវត្ថិភាពសម្រាប់ស្ត្រីនៅក្នុងសកម្មភាពសេដ្ឋកិច្ច។

៦. ពង្រីកកាលានុវត្តភាពសេដ្ឋកិច្ចនៅតាមសហគមន៍ រួមទាំងការទទួលបានសេវាហិរញ្ញវត្ថុប្រកបដោយបរិយាបន្នសម្រាប់ស្ត្រី ជាពិសេសស្ត្រីក្រីក្រ ស្ត្រីពិការ ស្ត្រីជាជនជាតិភាគតិច ស្ត្រីជនជាតិដើមភាគតិច ស្ត្រីជាមេគ្រួសារ។

## យុទ្ធសាស្ត្រទី២. ការលើកកម្ពស់ការអប់រំរបស់ស្ត្រី និងក្មេងស្រី

ការទទួលបានការអប់រំពេញលេញរបស់ស្ត្រីនិងក្មេងស្រី ជាលក្ខខណ្ឌដ៏ចាំបាច់ក្នុងការជំរុញឱ្យសម្រេចបានសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីនិងក្មេងស្រីនៅគ្រប់វិស័យ ។ ស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជានៅឆ្នាំ២០៥០ តម្រូវឱ្យមានការពង្រីកលទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាពសម្រាប់ស្ត្រីនិងក្មេងស្រី និងស្របតាមតម្រូវការរបស់សង្គម។ ទន្ទឹមនឹងនេះ គម្លាតយេនឌ័រក្នុងវិស័យអប់រំ ពិសេសនៅកម្រិតឧត្តមសិក្សា និងការចាប់យកជំនាញតាមតួនាទីយេនឌ័រនៅបន្តកើតមាន ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀត។ ជាមួយគ្នានេះ ការចូលរួមរបស់ក្រុមមនុស្សវ័យក្មេង ជាកាលានុវត្តភាពចាំបាច់ក្នុងការផ្លាស់ប្តូរ និងបណ្តុះនូវផ្នត់គំនិតជាវិជ្ជមានសម្រាប់ដំណើរឆ្ពោះទៅមុខដើម្បីសមភាពយេនឌ័រ។

នៅក្នុងបរិការណ៍នេះ **ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥** នឹងផ្តោតលើការពង្រឹងនិងពង្រីកការឆ្លើយតបយេនឌ័រនៅក្នុងគោលនយោបាយ និងកម្មវិធីជាតិពាក់ព័ន្ធវិស័យអប់រំ និងយុវជន ជាពិសេសការអប់រំរបស់ស្ត្រីនិងក្មេងស្រីនៅកម្រិតខ្ពស់ និងការអប់រំដែលស្របតាមតម្រូវការសង្គម ព្រមទាំងការពង្រីកកម្មវិធីអប់រំស្តីពីការចិញ្ចឹមកូនតាមបែបវិជ្ជមានដែលឆ្លើយតបយេនឌ័រ។

**នារីរតនៈទី៥** ផ្តោតលើអាទិភាពដូចខាងក្រោម៖

១. ពង្រឹងភាពជាដៃគូជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងអប់រំ យុវជននិងកីឡា ក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងក្របខណ្ឌគោលនយោបាយពាក់ព័ន្ធវិស័យអប់រំ យុវជន និងជំរុញការទទួលបានការអប់រំរបស់ស្ត្រីនិងក្មេងស្រីនៅកម្រិតខ្ពស់ និងការអប់រំផ្នែកវិទ្យាសាស្ត្របច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យា (STEAM) ។

២. ពង្រឹងភាពជាដៃគូជាមួយគ្រឹះស្ថានសិក្សា និងដៃគូពាក់ព័ន្ធ ក្នុងការលើកកម្ពស់សមភាពយេនឌ័រក្នុងចំណោមក្រុមមនុស្សវ័យក្មេង ។

៣. លើកកម្ពស់កម្មវិធីទារកដ្ឋាននៅតាមគ្រឹះស្ថានសាធារណៈនិងកន្លែងធ្វើការ និងពង្រីកកម្មវិធីមត្តេយ្យសិក្សាសហគមន៍នៅតាមមូលដ្ឋាន ព្រមទាំងលើកកម្ពស់កម្មវិធីអប់រំមាតាបិតា ការយល់ដឹងពីសារសំខាន់នៃការថែទាំ និងការសិក្សាសម្រាប់កុមារតូចនិងការចិញ្ចឹមកូនបែបវិជ្ជមាន។

៤. ពង្រឹង និងពង្រីកការអនុវត្តកម្មវិធី និងយុទ្ធសាស្ត្រស្ដីពីការចិញ្ចឹមកូនបែបវិជ្ជមានដែលឆ្លើយតបនឹងយេនឌ័រ។

៥. រៀបចំ និងអនុវត្តកម្មវិធីអប់រំសុខុមាលភាពសង្គម ជាពិសេសសម្រាប់ស្ត្រីនិងគ្រួសារ សំដៅលើកកម្ពស់ការអនុវត្តសិទ្ធិរបស់ស្ត្រី និងក្មេងស្រីដោយពេញលេញ ។

៦. ពង្រីកកម្មវិធីសិក្សាស្រាវជ្រាវ អំពីស្ថានភាពនិងបញ្ហាថ្មីៗពាក់ព័ន្ធស្ថានភាពស្ត្រីនិងយេនឌ័រនៅក្នុងវិស័យអប់រំ យុវជន និងកីឡា ។

## យុទ្ធសាស្ត្រទី៣. ការលើកកម្ពស់សុខភាពរបស់ស្ត្រី និងក្មេងស្រី

រាជរដ្ឋាភិបាល បន្តអនុវត្តនិងធ្វើបច្ចុប្បន្នភាព **ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០១៦-២០២០** ដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាពនិងសមធម៌នៃសេវាសុខភាព តាមរយៈប្រព័ន្ធសុខាភិបាល និងបង្កើនការបង្ការហានិភ័យហិរញ្ញវត្ថុ។ ការសម្រេចឱ្យបានលទ្ធផលសុខភាពដោយសមធម៌ នៅក្នុងចំណោមប្រជាពលរដ្ឋដែលមានស្ថានភាពសេដ្ឋកិច្ច និងសង្គមខុសៗគ្នារវាងប្រជាពលរដ្ឋរស់នៅទីប្រជុំជននិងតំបន់ជនបទ នៅតែជាសម្ពាធមកលើប្រព័ន្ធសុខាភិបាល ក្នុងការឈានទៅសម្រេចបានចក្ខុវិស័យរយៈពេលវែង *«ប្រជាពលរដ្ឋកម្ពុជាទាំងអស់មានសុខភាពនិងសុខមាលភាពកាន់តែល្អប្រសើរ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមប្រកបដោយចីរភាព»*។ ក្នុងខ្លឹមសារនេះ បញ្ហាវិសមភាពយេនឌ័រនៅក្នុងវិស័យសុខាភិបាល នៅតែជាឧបសគ្គសម្រាប់ស្ត្រីនិងក្មេងស្រី ក្នុងការទទួលបានសេវាសុខភាពដែលមានគុណភាពនិងសមធម៌ ដែលចំណុចនេះបណ្ដាលមកពីកត្តាមួយចំនួន ដូចជាកម្រិតនៃការអប់រំ ខ្វះការទទួលបានព័ត៌មាន ខ្វះខាតផ្នែកសេដ្ឋកិច្ច បន្ទុកការងារផ្ទះសម្បែង និងការថែទាំកូននិងចាស់ជរាជាដើម។

ក្រសួងកិច្ចការនារី នឹងសម្របសម្រួលជាមួយដៃគូពាក់ព័ន្ធ ពង្រីកកម្មវិធីវិភាគគម្លាតយេនឌ័រ និងការជំរុញការបញ្ជ្រាបយេនឌ័រក្នុងដំណើរការរៀបចំ និងអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីពាក់ព័ន្ធសុខភាព ជាពិសេសអាហារូបត្ថម្ភ សុខភាពបន្តពូជ និងសុខភាពផ្លូវភេទរបស់ស្ត្រីនិងក្មេងស្រី និងបន្តដើរតួនាទីលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិទទួលបាន និងប្រើប្រាស់**មូលនិធិសមធម៌** រួមជាមួយគម្រោងគាំពារសុខភាពសង្គមផ្សេងៗ ដូចជា**បេឡាជាតិរបបសន្តិសុខសង្គម** (ប.ស.ស) ការទទួលបានសេវាធានារ៉ាប់រងសុខភាពដល់ស្ត្រីនិងក្មេងស្រី ព្រមទាំងជំរុញឱ្យស្ត្រីនិងក្មេងស្រីទទួលបានសេវាប្រកបដោយគុណភាព សមធម៌និងបរិយាបន្ន។ កិច្ចការនេះ មានគោលដៅចូលរួមចំណែកកាត់បន្ថយអត្រាស្លាប់របស់មាតា និងទារក

អត្រាស្លាប់នៃជំងឺឆ្លង ជំងឺមិនឆ្លង និងស្លាប់ដែលបណ្តាលមកពីផលប៉ះពាល់នៃការប្រព្រឹត្តនានា ដូចជា អំពើហិង្សាទាក់ទងនឹងយេនឌ័រ ការប្រើប្រាស់គ្រឿងញៀន សារធាតុញៀន គ្រឿងស្រវឹង និងគ្រោះថ្នាក់ចរាចរណ៍ជាដើម។

ក្នុងមូលដ្ឋាននេះ **នារីរតនៈទី៥** ផ្តោតលើអាទិភាពខាងក្រោម៖

១. ពង្រឹង និងពង្រីកការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពវិស័យសុខាភិបាលនិងកម្មវិធីនានា រួមមានកម្មវិធីសុខភាពបន្តពូជ សុខភាពមាតា-ទារក សុខភាពផ្លូវភេទ សុខភាពផ្លូវចិត្ត សុខភាពភ្នែក អាហារូបត្ថម្ភ សន្តិសុខស្បៀង កម្មវិធីប្រយុទ្ធនឹងជំងឺឆ្លង និងជំងឺមិនឆ្លង ។

២. បង្កើនភាពអង់អាចដល់ស្ត្រីនិងក្មេងស្រី ក្នុងការទទួលបានសេវាសុខភាពប្រកបដោយបរិយាបន្នមានគុណភាព សុវត្ថិភាពនិងប្រសិទ្ធភាព ស្របតាមមូលដ្ឋានសុខាភិបាលសាធារណៈ។

៣. បន្តអភិវឌ្ឍសមត្ថភាពមន្ត្រី និងអ្នកពាក់ព័ន្ធនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ឱ្យបានទូលំទូលាយអំពីការវិភាគយេនឌ័រនៅក្នុងផ្នែកសុខភាព អាហារូបត្ថម្ភ និងសន្តិសុខស្បៀង ។

៤. លើកកម្ពស់សមភាពយេនឌ័រនិងបង្កើនភាពអង់អាចដល់ស្ត្រី នៅក្នុងដំណើរការអនុវត្តក្របខណ្ឌកិច្ចគាំពារសង្គម ។

៥. ពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលការងារបានអនុវត្ត ផ្អែកលើផែនការយុទ្ធសាស្ត្រ៥ឆ្នាំរបស់ក្រសួង និងរៀបចំប្រមូលទិន្នន័យថ្មីៗស្តីពីយេនឌ័រនិងសុខភាព (សុខភាពបន្តពូជ សុខភាពផ្លូវភេទ ជំងឺឆ្លង និងជំងឺមិនឆ្លង) អាហារូបត្ថម្ភ សន្តិសុខស្បៀង។

## យុទ្ធសាស្ត្រទី៤. កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រីនិងក្មេងស្រី

កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រីនិងក្មេងស្រី មានគោលបំណងលើកកម្ពស់ការពារសិទ្ធិនិងលុបបំបាត់រាល់ទម្រង់នៃអំពើហិង្សាលើស្ត្រីនិងក្មេងស្រី ជាពិសេសស្ត្រីនិងក្មេងស្រីដែលស្ថិតក្នុងក្រុមជនងាយរងគ្រោះ[1] ព្រមទាំងបង្កើនការផ្តល់សេវាដល់ស្ត្រីនិងក្មេងស្រីរងគ្រោះ ដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រឱ្យកាន់តែមានប្រសិទ្ធភាព គុណភាព បរិយាបន្ន និងទាន់ពេលវេលា។ ក្រសួងកិច្ចការនារី បន្តដឹកនាំ និងសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយ និងផ្នែកឯកជន ក្នុងការតាក់តែងនិងអនុវត្ត**ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទី៣ ២០១៩-២០២៣**។

[1] ស្ត្រីនិងក្មេងស្រីដែលស្ថិតក្នុងក្រុមងាយរងគ្រោះ រួមមានស្ត្រីដែលមានពិការភាព ផ្ទុកមេរោគអេដស៍ ពលករទេសន្តរប្រវេសន៍ អ្នកធ្វើការតាមផ្ទះ អ្នកដែលបំរើការងារនៅកន្លែងកំសាន្ត ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា ជនជាតិដើមភាគតិច ស្ត្រីស្ថិតនៅក្នុងក្រុមសាសនាដែលមានអ្នកគោរពប្រតិបត្តិភាគតិច ស្ត្រីនៅក្នុងពន្ធនាគារ ស្ត្រីដែលប្រើប្រាស់គ្រឿងញៀន ឬដៃគូរបស់ពួកគេប្រើប្រាស់គ្រឿងញៀន និងអាចមានក្រុមងាយរងគ្រោះដទៃផ្សេងទៀត។

ការទប់ស្កាត់និងឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមទាំងការបំពារបំពាននិងការកេងប្រវ័ញ្ចផ្លូវភេទ អំពើជួញដូរមនុស្ស ជាពិសេសលើស្ត្រី និងកុមារ ជាកិច្ចការដ៏ចាំបាច់សំដៅលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីនិងក្មេងស្រី ដើម្បីធានាការលើកកម្ពស់ និងការពារសិទ្ធិរបស់ពួកគេ ។

ក្នុងបរិការណ៍នេះ **នារីរតនៈទី៥** ផ្តោតលើអាទិភាពដូចខាងក្រោម៖

១. ជំរុញការបញ្ជ្រាបយេនឌ័រទៅក្នុងដំណើរការតាក់តែង និងអនុវត្តច្បាប់ និងកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។

២. សម្របសម្រួល និងជំរុញការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ២០១៩-២០២៣ តាមរយៈការបង្កើតផែនការប្រតិបត្តិប្រចាំឆ្នាំ និងការពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តមុខងារក្រុមការងារបច្ចេកទេសយេនឌ័រ ស្តីពីការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ។

៣. អនុវត្តកម្មវិធី និងយុទ្ធនាការបង្ការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី។

៤. រៀបចំ និងអនុវត្តកិច្ចការពារផ្លូវច្បាប់ និងសេវាកម្មពហុវិស័យជួយជនរងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

៥. ពិនិត្យនិងជំរុញការអនុវត្តច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងទប់ស្កាត់រាល់ទម្រង់អំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងក្មេងស្រី។

៦. ត្រួតពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ២០១៩-២០២៣។

៧. សម្របសម្រួល និងគាំទ្រការអនុវត្តផែនការសកម្មភាពថ្នាក់ជាតិ តំបន់ និងអនុតំបន់ពាក់ព័ន្ធការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ អំពើធ្វើអាជីវកម្មផ្លូវភេទ និងការកេងប្រវ័ញ្ចនានា។

៨. ចូលរួមគាំទ្រការអនុវត្ត និងធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពស្តីពីការទប់ស្កាត់និងឆ្លើយតបអំពើហិង្សាលើកុមារ ឆ្នាំ២០១៧-២០២១។

៩. សិក្សាស្រាវជ្រាវអំពីស្ថានភាព និងបញ្ហាថ្មីៗពាក់ព័ន្ធអំពើហិង្សាគ្រប់រូបភាពពាក់ព័ន្ធនឹងយេនឌ័រស្របតាមការវិវត្តន៍ និងស្ថានភាពថ្មីៗរបស់សង្គម ។

## យុទ្ធសាស្ត្រទី៥. ស្ត្រីក្នុងវិស័យសាធារណៈ នយោបាយ និងភាពជាអ្នកដឹកនាំ

នៅក្នុង**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤** បានកំណត់ថារាជរដ្ឋាភិបាលនឹងបន្តលើកកម្ពស់តួនាទីស្ត្រី តាមរយៈការបង្កើនសមាមាត្រ និងការពង្រឹងសមត្ថភាពស្ត្រីក្នុងជួរថ្នាក់ដឹកនាំ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទាំងកម្រិតនយោបាយ និងកម្រិតជំនាញ។ អាទិភាពទាំងនេះ អាចសម្រេចបានតាមរយៈការដាក់ចេញជាយុទ្ធសាស្ត្រនិងចូលរួមដោយសកម្ម រួមទាំងឆន្ទៈនិងការប្តេជ្ញានៅក្នុងដំណើរការកំណែទម្រង់របស់រាជរដ្ឋាភិបាលរួមមាន **កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ** និង**កម្មវិធីវិមជ្ឈការនិងវិសហមជ្ឈការ** ព្រមទាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណបក្សនយោបាយ។

ក្រសួងកិច្ចការនារី សម្របសម្រួលក្នុងការរៀបចំ និងអនុវត្ត**ក្របខណ្ឌកម្មវិធីស្តីពីការលើកកម្ពស់ស្ត្រីក្នុងវិស័យសាធារណៈនិងនយោបាយ** តាមរយៈក្រុមការងារបច្ចេកទេសយេនឌ័រ ស្តីពីស្ត្រីក្នុងភាពជាអ្នកដឹកនាំនិងអភិបាលកិច្ច (TWGG-WLG)។

ក្នុងបរិការណ៍នេះ **នារីរតនៈទី៥** ផ្តោតលើអាទិភាពដូចខាងក្រោម ៖

១. ពង្រីកបរិយាកាសគាំទ្រផ្នែកគោលនយោបាយ ព្រមទាំងបរិយាកាសមេត្រីភាពសម្រាប់ស្ត្រីនៅកន្លែងធ្វើការ និងការគាំទ្រពីដៃគូពាក់ព័ន្ធ ក្នុងការលើកកម្ពស់ការចូលរួមរបស់ស្ត្រីជាថ្នាក់ដឹកនាំ និងតួនាទីបច្ចេកទេសនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ក្នុងវិស័យនយោបាយ វិស័យសាធារណៈ និងនៅតាមសហគមន៍។

២. ពង្រឹងបណ្តាញ និងអភិវឌ្ឍភាពជាអ្នកដឹកនាំរបស់ស្ត្រី ក្នុងវិស័យសាធារណៈនិងនយោបាយនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

៣. លើកកម្ពស់ការយល់ដឹង និងការផ្លាស់ប្តូរឥរិយាបថរបស់សាធារណជន ទាំងបុរស និងស្ត្រីជាថ្នាក់ដឹកនាំ រួមទាំងយុវវ័យ ដៃគូពាក់ព័ន្ធ អំពីការលើកកម្ពស់សមភាពនិងសមធម៌យេនឌ័រ ក្នុងគោលបំណងលើកកម្ពស់ការចូលរួមរបស់ស្ត្រីនៅក្នុងកិច្ចអភិវឌ្ឍភាពជាអ្នកដឹកនាំ អភិបាលកិច្ច និងអភិវឌ្ឍសហគមន៍។

៤. លើកកម្ពស់ការចូលរួមរបស់យុវជននិងស្ត្រីវ័យក្មេង ក្នុងភាពជាអ្នកដឹកនាំនិងអភិបាលកិច្ចដែលឆ្លើយតបយេនឌ័រ។

## យុទ្ធសាស្ត្រទី៦. ការបញ្ជ្រាបយេនឌ័រ ក្នុងកម្មវិធីប្រែប្រួលអាកាសធាតុ

រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងរបៀបវារៈឆ្លើយតបការប្រែប្រួលអាកាសធាតុ ជាពិសេសតាមរយៈការដាក់បញ្ចូលជាយុទ្ធសាស្ត្រអាទិភាពនៃ**ផែនការយុទ្ធសាស្ត្រនារីរតនៈ** និងការដាក់ចេញនូវវិធានការពង្រឹងភាពអង់អាចដល់ស្ត្រី ក្នុងការបន្សាំនិងកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ និងផែនការអភិវឌ្ឍពាក់ព័ន្ធនានា។

ក្រសួងកិច្ចការនារី នឹងពង្រឹងសមត្ថភាពបច្ចេកទេសនិងប្រសិទ្ធភាព ក្នុងការចូលរួមនៅក្នុងរបៀបវារៈរបស់កម្មវិធីអភិវឌ្ឍន៍ដោយចីរភាព និងជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ តាមរយៈបន្តអនុវត្ត**ផែនការយុទ្ធសាស្ត្រយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ២០១៤-២០២៣ ផែនការមេស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ២០១៨-២០៣០** និង**ផែនការសកម្មភាពយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ២០១៩-២០២៣**។

ក្នុងមូលដ្ឋាននេះ **នារីរតនៈទី៥** ផ្តោតអាទិភាពដូចខាងក្រោម៖

១. ពង្រឹងសមត្ថភាពបច្ចេកទេស និងការគាំទ្រពីថ្នាក់ដឹកនាំនិងមន្ត្រីពាក់ព័ន្ធ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ការកសាងសមត្ថភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ។

២. បន្តបញ្ជ្រាបយេនឌ័រក្នុងដំណើរការតាក់តែង និងអនុវត្តគោលនយោបាយ កម្មវិធី និងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ រួមទាំងតំបន់ជុំវិញទន្លេសាប និងទន្លេមេគង្គមានភាពប្រសើរឡើង។

៣. គាំទ្រ និងបង្កើតគំនិតផ្តួចផ្តើមនានា ក្នុងការឆ្លើយតបតម្រូវការជាក់លាក់របស់ស្ត្រី និងក្រុមស្ត្រីក្មេងស្រីដែលងាយរងគ្រោះ ក្នុងកម្មវិធីប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ។

៤. រៀបចំប្រព័ន្ធគ្រប់គ្រងនិងចែករំលែកព័ត៌មាន និងការសិក្សាស្រាវជ្រាវថ្មីៗ ស្តីពីផលប៉ះពាល់យេនឌ័រ ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ប្រកបដោយបរិយាបន្ន។

## យុទ្ធសាស្ត្រគាំទ្រស្ថាប័ន. ការពង្រឹងសមត្ថភាព និងអភិវឌ្ឍស្ថាប័ន

នៅក្នុងនីតិកាលទី៦នៃរដ្ឋសភា រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើការកែទម្រង់ និងការលើកកម្ពស់សមត្ថភាពរបស់ក្រសួង-ស្ថាប័ន ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ និងពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តការងារ។

ភាពចាំបាច់ និងកត្តាជោគជ័យនៃការអនុវត្ត**ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥** អាស្រ័យលើភាពខ្លាំងរឹងមាំ និងប្រសិទ្ធភាពការងាររបស់ក្រសួងកិច្ចការនារីនិងមន្ទីរកិច្ចការនារី ។ ក្នុងបរិការណ៍នេះ កម្មវិធីអភិវឌ្ឍសមត្ថភាពស្ថាប័ន ត្រូវធ្វើឡើងដោយឆ្លុះបញ្ចាំងនិងឆ្លើយតបនឹងការប្រែប្រួលយ៉ាងឆាប់រហ័សនៃការវិវត្តន៍ និងបរិបទថ្មីៗរបស់សកលលោក និងនៅក្នុងប្រទេស ក៏ដូចជាការឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្ម ទី៤ និងការធ្វើឌីជីថលភាវូបនីយកម្ម។ ជាមួយគ្នានេះ **នារីរតនៈទី៥** នឹងបន្តលើកកម្ពស់សមត្ថភាពរបស់ក្រសួងកិច្ចការនារី និងអង្គភាពចំណុះ ក្នុងការពង្រឹងភាពស្អាតស្អំផ្នែករដ្ឋបាលសាធារណៈ និងពង្រឹងប្រសិទ្ធភាព ក្នុងការពិនិត្យតាមដាននិងវាយតម្លៃលើការអនុវត្តការងារ ព្រមទាំងពង្រីកយន្តការគ្រប់គ្រង និងផ្សព្វផ្សាយព័ត៌មានឱ្យឆ្លើយតបយេនឌ័រ ប្រកបដោយបរិយាបន្ន។

ជាមួយគ្នានេះ ការលើកកម្ពស់ការឆ្លើយតបបរិយាបន្ន ដល់ស្ត្រីនិងក្មេងស្រីដែលស្ថិតនៅក្នុងក្រុមដែលមានពិការភាព ក្រុមបាត់បង់ឱកាស និងក្រុមងាយរងគ្រោះនៅក្នុងសង្គម ជាកិច្ចការអន្តរវិស័យរបស់ក្រសួងកិច្ចការនារី ដែលជំរុញឱ្យបញ្ជ្រាបនិងមានវិធានការជាក់លាក់នៅតាមអង្គភាព និងយុទ្ធសាស្ត្រនីមួយៗ ព្រមទាំងលើកទឹកចិត្ត គិតគូរនិងជំរុញឱ្យមាន វិធានការប្រកបដោយសមធម៌នៅក្នុងការអនុវត្តសកម្មភាពប្រចាំថ្ងៃរបស់ក្រសួង ។

ក្នុងបរិការណ៍ទាំងនេះ **នារីរតនៈទី៥** នឹងផ្តោតអាទិភាពលើ៖

១. ធ្វើវិចារណកម្មមុខងារនិងភារកិច្ច និងការអនុវត្តការងារផ្អែកលើលទ្ធផល។

២. អភិវឌ្ឍធនធានមនុស្ស និងនវានុវត្តមុខងាររបស់ស្ថាប័ន និងអង្គភាពចំណុះ។

៣. ពង្រីកការអនុវត្តកម្មវិធីតុល្យភាពជីវិត គ្រួសារនិងការងារ និងបរិយាកាសមេត្រីភាពឆ្លើយតបនឹងយេនឌ័រនៅកន្លែងការងារ ក្នុងស្ថាប័ន និងអង្គភាពចំណុះ។

៤. ពង្រឹងប្រព័ន្ធរៀបចំផែនការ ស្ថិតិ តាមដាននិងវាយតម្លៃផ្អែកលើលទ្ធផលការងារ ដោយមានការបែងចែកតាមភេទ ស្ថានភាពសេដ្ឋកិច្ច និងសង្គម។

៥. ពង្រឹងយន្តការសម្របសម្រួល ប្រាស្រ័យទាក់ទង និងគ្រប់គ្រងព័ត៌មានផ្សព្វផ្សាយតាមប្រព័ន្ធទំនើប និងស្របតាមបរិបទសង្គម ។

៦. ពង្រឹងយន្តការក្នុងការពង្រីកកិច្ចសហប្រតិបត្តិការថ្នាក់ជាតិ ថ្នាក់តំបន់និងសកល ដើម្បីលើកកម្ពស់និងកិច្ចការពារសិទ្ធិស្ត្រីនិងកុមារ។

៧. ពង្រឹងសមត្ថភាព និងប្រសិទ្ធភាពស្ថាប័ន ឆ្លើយតបប្រកបដោយបរិយាបន្ន និងសមធម៌ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី៥។

៨. អនុវត្តកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាល ក្នុងការពង្រឹងប្រសិទ្ធភាពការងារស្ថាប័ន។

# ផ្នែកទី៥. សកម្មភាពការងារ

## យុទ្ធសាស្ត្រស្នូល៖ គ្រប់ខណ្ឌបង្ក្រាបយេនឌ័រ

**គោលបំណង៖** ពង្រឹងសមត្ថភាពយន្តការនៅថ្នាក់ជាតិនិងក្រោមជាតិ ក្នុងការបញ្ជ្រាបយេនឌ័រនៅក្នុងដំណើរការតាក់តែងនិងអនុវត្តច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធីជាតិ និងតាមវិស័យនៅគ្រប់កម្រិត ប្រកបដោយសមធម៌និងបរិយាបន្ន និងពង្រីកកម្មវិធីផ្លាស់ប្តូរឥរិយាបថរបស់សង្គម ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីនិងក្មេងស្រីនៅក្នុងគ្រួសារ សហគមន៍ និងសង្គម។

| យុទ្ធសាស្ត្រ | សូចនាករ | សកម្មភាពគន្លឹះ | ដៃគូពាក់ព័ន្ធ | ពេលវេលា (២០១៩-២០២៣) | | | | | ធនធាន | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១៩ | ២០ | ២១ | ២២ | ២៣ | ជាតិ | ដៃគូ |
| ១.ពង្រីកកម្មវិធីសិក្សាស្រាវជ្រាវនិងប៉ាន់ប្រមាណស្ថានភាពយេនឌ័រ ព្រមទាំងការរៀបចំ និងអនុវត្តគោលនយោបាយជាតិ ស្តីពីសមភាពយេនឌ័រ និងកម្មវិធីតាមវិស័យ | ចំនួនឯកសារស្តីពីការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា ត្រូវបានចងក្រង និងបោះពុម្ពផ្សព្វផ្សាយ | រៀបចំការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា (ជ្រើសរើសទីប្រឹក្សាបច្ចេកទេស កិច្ចប្រជុំពិភាក្សាផ្ទៃក្នុង កិច្ចប្រជុំជាមួយដៃគូពាក់ព័ន្ធ កែសម្រួលបញ្ចប់ និងបោះពុម្ព) | ក្រសួងកិច្ចការនារី<br>ក្រសួង-ស្ថាប័ន<br>ដៃគូអភិវឌ្ឍ<br>សង្គមស៊ីវិល<br>វិស័យឯកជន | ✓ | ✓ | ✓ | | | ✓ | ✓ |
| | គោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ បានអនុម័ត និងបោះពុម្ពផ្សព្វផ្សាយ | រៀបចំ និងតាក់តែងគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ (កិច្ចប្រជុំពិភាក្សាផ្ទៃក្នុង កិច្ចប្រជុំជាមួយដៃគូពាក់ព័ន្ធ កែសម្រួល និងបោះពុម្ព) | ក្រសួងកិច្ចការនារី<br>ក្រសួង-ស្ថាប័ន<br>ដៃគូអភិវឌ្ឍ<br>សង្គមស៊ីវិល វិស័យឯកជន | ✓ | ✓ | | | | ✓ | ✓ |
| | -ចំនួនប្រភេទសម្ភារៈផ្សព្វផ្សាយដែលបានរៀបចំ<br>-ចំនួនប្រព័ន្ធផ្សព្វផ្សាយដែលបានប្រើប្រាស់<br>-ចំនួនអ្នកចូលរួមក្នុងសិក្ខាសាលា ផ្សព្វផ្សាយ | រៀបចំសម្ភារៈសម្រាប់ផ្សព្វផ្សាយលើឯកសារការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា និងគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ | ក្រសួងកិច្ចការនារី<br>ក្រសួង-ស្ថាប័ន<br>ដៃគូអភិវឌ្ឍ<br>សង្គមស៊ីវិលនិងវិស័យឯកជន | | ✓ | ✓ | | | ✓ | ✓ |
| | | រៀបចំសិក្ខាសាលាផ្សព្វផ្សាយឯកសារការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា និងគោលនយោបាយជាតិ ស្តីពីសមភាពយេនឌ័រដល់គ្រប់អ្នកពាក់ព័ន្ធ | ក្រសួងកិច្ចការនារី<br>ក្រសួង-ស្ថាប័ន<br>ដៃគូអភិវឌ្ឍ<br>សង្គមស៊ីវិល | | ✓ | ✓ | | | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ២. ជំរុញ និងសម្របសម្រួលការបញ្ជ្រាបយេនឌ័រនៅក្នុងក្របខណ្ឌផែនការយុទ្ធ-សាស្ត្រ តាមវិស័យនិងកម្មវិធីជាតិ រួមទាំងការងារកំណែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីវិមជ្ឈការនិងវិសហមជ្ឈការ និងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ចំនួនលិខិតបទដ្ឋានគតិយុត្តដែលឆ្លើយតបយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម ដែលបានរៀបចំ | គាំទ្របច្ចេកទេសដល់ក្រសួង-ស្ថាប័ន ក្នុងការបញ្ជ្រាបយេនឌ័រនៅក្នុងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ<br><br>សហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប ពិនិត្យ និងផ្តល់យោបល់លើលិខិតបទដ្ឋានគតិយុត្ត ឱ្យឆ្លើយតបយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម | ក្រសួងកិច្ចការនារី<br>ក្រសួង-ស្ថាប័ន<br>លេខាធិការដ្ឋានគ.ជ.អ.ប | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | របាយការណ៍តាមដាន និងវាយតម្លៃ លើការអនុវត្តផែនការយុទ្ធសាស្ត្រ បានរៀបចំ និងផ្សព្វផ្សាយ | សហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប ជំរុញ តាមដាននិងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របង្កើនចំនួនស្ត្រីក្នុងមុខដំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងគោលនយោបាយស្តីពីការលើកកម្ពស់សមភាពយេនឌ័រសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | ក្រសួងកិច្ចការនារី<br>លេខាធិការដ្ឋានគ.ជ.អ.ប<br>ក្រសួង-ស្ថាប័ន<br>រដ្ឋបាលថ្នាក់ក្រោមជាតិ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនសវនកម្មយេនឌ័រដែលបានធ្វើ<br>ចំនួនរបាយការណ៍សវនកម្មដែលបានចងក្រង បោះពុម្ព និងផ្សព្វផ្សាយ | ភាពជាដៃគូជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប ធ្វើសវនកម្មយេនឌ័រក្នុងការអនុវត្តផអ៣ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | ក្រសួងកិច្ចការនារី<br>លេខាធិការដ្ឋានគ.ជ.អ.ប<br>ក្រសួង-ស្ថាប័ន<br>រដ្ឋបាលថ្នាក់ក្រោមជាតិ | | | ✓ | | | ✓ | ✓ |
| | ចំនួនដងនៃការចុះអភិបាលផ្តល់ការគាំទ្របច្ចេកទេសដល់មន្ទីរកិច្ចការនារី គ.ក.ស.ក និង គ.ក.ន.ក<br>ចំនួនមន្ត្រីដែលបានទទួលការគាំទ្របច្ចេកទេសដោយក្រសួង | ផ្តល់ការគាំទ្របច្ចេកទេស និងពង្រឹងសមត្ថភាព មន្ទីរកិច្ចការនារី គ.ក.ស.ក និងគ.ក.ន.ក ក្នុងការបញ្ជ្រាបយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម និងការបង្កើនភាពអង់អាចដល់ស្ត្រី តាមរយៈ | ក្រសួងកិច្ចការនារី<br>លេខាធិការដ្ឋានគ.ជ.អ.ប<br>មន្ទីរកិច្ចការនារី គ.ក.ស.ក<br>គ.ក.ន.ក | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ការងារចុះអភិបាល | | | | | | | | |
| | កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៩-២០៣០ ដែលមានសមាសភាព និង សូចនាករជាក់លាក់ ដែលឆ្លើយតបនឹងយេនឌ័រ ក្នុងរដ្ឋបាលសាធារណៈ<br><br>ចំនួនលិខិតបទដ្ឋាន និងកម្មវិធីនានា ក្នុងក្របខណ្ឌកម្មវិធីជាតិ ដែលឆ្លើយតបយេនឌ័រ | គាំទ្របច្ចេកទេស ក្នុងការលើកកម្ពស់ការបញ្ជ្រាបយេនឌ័រ នៅក្នុងការរៀបចំ និងអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០២០-២០៣០<br><br>បញ្ជ្រាបយេនឌ័រនៅក្នុងលិខិតបទដ្ឋាន និងកម្មវិធីនានា ក្នុងក្របខណ្ឌកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ឆ្នាំ២០២០-២០៣០ | ក្រសួងកិច្ចការនារី<br>ក្រសួងមុខងារសាធារណៈ | | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនក្រសួង ស្ថាប័នដែលមានប្រព័ន្ធតាមដាននិងវិភាជថវិកាសម្រាប់លើកកម្ពស់សមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រី | រៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាព ស្តីពីការរៀបចំថវិកាឆ្លើយតបនឹងយេនឌ័រ ដល់ក្រុមការងារយេនឌ័រក្រសួង-ស្ថាប័នពាក់ព័ន្ធ និងមន្ត្រីជំនាញថវិកា<br><br>ចងក្រងមេរៀនបទពិសោធន៍ និងឧត្តមានុវត្តន៍នានា ក្នុងការរៀបចំថវិកាដែលឆ្លើយតបយេនឌ័រ | ក្រសួងកិច្ចការនារី<br>ក្រុមការងារបញ្ជ្រាបយេនឌ័រក្រសួង-ស្ថាប័ន<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៣.ពង្រឹងសមត្ថភាព និងប្រសិទ្ធភាពយន្តការបញ្ជ្រាបយេនឌ័រនៅគ្រប់កម្រិតរួមទាំងការគាំទ្រដល់ក្រុមការងារ | -គោលការណ៍ណែនាំ និងឧបករណ៍ ត្រូវបានរៀបចំ និងបោះពុម្ពផ្សព្វផ្សាយ | រៀបចំគោលការណ៍ណែនាំ និងឧបករណ៍អនុវត្តស្តីពីការបញ្ជ្រាបនិងធ្វើស្ថាប័នីយកម្មយេនឌ័រនិងបង្កើនភាពអង់អាចដល់ស្ត្រីក្នុងក្រសួង-ស្ថាប័ន | ក្រសួងកិច្ចការនារី<br>ក្រសួង-ស្ថាប័នដៃគូពាក់ព័ន្ធ | | ✓ | ✓ | | | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| បញ្ជ្រាបយេនឌ័រ តាមក្រសួង-ស្ថាប័ន ក្រុមការងារបច្ចេកទេសយេនឌ័រ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់និងដៃគូពាក់ព័ន្ធ | -ចំនួនរបាយការណ៍ស្រាវជ្រាវបានចងក្រងនិងផ្សព្វផ្សាយ<br><br>-កម្មវិធីអភិវឌ្ឍសមត្ថភាពក្រុមការងារបញ្ជ្រាបយេនឌ័រក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំ | សិក្សាស្រាវជ្រាវ និងរៀបចំក្របខណ្ឌអភិវឌ្ឍសមត្ថភាព ដល់ក្រុមការងារបញ្ជ្រាបយេនឌ័រក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | ក្រសួងកិច្ចការនារី<br>ក្រសួង-ស្ថាប័ន<br>រដ្ឋបាលថ្នាក់ក្រោមជាតិ | | | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនក្រុមការងារយេនឌ័រក្រសួង ស្ថាប័ន ដែលបានទទួលការអភិវឌ្ឍសមត្ថភាពក្នុងការបញ្ជ្រាបយេនឌ័រ | អភិវឌ្ឍសមត្ថភាពក្រុមការងារបញ្ជ្រាបយេនឌ័រ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តមុខងារ និងគណនេយ្យភាពលើការអនុវត្តគោលនយោបាយស្តីពីសមភាពយេនឌ័រ តាមរយៈក្របខណ្ឌអភិវឌ្ឍសមត្ថភាព និងការអនុវត្តទៅតាមគោលការណ៍ណែនាំស្តីពីការបញ្ជ្រាបយេនឌ័រ | ក្រុមការងារបញ្ជ្រាបយេនឌ័រថ្នាក់ជាតិ និងក្រោមជាតិ | | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | -ចំនួនក្រសួង ស្ថាប័នដែលបានទទួលការគាំទ្រក្នុងការបញ្ជ្រាបយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី<br><br>-ចំនួនក្រសួង ស្ថាប័នដែលមាន ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ (GMAPs) និងបានធ្វើបច្ចុប្បន្នភាព | គាំទ្របច្ចេកទេសដល់ក្រុមការងារបញ្ជ្រាបយេនឌ័រតាមវិស័យ នៅថ្នាក់ជាតិ និងក្រោមជាតិក្នុងការបញ្ជ្រាបយេនឌ័រ ក៏ដូចជាក្នុងការរៀបចំផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ និងការបញ្ជ្រាបយេនឌ័រក្នុងសេចក្តីព្រាងគោលនយោបាយ កម្មវិធីតាមវិស័យ (តាមរយៈកិច្ចប្រជុំ ការចុះអភិបាល.) | ក្រុមការងារបញ្ជ្រាបយេនឌ័រថ្នាក់ជាតិ និងក្រោមជាតិ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | -ចំនួនកិច្ចប្រជុំប្រចាំឆមាស និងឆ្នាំរបស់ក្រុមការងារបញ្ជ្រាបយេនឌ័រ ក្រសួង-ស្ថាប័នដែលបានរៀបចំ<br>-ចំនួនរបាយការណ៍កិច្ចប្រជុំដែលបានចងក្រង | រៀបចំកិច្ចប្រជុំបណ្ដាញក្រុមការងារបញ្ជ្រាបយេនឌ័រក្រសួង ស្ថាប័នប្រចាំឆមាស និងឆ្នាំ ដើម្បីឆ្លុះបញ្ចាំង និងចែករំលែកអំពីវឌ្ឍនភាព បញ្ហាប្រឈម និងលើកទិសដៅបន្ត | ក្រសួងកិច្ចការនារី<br>ក្រុមការងារបញ្ជ្រាបយេនឌ័រក្រសួង ស្ថាប័ន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនកិច្ចប្រជុំប្រចាំត្រីមាសរបស់ក្រុមការងារបច្ចេកទេសយេនឌ័រ និង ក្រុមការងារ TWG-WLG ដែលបានរៀបចំ | រៀបចំកិច្ចប្រជុំប្រចាំត្រីមាស និងគាំទ្រដំណើរការការងាររបស់ក្រុមការងារបច្ចេកទេសយេនឌ័រ (TWG-G) និងក្រុមការងារ ក្នុងក្របខណ្ឌសូចនាករតាមដានរួមស្ដីពីយេនឌ័រ | លេខាធិការដ្ឋាន TWG-G<br>ក្រសួង ស្ថាប័ននិងដៃគូពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនអង្គភាព និងមន្ត្រីជំនាញក្នុងក្រសួងកិច្ចការនារី ដែលរីកចម្រើនលើជំនាញវិភាគនិងបញ្ជ្រាបយេនឌ័រតាមវិស័យ ដោយអនុវត្តស្របតាមក្របខណ្ឌអភិវឌ្ឍសមត្ថភាពស្ថាប័ន | សម្របសម្រួលរៀបចំនិងអនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញអង្គភាព និងស្ថាប័នក្រសួងកិច្ចការនារី ក្នុងការវិភាគ និងបញ្ជ្រាបយេនឌ័រតាមវិស័យ | លេខាធិការដ្ឋាន TWG-G<br>ក្រសួង និងមន្ទីរកិច្ចការនារី<br>ក្រុមការងារកំណែទម្រង់រដ្ឋបាលសាធារណៈ ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនវិធានការដាក់លាក់ ប្រចាំឆ្នាំ ដែលបានដាក់ចេញ ក្នុងការលើកកម្ពស់វប្បធម៌អហិង្សា សីលធម៌សង្គម និងការលើកកម្ពស់តួនាទីនិងតម្លៃស្ត្រី ដោយគណៈកម្មាធិការជាតិលើកកម្ពស់ សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ | គាំទ្រលេខាធិការដ្ឋានគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រីនិងគ្រួសារខ្មែរ បំពេញមុខងាររបស់ខ្លួន<br>ប្រជុំបូកសរុបការងារប្រចាំឆ្នាំ និងសន្និបាតរបស់គណៈកម្មាធិការជាតិ ក្នុងការពិនិត្យលើវឌ្ឍនភាព និងលើកទិសដៅបន្ត | លេខាធិការដ្ឋានគណៈកម្មាធិការជាតិលើកកម្ពស់ សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៤.ពង្រឹងប្រព័ន្ធនិងយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ លើការបញ្ជ្រាបយេនឌ័រ និងបង្កើនភាពអង់អាចរបស់ស្ត្រីតាមវិស័យ | ចំនួនរបាយការណ៍សំខាន់ៗ ដែលបានរៀបចំនិងផ្សព្វផ្សាយលើការអនុវត្តគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ និងគោលនយោបាយពាក់ព័ន្ធ | ចូលរួមជាមួយលេខាធិការដ្ឋានអចិន្ត្រៃយ៍ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្នុងការរៀបចំ និងជំរុញការអនុវត្តប្រព័ន្ធ និងឧបករណ៍ត្រួតពិនិត្យ និងតាមដានការអនុវត្តគោលនយោបាយជាតិ ស្តីពីសមភាពយេនឌ័រ និងគោលនយោបាយពាក់ព័ន្ធ រួមទាំងការអនុវត្តអនុសញ្ញា ស៊ី-ដ | ក្រសួងកិច្ចការនារី<br>លេខាធិការដ្ឋានអចិន្ត្រៃយ៍ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី<br>ក្រសួង-ស្ថាប័ន | | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៥. បង្កើនការយល់ដឹងជាសាធារណៈ និងការគាំទ្រលើការលើកកម្ពស់សមភាពយេនឌ័រ រួមទាំងការអនុវត្តកម្មវិធីការផ្លាស់ប្តូរឥរិយាបថ និងផ្នត់គំនិតអវិជ្ជមានរបស់សង្គមដែលរើសអើងលើស្ត្រី និងក្មេងស្រីគ្រប់រូបភាព | ចំនួនកម្មវិធីអប់រំផ្សព្វផ្សាយរបស់ក្រសួងកិច្ចការនារី (អគ្គនាយកដ្ឋាន) និងមន្ទីរកិច្ចការនារី ក្នុងការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងផ្លាស់ប្តូរឥរិយាបថ ផ្នត់គំនិតអវិជ្ជមានរបស់សង្គមដែលរើសអើងលើស្ត្រីគ្រប់រូបភាព | រៀបចំ និងអនុវត្តកម្មវិធីផ្សព្វផ្សាយនៅគ្រប់មធ្យោបាយ ក្នុងការលើកកម្ពស់សមភាពយេនឌ័រនិងផ្លាស់ប្តូរឥរិយាបថ ផ្នត់គំនិតអវិជ្ជមានរបស់សង្គមដែលរើសអើងលើស្ត្រី និងក្មេងស្រីគ្រប់រូបភាព | ក្រសួងកិច្ចការនារី<br>ក្រសួងព័ត៌មាន<br>បណ្តាញសារព័ត៌មាន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៦. ចងក្រងករណីសិក្សា និងមេរៀនបទពិសោធន៍ក្នុងការអនុវត្តការងារបញ្ជ្រាបយេនឌ័រ ក្នុងគោលនយោបាយ កម្មវិធី និងតាមវិស័យ និងចែករំលែក | ចំនួនករណីសិក្សាអំពីការអនុវត្តការបញ្ជ្រាបយេនឌ័រ ក្នុងគោលនយោបាយ កម្មវិធី និងតាមវិស័យនៅថ្នាក់ជាតិដែលបានចងក្រង និងផ្សព្វផ្សាយ | ចងក្រង និងផ្សព្វផ្សាយករណីសិក្សាមេរៀនបទពិសោធន៍អំពីការអនុវត្តការងារលើកកម្ពស់សមភាពយេនឌ័រការបញ្ជ្រាបយេនឌ័រ ក្នុងគោលនយោបាយ កម្មវិធី និងតាមវិស័យ | ក្រសួងកិច្ចការនារី<br>ក្រសួង ស្ថាប័នដៃគូពាក់ព័ន្ធ | | | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនករណីសិក្សា មេរៀនបទពិសោធន៍ ដែលបានចែករំលែកក្នុងព្រឹត្តិការណ៍កិច្ចប្រជុំ សិក្ខាសាលា សន្និសីទកម្រិតជាតិ អន្តរជាតិ និងតំបន់ | ចែករំលែកករណីសិក្សា មេរៀនបទពិសោធន៍ដែលបានចងក្រង នៅក្នុងព្រឹត្តិការណ៍ កិច្ចប្រជុំ សិក្ខាសាលា សន្និសីទក្នុងប្រទេស និងក្រៅប្រទេស | ក្រសួងកិច្ចការនារី<br>ក្រសួង ស្ថាប័នពាក់ព័ន្ធ | | | ✓ | ✓ | ✓ | ✓ | ✓ |

## យុទ្ធសាស្ត្រទី១៖ ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី

**គោលបំណង៖** ជំរុញការឆ្លើយតបយេនឌ័រទៅក្នុងក្របខណ្ឌគោលនយោបាយ ផែនការយុទ្ធសាស្ត្រនិងកម្មវិធីជាតិពាក់ព័ន្ធវិស័យសេដ្ឋកិច្ចនិងអភិវឌ្ឍសហគ្រិនភាព និងសក្តានុពលរបស់ស្ត្រី នៅក្នុងវិស័យសេដ្ឋកិច្ចឱ្យឆ្លើយតបនឹងបរិបទសង្គម ជាពិសេសក្នុងការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងការឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤ ប្រកបដោយបរិយាបន្ន។

| យុទ្ធសាស្ត្រ | សូចនាករ | សកម្មភាពគន្លឹះ | ដៃគូពាក់ព័ន្ធ | ពេលវេលា (២០១៩-២០២៣) | | | | | ធនធាន | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១៩ | ២០ | ២១ | ២២ | ២៣ | ជាតិ | ដៃគូ |
| ១. ពង្រឹង និងពង្រីកបរិយាកាសគាំទ្រ ផ្នែកគោលនយោបាយ និងការវិនិយោគប្រកបដោយបរិយាបន្ន ក្នុងការគាំទ្រការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី | ចំនួនគោលនយោបាយ និងកម្មវិធីអាទិភាពដែលចូលរួមដល់ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី និងឆ្លើយតបយេនឌ័រ ក្នុងវិស័យសេដ្ឋកិច្ច | សិក្សាស្រាវជ្រាវ និងចងក្រងធាតុចូលស្តីពីបញ្ហាយេនឌ័រ នៅក្នុងការអភិវឌ្ឍវិស័យពាក់ព័ន្ធសេដ្ឋកិច្ច<br>ស្វែងរកការគាំទ្រមតិ និងជំរុញឱ្យឆ្លើយតបនឹងសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី នៅក្នុងដំណើរការតាក់តែងកម្មវិធី និងគោលនយោបាយ ក្នុងវិស័យពាក់ព័ន្ធការអភិវឌ្ឍសេដ្ឋកិច្ច រួមទាំងក្នុងការអភិវឌ្ឍវិស័យសហគ្រាសខ្នាតតូចនិងមធ្យម កម្មវិធីមូលនិធិ និងអភិវឌ្ឍសហគ្រិនភាពនានា | ក្រសួងកិច្ចការនារី<br>ក្រសួងឧស្សាហកម្ម<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ក្រសួងពាណិជ្ជកម្ម<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនវិធានការដែលស៊ីចង្វាក់ជាមួយផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ និងឯកសារប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា ជំពូកស្តីពីយេនឌ័រនិងសេដ្ឋកិច្ច បានដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ និងផែនការយុទ្ធសាស្ត្រតាម | ផលិត និងផ្សព្វផ្សាយសម្ភារៈឯកសារប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា ជំពូកស្តីពីយេនឌ័រនិងសេដ្ឋកិច្ច | ក្រសួងកិច្ចការនារី<br>ស្ថាប័នពាក់ព័ន្ធ<br>ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ✓ | ✓ | | | | ✓ | ✓ |
| | | ភាពជាដៃគូក្នុងការធ្វើបច្ចុប្បន្នភាព និងគាំទ្របច្ចេកទេសក្នុងដំណើរការអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ និងផែនការមេក្នុងវិស័យ សេដ្ឋកិច្ច ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ស្ថាប័នពាក់ព័ន្ធ<br>ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | វិស័យរបស់ស្ថាប័នពាក់ព័ន្ធ | ពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម ទេសចរណ៍ និងអភិវឌ្ឍន៍ជនបទ ដែលស៊ីចង្វាក់ជាមួយនារីរតនៈទី៥ និងឆ្លុះបញ្ចាំងឯកសារប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា | | | | | | | | |
| | កម្មវិធីស្តីពីការលើកកម្ពស់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីបានតាក់តែង និងអនុវត្តន៍ (ឆ្នាំ២០២០-២០២៣) | -សិក្សាស្រាវជ្រាវ និងតាក់តែងកម្មវិធីស្តីពីការលើកកម្ពស់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី<br>-ដឹកនាំការអនុវត្តកម្មវិធី ស្តីពីការលើកកម្ពស់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី | ក្រសួងកិច្ចការនារី<br>ក្រសួងពាណិជ្ជកម្ម<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>វិស័យឯកជន<br>ស្ថាប័នពាក់ព័ន្ធ | | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនកិច្ចព្រមព្រៀងរវាងក្រសួងកិច្ចការនារី និងវិស័យឯកជនលើការងារអនុវត្តការងារសេដ្ឋកិច្ចសង្គម | សិក្សា និងជំរុញកម្មវិធីលើកកម្ពស់ភាពជាដៃគូ រវាងវិស័យសាធារណៈ និងឯកជន នៅក្នុងការបង្កើនភាពអង់អាចដល់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច និងការលើកកម្ពស់សមភាពយេនឌ័រ | ក្រសួងកិច្ចការនារី<br>វិស័យឯកជន<br>ស្ថាប័នពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ២. ពង្រីកកាលានុវត្តភាព និងបរិយាកាសសម្រាប់ការអភិវឌ្ឍសហគ្រិនភាព និងធុរកិច្ចសម្រាប់ស្ត្រី ដោយនវានុវត្តន៍ និងប្រកបដោយបរិយាបន្ន | -បណ្តាញសហគ្រិនស្ត្រីកម្ពុជា បានបង្កើត និងដំណើរការ (ចំនួនប្រជុំរបស់បណ្តាញ)<br>-ចំនួនសហគ្រិនស្ត្រីកម្ពុជា ដែលផ្តើម និងទទួលបានពានរង្វាន់ប្រចាំតំបន់ និងអន្តរជាតិ | -សម្របសម្រួលបង្កើត និងគាំទ្រដល់ដំណើរការបណ្តាញសហគ្រិនស្ត្រីនៅកម្ពុជា ដែលជាតំណាងសម្លេងស្ត្រីក្នុងវិស័យសហគ្រិន<br>-បង្កើនការយល់ដឹង និងស្វែងរកការគាំទ្រមតិឱ្យឆ្លើយតបលើបញ្ហាប្រឈម និងតម្រូវការដាក់លាក់ក្នុងការលើកកម្ពស់ស្ត្រីនៅក្នុងវិស័យសហគ្រាសខ្នាតមីក្រូ តូច និងមធ្យម នៅក្នុងវិធានការ និងគោលនយោបាយជាតិនានា ដើម្បីឆ្លើយតបបរិបទសកលភាវូបនីកម្ម សេដ្ឋកិច្ចឌីជីថល និងបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ | សមាជិកបណ្តាញCamWEN | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនកម្មវិធី និងគម្រោងដែលគាំទ្រដល់សហគ្រិនស្ត្រី ក្នុងក្របខណ្ឌបណ្តាញសហគ្រិនស្ត្រី បានរៀបចំ និងអនុវត្ត | -រៀបចំកិច្ចប្រជុំជាប្រចាំរបស់បណ្តាញសហគ្រិនស្ត្រី ក្នុងការជំរុញការគាំទ្រផ្នែកគោលនយោបាយនិងកម្មវិធី ដល់ការអភិវឌ្ឍសហគ្រិនស្ត្រីនៅកម្ពុជា<br>-រៀបចំ និងដឹកនាំដំណើរការកម្មវិធី និងមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនស្ត្រីនិងស្រាវជ្រាវ ក្នុងការគាំទ្រដល់ស្ត្រីវ័យក្មេង សហគ្រិនភាព ភាពជាអ្នកដឹកនាំរបស់ស្ត្រី<br>-ភាពជាដៃគូជាមួយធនាគារជាតិកម្ពុជា និងគ្រឹះស្ថាននានា ក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី | សមាជិកបណ្តាញសហគ្រិនស្ត្រីនៅកម្ពុជា<br>ភាពជាដៃគូជាមួយនឹងវិស័យឯកជន<br>ធនាគារជាតិនៃកម្ពុជា<br>សមាគមមីក្រូហិរញ្ញវត្ថុ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ចំនួនកម្មវិធី និងសកម្មភាពជាក់លាក់ដែលសម្របសម្រួលដោយក្រសួងកិច្ចការនារី ក្នុងពង្រីកទីផ្សារសម្រាប់ផលិតផលស្ត្រី | សម្របសម្រួល និងសហការក្នុងការសិក្សា និងស្វែងរកមធ្យោបាយ ដើម្បីលើកកម្ពស់លទ្ធភាព ពង្រីកទីផ្សារសម្រាប់ផលិតផលដែលផលិតដោយក្រុមស្ត្រី និងសហគ្រាសដែលដឹកនាំដោយស្ត្រី នៅក្នុង និងក្រៅប្រទេស | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនស្ត្រី និងក្មេងស្រី ដែលទទួលបានកម្មវិធីពេញលេញរយៈពេលវែងអំពីភាពជាអ្នកដឹកនាំ និងសហគ្រិនភាព ក្នុងក្របខណ្ឌកិច្ចព្រមព្រៀងជាមួយក្រសួងកិច្ចការនារី និងដៃគូពាក់ព័ន្ធ | -ភាពជាដៃគូជាមួយដៃគូពាក់ព័ន្ធក្នុងការអនុវត្តការទទួលខុសត្រូវផ្នែកសង្គម លើកកម្ពស់បរិយាកាសសម្រាប់ការអភិវឌ្ឍសមត្ថភាព និងពង្រីកសហគ្រិនភាពដល់ស្ត្រីវ័យក្មេង<br>-ដឹកនាំ និងសម្របសម្រួលការអនុវត្តកម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំ និងសហគ្រិនភាពដល់ស្ត្រី និងក្មេងស្រី ដើម្បីលើកកម្ពស់ជីវភាពរស់នៅ | ក្រសួងកិច្ចការនារី<br>WE-CAN<br>WEDU | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៣. ពង្រីកបរិយាកាសសម្រាប់ស្ត្រី ក្នុងការទទួលបានជំនាញវិជ្ជាជីវៈ ជាពិសេសស្របតាមតម្រូវការសេដ្ឋកិច្ចឌីជីថល និងប្រកបដោយបរិយាប័ន្ន | ចំនួនស្ត្រីទទួលបានការបណ្តុះបណ្តាលពីមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងវិទ្យាស្ថាននានា ក្រោមការសម្របសម្រួលដោយក្រសួងនិងមន្ទីរកិច្ចការនារី | -ចូលរួមក្នុងការបញ្ជ្រាបយេនឌ័រ ក្នុងគោលនយោបាយ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-សម្របសម្រួលជាមួយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងវិទ្យាស្ថាននានាដើម្បីផ្តល់ឱកាសបណ្តុះបណ្តាលជំនាញដល់ស្ត្រី ស្របតាមតម្រូវការសេដ្ឋកិច្ចឌីជីថល ក្នុងតំបន់ និងជាសកល និងប្រកបដោយបរិយាបន្នតាមវិស័យផ្សេងៗនិងសមធម៌ | ក្រសួងកិច្ចការនារី<br>ក្រសួងឧស្សាហកម្ម<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ក្រសួងពាណិជ្ជកម្ម<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ចំនួនស្ត្រី ដែលទទួលបានការបណ្តុះបណ្តាលពីមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី និងការហ្វឹកហាត់ការងារនៅតាមបណ្តាខេត្ត<br>ចំនួនមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី ដែលបានធ្វើពិពិធកម្មមុខងារក្នុងគំនិតផ្តួចផ្តើមនានា ឆ្លើយតបតម្រូវការជាក់ស្តែងរបស់ស្ត្រី និងក្មេងស្រី តាមតំបន់របស់ខ្លួន | ធ្វើពិពិធកម្មមុខងារ និងអភិវឌ្ឍមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី ក្នុងការផ្តល់បណ្តុះបណ្តាលវិជ្ជាជីវៈដល់ស្ត្រី ដែលមានទំនើបកម្ម រួមទាំងបច្ចេកវិទ្យាឌីជីថល ដោយសមស្របតាមតម្រូវការទីផ្សារ និងផ្សារភ្ជាប់ទីកន្លែងហាត់ការ និងតាមដាន | ក្រសួងកិច្ចការនារី<br>SDC<br>WDCs<br>WDCs<br>Private sector | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៤. លើកកម្ពស់ការយកចិត្តទុកដាក់ និងគាំទ្រដល់ស្ត្រីដែលកំពុង មានសកម្មភាពនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ | ចំនួនវិធានការផ្លូវការដែលទទួលស្គាល់ និងដោះស្រាយការទទួលបានកិច្ចគាំពារសង្គមសម្រាប់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ | សិក្សាស្វែងយល់ពីតម្រូវការអាទិភាពរបស់ស្ត្រី ក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងកំណត់ជាអនុសាសន៍ជាក់លាក់ក្នុងការឆ្លើយតប ចូលរួមបញ្ជ្រាបយេនឌ័រ និងការឆ្លើយតបនឹងស្ត្រីដែលស្ថិតក្នុងវិស័យក្រៅប្រព័ន្ធ ក្នុងរបៀបវារៈនយោបាយ និងវិធានការណ៍ឆ្លើយតបនានា | ក្រសួងកិច្ចការនារី<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ក្រសួងការងារនិងបណ្តុះ-បណ្តាលវិជ្ជាជីវៈ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៥. លើកកម្ពស់កម្មវិធី តុល្យភាពជីវិត គ្រួសារ និងការងារ បរិយាកាសមេត្រីភាព សុវត្ថិភាពសម្រាប់ស្ត្រី នៅក្នុងសកម្មភាពសេដ្ឋកិច្ច | ចំនួនកម្មវិធី និងវិធានការផ្លូវការនានាដែលដោះស្រាយ និងទទួលស្គាល់នូវតុល្យភាពជីវិត និងការងារ ការងារផ្ទះនិងការថែទាំដែលមិនមានកម្រៃ | -រៀបចំកម្មវិធីបង្កើនការយល់ដឹង និងស្វែងរកការគាំទ្រ យកចិត្តទុកដាក់ និងទទួលស្គាល់នូវតុល្យភាពជីវិត និងការងារ<br>-អនុវត្តគំនិតផ្តួចផ្តើម និងពង្រីកការអនុវត្តកម្មវិធីការទទួលខុសត្រូវផ្នែកសង្គម ក្នុងភាពជាដៃគូជាមួយវិស័យឯកជន និងការគាំទ្របរិយាកាសមេត្រីភាពនៅកន្លែងការងារសម្រាប់ស្ត្រី<br>-រៀបចំកម្មវិធី និងគំនិតផ្តួចផ្តើមក្នុងការលើកកម្ពស់ទទួលខុសត្រូវរបស់បុរសលើកិច្ចការផ្ទះសម្បែងនិងការថែទាំ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>វិស័យឯកជន<br>ដៃគូអភិវឌ្ឍន៍<br>សង្គមស៊ីវិល<br>MLVT<br>Oxfam<br>ILO | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនគំនិតផ្តួចផ្តើម និងកម្មវិធីដែលយកចិត្តទុកដាក់ដល់បង្កើនបរិយាកាសមេត្រីភាព និងសុវត្ថិភាពស្ត្រី តាមរយៈការសម្របសម្រួលដោយក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារី<br><br>ចំនួនស្ត្រីក្នុងតួនាទីជាអ្នកដឹកនាំក្នុងស្ថាប័នវិស័យឯកជន មានការកើនឡើង ក្រោយពីទទួលបានការស្វែងរកគាំទ្រមតិពីក្រសួងកិច្ចការនារី | -បង្កើនការយល់ដឹង និងគំនិតផ្តួចផ្តើមលើការរៀបចំទារកដ្ឋាន និងវិធានការប្រកបដោយសមធម៌សម្រាប់ស្ត្រី នៅកន្លែងធ្វើការ<br>-បង្កើនការយល់ដឹង អំពីសុវត្ថិភាពនៅកន្លែងការងារសម្រាប់ស្ត្រី រួមទាំងការអនុវត្តគោលនយោបាយទប់ស្កាត់ការបៀតបៀនផ្លូវភេទនៅកន្លែងការងារ<br>-បង្កើនការយល់ដឹង ស្វែងរកការគាំទ្រមតិ និងលើកទឹកចិត្តក្នុងការបង្កើនចំនួនស្ត្រីក្នុងតួនាទីជាអ្នកដឹកនាំ នៅក្នុងស្ថាប័ន និងអង្គភាពវិស័យឯកជន | ក្រសួង ស្ថាប័ន<br>វិស័យឯកជន<br>ដៃគូអភិវឌ្ឍន៍<br>សង្គមស៊ីវិល | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៧. ពង្រីកកាលានុវត្តភាពសេដ្ឋកិច្ចនៅតាមសហគមន៍ រួមទាំងការទទួលបានសេវាហិរញ្ញវត្ថុប្រកបដោយបរិយាបន្នសម្រាប់ស្ត្រី ជាពិសេសស្ត្រីក្រីក្រ ស្ត្រីពិការ ជនជាតិភាគតិច ជនជាតិដើមភាគតិច ស្ត្រីជាមេគ្រួសារ | ចំនួនក្រុមគោលដៅជាស្ត្រី និងគ្រួសារ ដែលទទួលបានទទួលផលផ្ទាល់ពីគម្រោង និងកម្មវិធីលើកកម្ពស់ជីវភាព និងផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីនៅជនបទដែលដឹកនាំដោយក្រសួងកិច្ចការនារី និងចូលរួមជាមួយក្រសួង ស្ថាប័នផ្សេងដែលមានកិច្ចព្រមព្រៀងជាផ្លូវការ | -ពង្រឹង និងពង្រីកក្រុមស្ត្រីតាមសហគមន៍ ដើម្បីបង្កើនសមត្ថភាព ជំនាញបច្ចេកទេស បច្ចេកវិទ្យាឌីជីថល និងធនធាន ក្នុងការបង្កើនផលិតភាព និងគុណភាពផលិតផល ព្រមទាំងទទួលបានព័ត៌មាននិងទីផ្សារ<br>-សម្របសម្រួលក្នុងការផ្តល់កម្មវិធីស្តីពីការបង្កើនចំណេះដឹងហិរញ្ញវត្ថុសម្រាប់ស្ត្រី នៅតាមសហគមន៍តាមរយៈ កិច្ចសហការជាមួយធនាគារជាតិកម្ពុជា ស្ថាប័នមីក្រូហិរញ្ញវត្ថុ និងសមាគមស្ថាប័នមីក្រូហិរញ្ញវត្ថុ | ក្រសួងកិច្ចការនារី<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>ធនាគារជាតិនៃកម្ពុជា | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

## យុទ្ធសាស្ត្រទី២៖ ការលើកកម្ពស់ការអប់រំរបស់ស្ត្រីនិងក្មេងស្រី

**គោលបំណង៖** ការពង្រឹង និងពង្រីកការឆ្លើយតបនឹងយេនឌ័រនៅក្នុងគោលនយោបាយ និងកម្មវិធីជាតិពាក់ព័ន្ធវិស័យអប់រំ និងការអភិវឌ្ឍយុវជន ជាពិសេសការអប់រំរបស់ស្ត្រីនិងក្មេងស្រីនៅកម្រិតខ្ពស់ និងការអប់រំដែលស្របតាមតម្រូវការសង្គម ព្រមទាំងការពង្រីកកម្មវិធីអប់រំស្តីពីការចិញ្ចឹមកូនតាមបែបវិជ្ជមានដែលឆ្លើយតបយេនឌ័រ។

| យុទ្ធសាស្ត្រ | សូចនាករ | សកម្មភាពគន្លឹះ | ដៃគូពាក់ព័ន្ធ | ពេលវេលា (២០១៩-២០២៣) | | | | | ធនធាន | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១៩ | ២០ | ២១ | ២២ | ២៣ | ជាតិ | ដៃគូ |
| ១. ពង្រឹងភាពជាដៃគូជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងអប់រំ យុវជន និងកីឡា ក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងក្របខណ្ឌគោលនយោបាយពាក់ព័ន្ធវិស័យអប់រំ វិស័យយុវជន និងជំរុញការទទួលបានការអប់រំរបស់ស្ត្រីនិងក្មេងស្រីនៅកម្រិតខ្ពស់ និងផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យា (STEAM) | ចំនួនគោលនយោបាយ ផែនការសកម្មភាព និងកម្មវិធីពាក់ព័ន្ធវិស័យអប់រំ ដែលឆ្លើយតបនឹងយេនឌ័រ តាមរយៈការចូលរួមពីក្រសួងកិច្ចការនារី | គាំទ្របច្ចេកទេសដល់ក្រសួង ស្ថាប័នក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ កម្មវិធី និងផែនការសកម្មភាពទាក់ទងវិស័យអប់រំ និងការអភិវឌ្ឍន៍យុវជន<br>ចូលរួមអភិវឌ្ឍគោលនយោបាយ ផែនការសកម្មភាព និងកម្មវិធីពាក់ព័ន្ធវិស័យអប់រំ និងការអភិវឌ្ឍយុវជនឆ្លើយតបនឹងយេនឌ័រ | ក្រសួងកិច្ចការនារី<br>ក្រសួងអប់រំ យុវជន និងកីឡា និងគ្រឹះស្ថានសិក្សាគ្រប់កម្រិត | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនអ្នកចូលរួមក្នុងវេទិកា វគ្គបណ្តុះបណ្តាល និងកម្មវិធីផ្សព្វផ្សាយស្តីពីសារៈសំខាន់នៃការសិក្សារបស់ក្មេងស្រីនៅក្នុងការអប់រំជំនាញ (STEAM) និងចំនួនក្មេងស្រីដែលបានចូលរៀន | សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំកម្មវិធីអប់រំផ្សព្វផ្សាយ និងលើកទឹកចិត្តសិស្សស្រីឱ្យបន្តការសិក្សាកម្រិតខ្ពស់ ជាពិសេសក្នុងការអប់រំជំនាញ STEAM | ក្រសួងកិច្ចការនារី<br>ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងព័ត៌មាន<br>គ្រឹះស្ថានសិក្សា<br>វិស័យឯកជន<br>ដៃគូអភិវឌ្ឍន៍ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ចំនួនសិស្សនិស្សិតជានារីទទួលបានអាហារូបករណ៍បន្តការអប់រំនៅកម្រិតខ្ពស់ តាមរយៈកិច្ចអន្តរគមន៍របស់ក្រសួងកិច្ចការនារី | -សហការជាមួយក្រសួងអប់រំ យុវជន និងកីឡាគ្រឹះស្ថានសិក្សាក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ ក្នុងការបង្កើនចំនួនអាហារូបករណ៍ដល់សិស្សនិស្សិតជានារី ប្រកបដោយបរិយាបន្នដើម្បីបន្តការសិក្សាដល់កម្រិតខ្ពស់<br>-ជំរុញ និងលើកទឹកចិត្តសិស្ស និស្សិតជានារីឱ្យទទួលអាហារូបករណ៍ប្រកបដោយបរិយាបន្នបន្តការសិក្សាកម្រិតខ្ពស់ តាមរយៈយុទ្ធនាការអប់រំផ្សព្វផ្សាយ វេទិកា ភាពជាគំរូ ការចែករំលែកបទពិសោធន៍របស់ស្ត្រីដែលបានបញ្ចប់ការសិក្សាកម្រិតខ្ពស់ | ក្រសួងកិច្ចការនារី<br>ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងព័ត៌មាន<br>គ្រឹះស្ថានសិក្សា<br>វិស័យឯកជន<br>ដៃគូអភិវឌ្ឍន៍ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនអន្តេវាសិកដ្ឋាននិងសិស្សនិស្សិតជានារី ដែលទទួលបានអាហារូបករណ៍ និងបានស្នាក់នៅ (ជារួម និងស្ថិតនៅក្រោមកិច្ចសម្របសម្រួលដោយក្រសួងកិច្ចការនារី) ប្រកបដោយបរិយាបន្ន | ស្វែងរកការគាំទ្រមតិជាមួយក្រសួងអប់រំ យុវជននិងកីឡា ក្រសួងស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍<br>ផលិតនិងផ្សព្វផ្សាយកម្មវិធីផ្សព្វផ្សាយអប់រំអំពីសារៈសំខាន់នៃការអប់រំកម្រិតខ្ពស់សម្រាប់សិស្ស និស្សិត ជានារី<br>ប្រមូល និងវិភាគចងក្រងទិន្នន័យស្តីពីសិស្សនិស្សិតជានារីដែលស្នាក់នៅក្នុងអន្តេវាសិកដ្ឋាន | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ២. ពង្រឹងភាពជាដៃគូជាមួយគ្រឹះស្ថានសិក្សា និងដៃគូពាក់ព័ន្ធ ក្នុងការលើកកម្ពស់សមភាពយេនឌ័រ ក្នុងចំណោមក្រុមមនុស្សវ័យក្មេង | -ចំនួនគ្រឹះស្ថានសិក្សា និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ដែលបានសហការជាមួយក្រសួងកិច្ចការនារី ក្នុងការលើកកម្ពស់សមភាពយេនឌ័រនិងការបង្កើនភាពអង់អាចដល់ស្ត្រី និងក្មេងស្រី ជាពិសេសស្ត្រីនិងក្មេងស្រីដែលស្ថិតក្នុងក្រុមដែលងាយរងគ្រោះ<br><br>-ចំនួនកិច្ចព្រៀងលើកិច្ចសហការរវាងក្រសួងកិច្ចការនារី ក្រសួងអប់រំ យុវជននិងកីឡា និងគ្រឹះស្ថានសិក្សាគ្រប់កម្រិត<br><br>-ចំនួនវេទិកានិងអ្នកចូលរួមស្តីពីជំនាញបំណិនជីវិត វប្បធម៌អហិង្សា និងសមភាពយេនឌ័រ ដែលរៀបចំដោយក្រសួង និងមន្ទីរកិច្ចការនារី | -សហការជាមួយគ្រឹះស្ថានសិក្សា ដើម្បីរៀបចំកម្មវិធីបង្កើនការយល់ដឹង និងគាំទ្រសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី ជាពិសេសនៅក្នុងចំណោមយុវវ័យ<br><br>សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងគ្រឹះស្ថានសិក្សាគ្រប់កម្រិត ក្នុងការរៀបចំកិច្ចព្រមព្រៀង ដើម្បីអនុវត្តកម្មវិធី និងផែនការលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យអប់រំ<br><br>រៀបចំកម្មវិធីបង្កើនការយល់ដឹងស្តីពីជំនាញបំណិនជីវិត វប្បធម៌អហិង្សា និងសមភាពយេនឌ័រ | ក្រសួងកិច្ចការនារី<br>ក្រសួងអប់រំ យុវជន និងកីឡា<br>គ្រឹះស្ថានសិក្សាគ្រប់កម្រិត និងដៃគូពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៣. លើកកម្ពស់កម្មវិធីទារកដ្ឋានតាមគ្រឹះស្ថានសាធារណៈ និងកន្លែងធ្វើការ និងពង្រីកកម្មវិធីមត្តេយ្យសិក្សាសហគមន៍នៅតាមមូលដ្ឋាន ព្រមទាំងលើកកម្ពស់កម្មវិធីអប់រំមាតាបិតា ការយល់ដឹងពីសារសំខាន់នៃការថែទាំនិងការសិក្សាសម្រាប់កុមារតូចនិងការចិញ្ចឹមកូនបែបវិជ្ជមាន | -ចំនួនទារកដ្ឋានបានបង្កើតនៅតាមគ្រឹះស្ថានការងារ<br>-ចំនួនមត្តេយ្យសិក្សាសហគន៍<br>-ចំនួនវេទិកានិងចំនួនមាតាបិតា អាណាព្យាបាល និងអ្នកថែទាំ ដែលទទួលបានការអប់រំផ្សព្វផ្សាយស្តីពីសារៈសំខាន់នៃការសិក្សារបស់កុមារតូច | -សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការជំរុញ និងគាំទ្រឱ្យមានការបង្កើត និងដំណើរការទារកដ្ឋានតាមកន្លែងការងារ<br>-សម្របសម្រួល និងសហការជាមួយក្រសួងមហាផ្ទៃ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ ក្នុងការអនុវត្តការងារ ពាក់ព័ន្ធមត្តេយ្យសិក្សាសហគមន៍ និងកម្មវិធីអប់រំផ្សព្វផ្សាយដល់មាតាបិតាអាណាព្យាបាលនិងអ្នកថែទាំ អំពីសារៈសំខាន់នៃការសិក្សារបស់កុមារតូច | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ<br>ដៃគូអភិវឌ្ឍន៍ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៤. ពង្រឹងនិងពង្រីកការអនុវត្តកម្មវិធីនិងយុទ្ធសាស្ត្រស្តីពីការចិញ្ចឹមកូនបែបវិជ្ជមានដែលឆ្លើយតបនឹងយេនឌ័រ | -ចំនួនវគ្គបណ្តុះបណ្តាល ស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន<br>-ចំនួនខេត្តគោលដៅដែលត្រូវបានពង្រីកបន្ថែម ដើម្បីអនុវត្តយុទ្ធសាស្ត្រ ស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន<br>-ចំនួនមាតាបិតា អាណាព្យាបាល និងអ្នកថែទាំ ដែលទទួលបានការអប់រំផ្សព្វផ្សាយស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន<br>-ប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃត្រូវបានបង្កើត | -រៀបចំ និងអនុវត្តកម្មវិធីផ្សព្វផ្សាយ និងអភិវឌ្ឍន៍សមត្ថភាពស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន<br>-សហការជាមួយដៃគូពាក់ព័ន្ធ ដើម្បីពិនិត្យលទ្ធភាព ក្នុងការពង្រីកខេត្តគោលដៅ ដើម្បីអនុវត្តយុទ្ធសាស្ត្រស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន<br>-រៀបចំកម្មវិធីអប់រំផ្សព្វផ្សាយដល់មាតាបិតា អាណាព្យាបាល និងអ្នកថែទាំស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន<br>-រៀបចំប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន | ក្រសួងកិច្ចការនារី<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ<br>ដៃគូអភិវឌ្ឍន៍ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៥. រៀបចំ និងអនុវត្តកម្មវិធីអប់រំសុខុមាលភាពសង្គមជាពិសេសសម្រាប់ស្ត្រីនិងគ្រួសារក្នុងការលើកកម្ពស់ការអនុវត្តសិទ្ធិរបស់ស្ត្រី និងក្មេងស្រីដោយពេញលេញ | ចំនួនវគ្គបណ្តុះបណ្តាល និងអ្នកចូលរួមស្តីពីការអប់រំសុខុមាលភាពសង្គម | -រៀបចំ និងអនុវត្តកម្មវិធីអភិវឌ្ឍន៍សមត្ថភាពគ្រូបង្គោលថ្នាក់ជាតិ និងក្រោមជាតិ ស្តីពីការអប់រំសុខុមាលភាពសង្គម<br>-គាំទ្រ និងអនុវត្តកម្មវិធីអប់រំផ្សព្វផ្សាយស្តីពីការអប់រំសុខុមាលភាពសង្គម<br>-ផលិតឯកសារ និងសម្ភារៈផ្សព្វផ្សាយស្តីពីការអប់រំសុខុមាលភាពសង្គម និងផ្សព្វផ្សាយតាមប្រព័ន្ធនិងវិធីសាស្ត្រថ្មីៗ | ក្រសួងកិច្ចការនារី<br>រដ្ឋបាលថ្នាក់ក្រោមជាតិ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៦. ពង្រីកកម្មវិធីសិក្សាស្រាវជ្រាវ អំពីស្ថានភាព និងបញ្ហាថ្មីៗពាក់ព័ន្ធស្ថានភាពស្ត្រី និងយេនឌ័រ នៅក្នុងវិស័យអប់រំ និងកីឡា | ចំនួនសិក្សាស្រាវជ្រាវ អំពីស្ថានភាព និងបញ្ហាថ្មីៗពាក់ព័ន្ធស្ថានភាពស្ត្រី និងយេនឌ័រ នៅក្នុងវិស័យអប់រំ និងកីឡា | ចងក្រង និងរៀបចំកម្មវិធីការសិក្សាស្រាវជ្រាវ អំពីស្ថានភាព និងបញ្ហាថ្មីៗពាក់ព័ន្ធនឹងស្ថានភាពស្ត្រី និងយេនឌ័រ នៅក្នុងវិស័យអប់រំ និងកីឡា ប្រកបដោយបរិយាបន្ន | ក្រសួងកិច្ចការនារី<br>ក្រសួងអប់រំ យុវជន និងកីឡា | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

## យុទ្ធសាស្ត្រទី៣៖ ការលើកកម្ពស់សុខភាពស្ត្រីនិងក្មេងស្រី

**គោលបំណង៖** ពង្រីកការឆ្លើយតបយេនឌ័រនៅក្នុងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីពាក់ព័ន្ធនឹងសុខភាព ជាពិសេសសុខភាពស្ត្រីនិងក្មេងស្រីពាក់ព័ន្ធសុខភាពបន្តពូជនិងសុខភាពផ្លូវភេទ អាហារូបត្ថម្ភ ព្រមទាំងជំងឺឆ្លងនិងជំងឺមិនឆ្លង។

| យុទ្ធសាស្ត្រ | សូចនាករ | សកម្មភាពគន្លឹះ | ដៃគូពាក់ព័ន្ធ | ពេលវេលា (២០១៩-២០២៣) | | | | | ធនធាន | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១៩ | ២០ | ២១ | ២២ | ២៣ | ជាតិ | ដៃគូ |
| ១ . ពង្រឹង និងពង្រីកការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពវិស័យសុខាភិបាលនិងកម្មវិធីនានា រួមមានកម្មវិធីសុខភាពបន្តពូជ សុខភាពមាតា-ទារក សុខភាពផ្លូវភេទ សុខភាពផ្លូវចិត្ត អាហារូបត្ថម្ភ សន្តិសុខស្បៀង កម្មវិធីប្រយុទ្ធនឹងជំងឺឆ្លង និងជំងឺមិនឆ្លង | ចំនួនគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធី នៃវិស័យសុខាភិបាលមានការឆ្លើយតបនឹងយេនឌ័រ | ពិនិត្យ វិភាគលើគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពនិងកម្មវិធីពាក់ព័ន្ធសុខភាព សន្តិសុខស្បៀង អាហារូបត្ថម្ភ ដើម្បីកំណត់គម្លាតយេនឌ័រ<br>រៀបចំវិធីសាស្ត្រក្នុងការស្វែងការគាំទ្រមតិ ដើម្បីបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីទាក់ទងនឹងសុខភាព សន្តិសុខស្បៀង និងអាហារូបត្ថម្ភ<br>ពង្រឹងភាពជាដៃគូ កិច្ចសហការ និងគាំទ្របច្ចេកទេស ក្នុងការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីពាក់ព័ន្ធវិស័យសុខាភិបាល | ក្រសួងកិច្ចការនារី<br>ក្រសួងសុខាភិបាល<br>ក្រសួងអភិវឌ្ឍជនបទ<br>ក្រសួង ស្ថាប័នពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ២.បង្កើនភាពអង់អាចដល់ស្ត្រី ក្មេងស្រី និងស្ត្រីដែលស្ថិតក្នុងក្រុមងាយរងគ្រោះ ទទួលបានសេវាសុខភាពគ្រប់ជ្រុងជ្រោយ មានគុណភាព | -ទិន្នន័យអ្នកចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា ប្រជុំ វេទិកាសាធារណៈ និងយុទ្ធការនានា ដែលបានរៀបចំ<br>-អត្រាយ៉ាងតិច ១៥% នៃ | -រៀបចំកម្មវិធីអភិវឌ្ឍន៍សមត្ថភាព និងកម្មវិធីអប់រំ ផ្សព្វផ្សាយ និង បង្កើនការយល់ដឹងជាសាធារណៈស្តីពីយេនឌ័រ និងសុខភាព សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដល់ប្រជាជនគោលដៅ | ក្រសួងកិច្ចការនារី<br>ក្រសួងសុខាភិបាល<br>ក្រសួងអភិវឌ្ឍជនបទ<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| សុវត្ថិភាព និងប្រសិទ្ធភាពនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ | ប្រជាពលរដ្ឋបានយល់ដឹងពីយេនឌ័រ សុខភាពបន្តពូជ សុខភាពមាតា ទារក ជំងឺឆ្លង ជំងឺមិនឆ្លង អាហារូបត្ថម្ភ សន្តិសុខស្បៀង និងព័ត៌មានទាក់ទងនឹងសេវាសុខាភិបាល និង<br>- ជំរុញឲ្យពួកគាត់ទៅទទួលយកសេវាសុខាភិបាលសាធារណៈ និងឯកជនទាន់ពេលវេលា។ | ជាពិសេសស្ត្រី ក្មេងស្រី និងក្រុមងាយរងគ្រោះ<br>-ជំរុញ លើកទឹកចិត្តឲ្យប្រជាពលរដ្ឋកម្ពុជាទាំងអស់ ជាពិសេស ស្ត្រី និង ក្មេងស្រី និងក្រុមងាយរងគ្រោះបានទៅទទួលយកសេវាសុខភាពមានគុណភាព ប្រសិទ្ធភាព និងសមធម៌នៅមូលដ្ឋានសុខាភិបាល។<br>-រៀបចំប្រព័ន្ធរបាយការណ៍តាមដាន និងវាស់វែងលទ្ធផលសម្រេចបានក្នុងឆ្នាំ និងចុងឆ្នាំ | | | | | | | | |
| ៣. បន្តអភិវឌ្ឍសមត្ថភាពមន្ត្រី និងអ្នកពាក់ព័ន្ធ នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិឱ្យបានទូលំទូលាយអំពីយេនឌ័រ និងសុខភាព សន្តិសុខស្បៀង និងអាហារូបត្ថម្ភ | ទិន្នន័យមន្ត្រីថ្នាក់ជាតិ និងក្រោមជាតិដែលទទួលបានការបណ្តុះបណ្តាលស្តីពីយេនឌ័រ និងសុខភាព<br><br>-អត្រាយ៉ាងតិច ១៥% នៃមន្ត្រីទទួលបានចំណេះដឹងកើនឡើងទាក់ទងនឹងយេនឌ័រ សុខភាពបន្តពូជ សន្តិសុខស្បៀង អាហារូបត្ថម្ភ | -បង្កើត និងអនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាពមន្ត្រី និងអ្នកពាក់ព័ន្ធ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អំពីយេនឌ័រ និងសុខភាព សន្តិសុខស្បៀង និងអាហារូបត្ថម្ភ<br>-រៀបចំប្រព័ន្ធតាមដាន និងវាស់វែងសមត្ថភាពមន្ត្រីថ្នាក់ជាតិ និងក្រោមជាតិ ស្តីពីយេនឌ័រ និងសុខភាព | ក្រសួងកិច្ចការនារី<br>ក្រសួងសុខាភិបាល<br>ក្រសួងអភិវឌ្ឍន៍ជនបទ<br>ក្រសួង ស្ថាប័នពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៤. លើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី នៅក្នុងក្របខណ្ឌកិច្ចគាំពារ សង្គម | របាយការណ៍វឌ្ឍនភាពនៃវិភាគគោលនយោបាយ ក្របខណ្ឌកិច្ចគាំពារសង្គម ដែលមានកំណត់នូវគម្លាតយេនឌ័រ និងស្វែងរកកាលានុវត្តនានា | -តាមដានការអនុវត្ត និងវិភាគគោលនយោបាយ និងក្របខណ្ឌកិច្ចគាំពារសង្គម ដើម្បីកំណត់គម្លាតយេនឌ័រ<br><br>-បង្កើតនិងអនុវត្តវិធីសាស្ត្រស្វែងរកការគាំទ្រមតិក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ និងក្របខណ្ឌកិច្ចគាំពារសង្គម ដើម្បីធានាថាស្ត្រី និងក្មេងស្រី ជាពិសេសស្ត្រី និងក្មេងស្រីដែលស្ថិតក្នុងក្រុមដែលងាយរងគ្រោះបានទទួលអត្ថប្រយោជន៍ពីក្របខណ្ឌកិច្ចគាំពារសង្គម ប្រកបដោយបរិយាបន្ន | ក្រសួងកិច្ចការនារី ស្ថាប័នពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៥. ពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលការងារបានអនុវត្ត ផ្អែកលើផែនការយុទ្ធសាស្ត្រ ៥ ឆ្នាំរបស់ក្រសួង និងរៀបចំប្រមូលចងក្រងទិន្នន័យថ្មីៗស្តីពីយេនឌ័រ និងសុខភាព អាហារូបត្ថម្ភ សន្តិសុខស្បៀង ជំងឺឆ្លងនិងជំងឺមិនឆ្លង | ចំនួនរបាយការណ៍ពីលទ្ធផលការងារ និងទិន្នន័យថ្មីៗ ស្តីពីយេនឌ័រនិងសុខភាព សន្តិសុខស្បៀង អាហារូបត្ថម្ភ ជំងឺឆ្លង និងជំងឺមិនឆ្លងដែលបានចងក្រង និងប្រើប្រាស់ | -សិក្សាស្រាវជ្រាវប្រមូល និងចងក្រងលទ្ធផលការងារ ទិន្នន័យថ្មីៗ ស្តីពីយេនឌ័រ និងសុខភាព សន្តិសុខស្បៀង អាហារូបត្ថម្ភ ជំងឺឆ្លងនិងជំងឺមិនឆ្លង<br>-ធ្វើបច្ចុប្បន្នភាពទិន្នន័យ និងព័ត៌មានតាមវិស័យពាក់ព័ន្ធដើម្បីកំណត់រកគម្លាតយេនឌ័រក្នុងវិស័យសុខាភិបាល (ប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា) | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

## យុទ្ធសាស្ត្រទី៤៖ កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រីនិងក្មេងស្រី

**គោលបំណង៖**ដើម្បីលើកកម្ពស់ការការពារសិទ្ធិ និងកាត់បន្ថយរាល់ទម្រង់នៃអំពើហិង្សាលើស្ត្រីនិងក្មេងស្រី ជាពិសេសក្រុមងាយរងគ្រោះ[2] ព្រមទាំងបង្កើនការផ្តល់សេវាដល់ស្ត្រីនិងក្មេងស្រីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រឱ្យកាន់តែមានប្រសិទ្ធភាព គុណភាព និងទាន់ពេលវេលា។

| យុទ្ធសាស្ត្រ | សូចនាករ | សកម្មភាពគន្លឹះ | ដៃគូពាក់ព័ន្ធ | ពេលវេលា (២០១៩-២០២៣) | | | | | ធនធាន | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១៩ | ២០ | ២១ | ២២ | ២៣ | ជាតិ | ដៃគូ |
| **ការបញ្ជ្រាបយេនឌ័រទៅក្នុងដំណើរការតាក់តែង និងអនុវត្តច្បាប់ និងកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌** | | | | | | | | | | |
| ១. ជំរុញការបញ្ជ្រាបយេនឌ័រទៅក្នុងដំណើរការតាក់តែង និងអនុវត្តច្បាប់ និងកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ | -ចំនួនច្បាប់ បទបញ្ញត្តិ ក្របខណ្ឌគតិយុត្ត និងគោលនយោបាយថ្មីៗដែលបានអនុម័តវិសោធនកម្ម និងកែលម្អដើម្បីឆ្លើយតបនឹងយេនឌ័រ និងតម្រូវការរបស់ក្រុមស្ត្រី និងក្មេងស្រីងាយរងគ្រោះប្រកបដោយបរិយាបន្ន<br><br>-ចំនួនស្ត្រីជាចៅក្រមព្រះរាជអាជ្ញា និងមេធាវី ដែលបានកើន | -ចូលរួមអភិវឌ្ឍ និងពិនិត្យច្បាប់ គោលនយោបាយនិងផែនការសកម្មភាពជាតិ គោលការណ៍ណែនាំ និងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការរំលោភបំពានផ្លូវភេទ និងផ្តល់កិច្ចការពារផ្លូវច្បាប់ដល់ស្ត្រី និងក្មេងស្រី<br>-សម្របសម្រួលក្នុងការរៀបចំឱ្យក្លាយជាដៃគូយុទ្ធសាស្ត្រជាមួយក្រុមការងារកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ<br>-ស្វែងរកការគាំទ្រមតិ ដើម្បីបង្កើនចំនួនអាហារូបករណ៍ និងលើកទឹកចិត្តដល់នារី ចូលរៀនថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកច្បាប់<br><br>-ស្វែងរកការគាំទ្រមតិ ដើម្បីបង្កើនចំនួនស្ត្រីក្នុងប្រព័ន្ធយុត្តិធម៌ និងអភិវឌ្ឍសមត្ថភាពអំពីយេនឌ័រ និងការ | ក្រសួងកិច្ចការនារី<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ<br>អង្គការសង្គមស៊ីវិល | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ឡើង | យល់ដឹងអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រដល់ចៅក្រមព្រះរាជអាជ្ញា និងមេធាវីជាស្ត្រី | | | | | | | | |
| **ការសម្របសម្រួល និងពង្រឹងកិច្ចសហការរវាងក្រសួងស្ថាប័ន និងដៃគូពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តន៍ផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងក្មេងស្រី ឆ្នាំ២០១៩-២០២៣ ឱ្យមានប្រសិទ្ធភាពខ្ពស់** | | | | | | | | | | |
| ២. សម្របសម្រួល និងជំរុញការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ២០១៩-២០២៣ តាមរយៈក្រុមការងារបច្ចេកទេសយេនឌ័រ ស្តីពីការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ (TWGG-GBV) និងក្រុមការងារទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រនៅថ្នាក់ក្រោមជាតិ | -ចំនួនកិច្ចប្រជុំក្រុមការងារបច្ចេកទេសយេនឌ័រ ស្តីពីការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ (TWGG-GBV)<br>-លទ្ធផលចម្បងៗដែលបានអនុវត្តន៍ស្របតាមរបៀប វារៈ និង កំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមក្រុមការងារបច្ចេកទេសយេនឌ័រ ស្តីពីការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ (TWGG-GBV)<br>-របាយការណ៍របស់ក្រសួង ស្ថាប័ន ដែលចូលរួមអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ ២០១៩-២០២៣ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលបង្ហាញអំពីការផ្តល់ថវិកាគ្រប់គ្រាន់សម្រាប់ការអនុវត្តសកម្មភាព ក៏ដូចជាបង្ហាញអំពីវឌ្ឍនភាពនៅក្នុងការអនុវត្ត | -រៀបចំ និងសម្របសម្រួលកិច្ចប្រជុំរបស់ TWGG-GBV ជាទៀងទាត់<br>-សម្របសម្រួលក្នុងការផ្សព្វផ្សាយផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (NAPVAW) នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ<br>-សម្របសម្រួល និងកៀរគរធនធានសម្រាប់ការអនុវត្តវិធានការពាក់ព័ន្ធនៃផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ព្រមទាំងរៀបចំ និងអនុវត្តន៍នូវផែនការប្រតិបត្តិសម្រាប់អនុវត្តន៍នូវវិធានការ និងសកម្មភាព<br>-សម្របសម្រួលរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ក្នុងការអនុវត្ត NAPVAWIII ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>-រៀបចំការវាយតម្លៃពាក់កណ្តាលអាណត្តិ NAPVAWIII និងការតាម | ក្រសួងកិច្ចការនារី<br>TWGG-GBV<br>ក្រសួង-ស្ថាប័ននិងដៃគូពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | សកម្មភាព<br><br>-ចំនួនក្រុមការងារទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រនៅថ្នាក់ក្រោមជាតិ បានបង្កើត និងដំណើរ ក្នុងការចូលរួមអនុវត្ត NAPVAW III | ជានប្រចាំឆ្នាំ លើការអនុវត្តវិស័យជាយុទ្ធសាស្ត្រក្នុង NAPVAW III<br>-រៀបចំ និងចែករំលែករបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពជាតិ ស្ដីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី តាមរយៈ TWGG-GBV<br>-អនុវត្តវិធានការជាក់ស្តែង ដើម្បីដោះស្រាយបញ្ហាអំពើហិង្សាទាក់ទងនឹងយេនឌ័រលើស្ត្រី និងក្មេងស្រីដែលងាយរងគ្រោះ ជាពិសេសពិការភាព<br>សិក្សាស្រាវជ្រាវ អំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រលើស្ត្រីនិងក្មេងស្រីដែលងាយរងគ្រោះ និងចែករំលែកនៅក្នុងកិច្ចប្រជុំរបស់ TWGG-GBV<br>-បង្កើនចំនួន និងអភិវឌ្ឍន៍សមត្ថភាពក្នុងការអនុវត្តមុខងាររបស់ក្រុមការងារ GBV-Working Group នៅថ្នាក់ក្រោមជាតិ<br>-សម្របសម្រួល និងកៀរគរធនធានសម្រាប់ការពង្រឹងបណ្តាញក្រុមការងារទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រនៅថ្នាក់ក្រោមជាតិ | | | | | | | |

| ការអនុវត្តផែនការសកម្មភាពជាតិទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ឆ្នាំ២០១៩-២០២៣ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៣. អនុវត្តកម្មវិធីការបង្ការទប់ស្កាត់អំពើហិង្សាលើស្ត្រី | -ចំនួនយុទ្ធនាការ និងអ្នកចូលរួមយុទ្ធនាការបង្ការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី<br>-ចំនួនគ្រូបង្គោល និងអ្នកចូលរួមក្នុងវេទិកាផ្សព្វផ្សាយថ្នាក់មូលដ្ឋាន ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពានផ្លូវភេទ<br>-ចំនួនគោលនយោបាយដែលមានដាក់បញ្ចូលបញ្ហាពលករទេសន្តរប្រវេសន៍ជាស្ត្រី | -រៀបចំយុទ្ធនាការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីផ្សព្វផ្សាយស្តីពីការបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្រុមងាយរងគ្រោះ (ក្រុមបរិយាប័ន្ន)<br>-រៀបចំកម្មវិធីអភិវឌ្ឍន៍សមត្ថភាពដល់គ្រូបង្គោល និងយុទ្ធនាការផ្សព្វផ្សាយថ្នាក់មូលដ្ឋានពាក់ព័ន្ធនឹងការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការរំលោភបំពានផ្លូវភេទ<br>-ផ្សព្វផ្សាយជាសាធារណៈ ដើម្បីលើកកម្ពស់ការយល់ដឹងទាក់ទងនឹងអំពើហិង្សាលើស្ត្រី ពលករទេសន្តរប្រវេសន៍ | ក្រសួង មន្ទីរកិច្ចការនារីខេត្ត រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | -របាយការណ៍ចងក្រងការអនុវត្តល្អនិងបញ្ហាប្រឈមទាក់ទងនឹងការបង្ការទប់ស្កាត់អំពើហិង្សាលើស្ត្រីពលករទេសន្តរប្រវេសន៍<br>-ចំនួនវេទិកា និងចំនួនអ្នកចូលរួមក្នុងវេទិកា<br>-ផ្សព្វផ្សាយថ្នាក់មូលដ្ឋាន ស្តីពីការកេងប្រវ័ញ្ចនានា អំពើជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ ការធ្វើចំណាកស្រុកដោយប្រថុយប្រថាន និងការ | -សហការជាមួយក្រសួង-ស្ថាប័ន និងដៃគូពាក់ព័ន្ធ ដើម្បីលើកកម្ពស់សិទ្ធិ និងកិច្ចការពារដល់ស្ត្រីពលករទេសន្តរប្រវេសន៍<br>-ចូលរួមរៀបចំគោលនយោបាយ និងកម្មវិធីនានាសម្រាប់គាំទ្រស្ត្រីពលករទេសន្តរប្រវេសន៍<br>-រៀបចំសិក្ខាសាលាថ្នាក់ជាតិប្រចាំឆ្នាំ ដើម្បីពិភាក្សានិងប្រមូលការអនុវត្តល្អ និងបញ្ហាប្រឈមទាក់ទងនឹងការបង្ការទប់ស្កាត់អំពើហិង្សាលើស្ត្រីពលករទេសន្តរប្រវេសន៍ | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ប្រើប្រាស់ និងចែកចាយគ្រឿងញៀន | -រៀបចំ និងអនុវត្តកម្មវិធីអភិវឌ្ឍន៍សមត្ថភាពដល់គ្រូបង្គោល និងយុទ្ធនាការផ្សព្វផ្សាយថ្នាក់មូលដ្ឋាន ពាក់ព័ន្ធនឹងការទប់ស្កាត់ការប្រើប្រាស់ និងចែកចាយគ្រឿងញៀនខុសច្បាប់ ដែលជាកត្តាជំរុញឱ្យមានអំពើហិង្សាក្នុងគ្រួសារ | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៤. រៀបចំ និងអនុវត្តកិច្ចការពារផ្លូវច្បាប់ និងសេវាកម្មពហុវិស័យសម្រាប់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ | -ចំនួនកន្លែងផ្តល់សេវាចម្រុះសម្រាប់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលបានបង្កើត និងដំណើរការ<br>-ចំនួនខេត្តដែលមានកន្លែងផ្តល់សេវាចម្រុះ សម្រាប់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ | -បង្កើត និងពង្រីកកន្លែងផ្តល់សេវាចម្រុះសម្រាប់ជួយស្ត្រី និងក្មេងស្រី ដែលរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ<br>-ពង្រីក និងពង្រឹងក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ ទងនឹងយេនឌ័រ អំពីរបៀបក្នុងការឆ្លើយតបនិងជួយជនរងគ្រោះ ស្ត្រីដែលមានពិការភាពនិងក្រុមងាយរងគ្រោះ (បរិយាបន្ន)<br>-ពង្រឹងសមត្ថភាពមន្ត្រីភ្នាក់ងារនគរបាលយុត្តិធម៌ និងអ្នកផ្តល់សេវាស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការផ្តល់ប្រឹក្សាជាមូលដ្ឋានដល់ស្ត្រី និងក្មេងស្រី ជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងប្រកបដោយបរិយាបន្ន | ក្រសួងកិច្ចការនារី<br>ក្រសួងសុខាភិបាល<br>ក្រសួងជំនាញពាក់ព័ន្ធ<br>អង្គការសង្គមស៊ីវិល | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | -ពង្រឹងសមត្ថភាព ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការផ្តល់ប្រឹក្សាជាមូលដ្ឋានដល់ស្ត្រីនិងក្មេងស្រីជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រដល់សមាជិកក្រុមការងារឆ្លើយតបពហុវិស័យ ចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ | | | | | | | | |
| ៥. រៀបចំនិងជំរុញការអនុវត្តក្របខណ្ឌច្បាប់ និងគោលនយោបាយពាក់ព័ន្ធនឹងការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រនិងទប់ស្កាត់រាល់ទម្រង់នៃអំពើធ្វើអាជីវកម្មលើស្ត្រី និងក្មេងស្រី | ចំនួនច្បាប់ និងឯកសារគតិយុត្តដែលបានធ្វើវិសោធនកម្ម និងរៀបចំថ្មី<br><br>ចំនួនកម្មវិធីអភិវឌ្ឍន៍សមត្ថភាពមន្ត្រីភ្នាក់ងារនគរបាលយុត្តិធម៌ និងអ្នកផ្តល់សេវា នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្តីពីច្បាប់ពាក់ព័ន្ធ បទដ្ឋានគតិយុត្តិ គោលការណ៍ណែនាំ និងនីតិវិធីក្នុងការជួយជនរងគ្រោះ និងប្រកបដោយបរិយាបន្ន | សម្របសម្រួលការរៀបចំវិសោធនកម្មច្បាប់ និងរៀបចំសេចក្តីព្រាងច្បាប់ពាក់ព័ន្ធការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងទប់ស្កាត់រាល់ទម្រង់នៃអំពើធ្វើអាជីវកម្មលើស្ត្រី និងក្មេងស្រី<br><br>បន្តពង្រឹងសមត្ថភាពមន្ត្រីភ្នាក់ងារនគរបាលយុត្តិធម៌ និងអ្នកផ្តល់សេវា នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្តីពីច្បាប់ពាក់ព័ន្ធ បទដ្ឋានគតិយុត្តិ គោលការណ៍ណែនាំ និងនីតិវិធីក្នុងការជួយជនរងគ្រោះ | ក្រសួងកិច្ចការនារី<br>ក្រសួងជំនាញ-ពាក់ព័ន្ធ<br>អង្គការសង្គមស៊ីវិល | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៦. ពិនិត្យតាមដាន និងវាយតម្លៃ ការអនុវត្តផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី លើកទី៣ ២០១៩-២០២៣ | របាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី លើកទី៣ ២០១៩-២០២៣ និងចំនួនសកម្មភាពផ្សព្វផ្សាយ | រៀបចំវាយតម្លៃពាក់កណ្តាលអាណត្តិលើផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី លើកទី៣ ២០១៩-២០២៣<br>រៀបចំ និងដំណើរការប្រព័ន្ធប្រមូលទិន្នន័យ និងពិនិត្យតាមដានទិន្នន័យអំពើហិង្សាលើស្ត្រី | ក្រសួងកិច្ចការនារី<br>ក្រសួងជំនាញពាក់ព័ន្ធ<br>អង្គការសង្គមស៊ីវិល | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | របាយការណ៍អំពីប្រព័ន្ធប្រមូល និងពិនិត្យតាមដានទិន្នន័យស្តីពីអំពើហិង្សាលើស្ត្រី ដែលបានរៀបចំ និងចែករំលែកនៅក្នុងកិច្ចប្រជុំ TWGG-GBV | ប្រមូល និងពិនិត្យតាមដានទិន្នន័យដែលប្រើប្រាស់ដោយក្រសួងកិច្ចការនារី ក្រសួងស្ថាប័ន និងដៃគូពាក់ព័ន្ធ ដើម្បីបន្តពិនិត្យតាមដានលើការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី<br>ចងក្រងទិន្នន័យជាមូលដ្ឋានទាក់ទងនឹងការផ្តល់សេវា និងការបញ្ជូនជនរងគ្រោះ និងក្រុមងាយរងគ្រោះដោយដោយអំពើហិង្សាលើស្ត្រី | | | | | | | | |
| | របាយការណ៍ចុងក្រោយ និងលទ្ធផលពីការអង្កេតអំពីប្រេវ៉ាឡង់នៃអំពើហិង្សាលើស្ត្រី | បញ្ចូលទិន្នន័យពីការធ្វើអង្កេតលើប្រេវ៉ាឡង់ទៅក្នុងប្រព័ន្ធស្ថិតិជាតិ | | | | | | | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៧. ការសម្របសម្រួល និងគាំទ្រការអនុវត្តផែនការសកម្មភាពថ្នាក់ជាតិ តំបន់ និងអនុតំបន់ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ អំពើធ្វើអាជីវកម្មផ្លូវភេទ និងការកេងប្រវ័ញ្ចនានា | ចំនួនវេទិកានិងចំនួនអ្នកចូលរួមក្នុងវេទិកាផ្សព្វផ្សាយថ្នាក់ភូមិ ស្តីពី ការកេងប្រវ័ញ្ចនានា អំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ការធ្វើចំណាកស្រុកដោយប្រថុយប្រថាន | រៀបចំ និងអនុវត្តកម្មវិធីអភិវឌ្ឍន៍សមត្ថភាពគ្រូបង្គោល និងកម្មវិធីយុទ្ធនាការផ្សព្វផ្សាយនៅថ្នាក់មូលដ្ឋាន និងកិច្ចប្រជុំក្រុមការងារពាក់ព័ន្ធការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចនានា ជាពិសេសស្ត្រី និងកុមារ និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន<br>រៀបចំយុទ្ធនាការផ្សព្វផ្សាយនិងកម្មវិធីលើកកម្ពស់ការយល់ដឹងជាសាធារណៈក្នុងការទប់ស្កាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ជាពិសេសលើស្ត្រី និងកុមារ សម្របសម្រួលធ្វើបច្ចុប្បន្នភាព និងអភិវឌ្ឍអនុស្សរណៈនៃការយោគយល់គ្នាទ្វេរភាគី ឬពហុភាគី ស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសលើស្ត្រី និងកុមារ | ក្រសួង មន្ទីរកិច្ចការនារីខេត្ត អាជ្ញាធរនៅថ្នាក់ក្រោមជាតិ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៨. ចូលរួមគាំទ្រការអនុវត្ត ផែនការសកម្មភាព ស្តីពីការទប់ស្កាត់ និងឆ្លើយតបអំពើហិង្សាលើកុមារ ឆ្នាំ២០១៧ - ២០២១ | ចំនួនផែនការសកម្មភាពស្តីពីការបង្ការទប់ស្កាត់អាពាហ៍ពិពាហ៍វ័យកុមារ និងការមានផ្ទៃពោះវ័យជំទង់ នៅថ្នាក់ខេត្ត ដែលបានរៀបចំ<br>របាយការណ៍វាយតម្លៃនៃការអនុវត្ត ផែនការសកម្មភាពស្តីពីការបង្ការទប់ស្កាត់អាពាហ៍ពិពាហ៍វ័យកុមារ និងការមានផ្ទៃពោះវ័យជំទង់ ដែលបានរៀបចំ និងផ្សព្វផ្សាយ | រៀបចំការវាយតម្លៃលើផែនការសកម្មភាពស្តីពីការបង្ការទប់ស្កាត់អាពាហ៍ពិពាហ៍វ័យកុមារ និងការមានផ្ទៃពោះវ័យជំទង់ខេត្តរតនគិរី<br>រៀបចំផែនសកម្មភាព ស្តីពីការបង្ការទប់ស្កាត់អាពាហ៍ពិពាហ៍ វ័យកុមារ និងការមានផ្ទៃពោះវ័យជំទង់សម្រាប់ខេត្តអាទិភាព | ក្រសួងកិច្ចការនារី<br>រដ្ឋបាលខេត្តរតនគិរី<br>អង្គការសង្គមស៊ីវិល | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៩. សិក្សាស្រាវជ្រាវដែលមាននវានុវត្តន៍ដើម្បីលើកកម្ពស់ចំណេះដឹង និងការដាក់ចេញជាយុទ្ធសាស្ត្រនិងរៀបចំគោលនយោបាយឆ្លើយតបអំពើហិង្សាទាក់ទងយេនឌ័រ | ចំនួនរបាយការណ៍សិក្សាស្រាវជ្រាវ ដែលបានសម្របសម្រួល និងចែករំលែកនៅក្នុងប្រព័ន្ធគ្រប់គ្រងនិងចែករំលែកព័ត៌មានរបស់ក្រសួង | សិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងបញ្ហាថ្មីៗអំពើហិង្សាទាក់ទងយេនឌ័រ ដែលស្របតាមបរិបទថ្មីៗរបស់សង្គម | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

## យុទ្ធសាស្ត្រទី៥៖ ភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុងវិស័យសាធារណៈ និងនយោបាយ

**គោលបំណង៖** លើកកម្ពស់ការចូលរួមរបស់ស្ត្រី នៅក្នុងថ្នាក់ធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិត និងការលើកកម្ពស់សមភាពយេនឌ័រក្នុងភាពជាអ្នកដឹកនាំ។

| យុទ្ធសាស្ត្រ | សូចនាករ | សកម្មភាពគន្លឹះ | ដៃគូពាក់ព័ន្ធ | ពេលវេលា (២០១៩-២០២៣) | | | | | ធនធាន | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១៩ | ២០ | ២១ | ២២ | ២៣ | ជាតិ | ដៃគូ |
| ១. ពង្រឹង និងពង្រីកបរិយាកាសគាំទ្រផ្នែកគោលនយោបាយក្នុងការគាំទ្រការចូលរួមរបស់ស្ត្រីជាថ្នាក់ដឹកនាំ ទាំងនៅថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ ទាំងកម្រិតនយោបាយ និងកម្រិតជំនាញ | -ចំនួនព្រឹត្តិការណ៍ កិច្ចប្រជុំ វេទិកា និងយុទ្ធនាការនានា ដែលបានពិភាក្សា និងស្វែងរកការគាំទ្រមតិ លើការដាក់ចេញនូវវិធានការដាក់លាក់ ក្នុងការបង្កើនចំនួនស្ត្រី ក្នុងមុខងារសាធារណៈ ដែលស្ថិតក្នុងការសម្របសម្រួល ដោយក្រសួងកិច្ចការនារី ដែលបានរៀបចំ<br>-ចំនួនលិខិតបទដ្ឋានគតិយុត្តិ និងវិធានការណ៍នានា ក្នុងការបង្កើនចំនួនស្ត្រី និងជាអ្នកដឹកនាំក្នុងវិស័យសាធារណៈ ដែលបានរៀបចំនិងអនុវត្ត<br>ព័ត៌មានស្ត្រីជាថ្នាក់ដឹកនាំក្នុងវិស័យនយោបាយ សាធារណៈ ឯកជន ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិល បានចងក្រង និងចែករំលែក | -ភាពជាដៃគូ និងសហការជាមួយក្រសួង-ស្ថាប័ន ក្នុងការដាក់ចេញ និងលើកទឹកចិត្តលើការអនុវត្តនូវវិធានការណ៍ និងសកម្មភាពជាក់លាក់ដែលគាំទ្រ និងបង្កើនចំនួនស្ត្រីក្នុងវិស័យសាធារណៈ<br>(កិច្ចការនេះ ជារបៀបវារៈមួយរបស់ក្រុមបច្ចេកទេសយេនឌ័រ WLG និងជាធាតុចូលក្នុងការបញ្ជ្រាបយេនឌ័រ ក្នុងរដ្ឋបាលសាធារណៈ)<br>-ភាពជាដៃគូ និងសហការជាមួយរដ្ឋសភា ព្រឹទ្ធសភា ក្រសួង-ស្ថាប័ន វិស័យឯកជន ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិល ក្នុងការប្រមូល និងចក្រងទិន្នន័យស្ត្រីជាថ្នាក់ដឹកនាំក្នុងវិស័យនយោបាយ សាធារណៈ ឯកជន ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិល | ក្រសួងកិច្ចការនារី<br>ក្រសួងមុខងារសាធារណៈ<br>ក្រសួងមហាផ្ទៃ<br>លេខាធិការដ្ឋានគ.ជ.អ.ប<br>ដៃគូពាក់ព័ន្ធ និងសង្គមស៊ីវិល | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | -ចំនួនគណបក្សនយោបាយដែលមានកំណត់ដាក់លាក់នូវ | សហការ និងស្វែងរកការគាំទ្រមតិជាមួយគណបក្សនយោបាយ គ.ជ.ប | ក្រសួងកិច្ចការនារី<br>គណៈបក្សនយោបាយ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | វិធានការនិងគោលនយោបាយក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនចំនួនស្ត្រី ក្នុងបញ្ជីបេក្ខភាពលេខរៀង(លំដាប់ខ្ពស់)នៃបញ្ជីឈ្មោះបោះឆ្នោតជាតិ<br>-អត្រា (%) ស្ត្រីនៅក្នុងបញ្ជីឈ្មោះបោះឆ្នោតជាតិនានា | និងដៃគូពាក់ព័ន្ធ ក្នុងការដាក់ចេញនិងអនុវត្តគោលនយោបាយយេនឌ័រក្នុងគណបក្សនយោបាយ និងការបង្កើនចំនួនស្ត្រីក្នុងវិស័យនយោបាយជាពិសេសដើម្បីធានាថាមានសមាសភាពស្ត្រី ក្នុងលេខរៀងជាប់ឆ្នោត | គ.ជ.ប<br>ដៃគូពាក់ព័ន្ធនិងសង្គមស៊ីវិល | | | | | | | |
| | របាយការណ៍វឌ្ឍនភាព និងមេរៀនបទពិសោធន៍ជាក់លាក់នៃការអនុវត្តវិធានការណ៍និងគោលនយោបាយបានកំណត់នៅក្នុងប្រព័ន្ធនិងយន្តការដែលសម្របសម្រួលដោយក្រសួងកិច្ចការនារី និងចែករំលែក | បង្កើត ធ្វើបច្ចុប្បន្នភាព និងអនុវត្តជាប្រចាំលើប្រព័ន្ធ និងយន្តការក្នុងការតាមដាន និងលើកទឹកចិត្តការអនុវត្តវិធានការពាក់ព័ន្ធការបង្កើនសមាសភាពស្ត្រី ក្នុងវិស័យមុខងារសាធារណៈនិងភាពជាអ្នកដឹកនាំ (សេចក្តីណែនាំរបស់ក្រសួងមុខងារសាធារណៈ) និងស្ត្រីក្នុងវិស័យនយោបាយ | ក្រសួងកិច្ចការនារី<br>ក្រសួងមុខងារសាធារណៈ<br>ក្រសួងមហាផ្ទៃ<br>លេខាធិការដ្ឋានគ.ជ.អ.ប<br>ដៃគូពាក់ព័ន្ធនិងសង្គមស៊ីវិល | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ២. ពង្រឹងបណ្តាញ និងសមត្ថភាពស្ត្រីក្នុងថ្នាក់ធ្វើសេចក្តីសម្រេច ក្នុងវិស័យសាធារណៈ និងនយោបាយ នៅថ្នាក់ជាតិ និងក្រោមជាតិ | -ចំនួនកម្មវិធី និងសកម្មភាពអភិវឌ្ឍន៍សមត្ថភាពនិងភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុងវិស័យសាធារណៈ និងនយោបាយនៅថ្នាក់ជាតិ និងក្រោមជាតិដែលស្ថិតនៅក្រោមក្របខណ្ឌ<br>-សម្រប សម្រួលនិងភាពជាដៃគូជាមួយក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារី បានអនុវត្តចំនួនស្ត្រី ក្នុងថ្នាក់ធ្វើសេចក្តីសម្រេច ក្នុងវិស័យសាធារណៈ | -ភាពជាដៃគូជាមួយក្រសួង-ស្ថាប័ននិងដៃគូពាក់ព័ន្ធ អភិវឌ្ឍសមត្ថភាពនិងភាពជាអ្នកដឹកនាំស្ត្រីក្នុងវិស័យសាធារណៈនិងវិស័យនយោបាយជាពិសេសស្ត្រីជាថ្នាក់ដឹកនាំកម្រិតគ្រប់គ្រងក្នុងរដ្ឋបាលសាធារណៈ នៅថ្នាក់ជាតិនិងក្រោមជាតិនិងក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ)<br>(កិច្ចការនេះ ក្រសួងកិច្ចការនារី នឹងបន្តសម្របសម្រួលរៀបចំ និងគាំទ្រការអនុវត្តក្របខណ្ឌអភិវឌ្ឍសមត្ថភាព | ក្រសួងកិច្ចការនារី<br>ក្រសួងមុខងារសាធារណៈ<br>សាលាភូមិន្ទរដ្ឋបាល<br>សាលាជាតិរដ្ឋបាលមូលដ្ឋាន<br>ដៃគូពាក់ព័ន្ធ<br>និងសង្គមស៊ីវិល | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | និងនយោបាយ នៅថ្នាក់ជាតិ និងក្រោមជាតិ ដែលបានចូលរួមក្នុងកម្មវិធីអភិវឌ្ឍភាពជាអ្នកដឹកនាំនិងវគ្គបណ្តុះបណ្តាល | និងភាពជាអ្នកដឹកនាំរបស់ស្ត្រី ដែលជាមុខងាររបស់ក្រុមការងារបច្ចេកទេសយេនឌ័រស្តីពីស្ត្រីក្នុងភាពជាអ្នកដឹកនាំនិងអភិបាលកិច្ច ) | | | | | | | | |
| | -ចំនួនកម្មវិធីអភិវឌ្ឍសមត្ថភាព និងភាពជាអ្នកដឹកនាំសម្រាប់ស្ត្រី ដែលបានរៀបចំ<br><br>-ចំនួនស្ត្រីជាអ្នកដឹកនាំដែលបានចូលរួមក្នុងវេទិកា/សិក្ខាសាលា/វគ្គបណ្តុះបណ្តាល អភិវឌ្ឍន៍សមត្ថភាពស្ត្រីក្នុងភាពជាអ្នកដឹកនាំ<br><br>-ចំនួនឯកសារអភិវឌ្ឍសមត្ថភាពភាពជាអ្នកដឹកនាំ និង យេនឌ័រ ដែលចងក្រងបោះពុម្ព និងប្រើប្រាស់ | -រៀបចំ និងអនុវត្តកម្មវិធីអភិវឌ្ឍភាពជាអ្នកដឹកនាំស្ត្រី ក្នុងវិស័យសាធារណៈ នយោបាយ និងឯកជន (វគ្គបណ្តុះបណ្តាល សិក្ខាសាលា វេទិកា ការហ្វឹកហ្វឺន ទស្សនកិច្ចសិក្សា និងមធ្យោបាយឌីជីថលនានា)<br><br>-រៀបចំចងក្រងឯកសារបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ (គោលគំនិតសំខាន់ៗ ស្តីពីភាពជាអ្នកដឹកនាំ សិល្បៈក្នុងការប្រាស្រ័យទាក់ទង ជំនាញសម្របសម្រួល ជំនាញចរចា ការស្វែងរកការគាំទ្រមតិ គោលគំនិតក្នុងការបញ្ជ្រាបយេនឌ័រ ) | ក្រសួងកិច្ចការនារី<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ<br>វិស័យឯកជន<br>ដៃគូពាក់ព័ន្ធនិងសង្គមស៊ីវិល | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនរបាយការណ៍ និងករណីសិក្សានិងសៀវភៅព័ត៌មានស្តីពីស្ត្រីក្នុងភាពជាអ្នកដឹកនាំក្នុងវិស័យសាធារណៈ នយោបាយ និងឯកជន ដែលបានចងក្រង និងផ្សព្វផ្សាយក្នុងបណ្តាញផ្សព្វផ្សាយក្រសួងកិច្ចការនារី | -ចងក្រងព័ត៌មាន មេរៀនបទពិសោធន៍ និងករណីសិក្សា អំពីស្ត្រីក្នុងភាពជាអ្នកដឹកនាំក្នុងវិស័យសាធារណៈ នយោបាយ និងឯកជន<br>-ធ្វើបច្ចុប្បន្នភាព និងចងក្រងព័ត៌មានចំនួនស្ត្រីជាថ្នាក់ដឹកនាំក្នុងវិស័យសាធារណៈ នយោបាយ និងតុលាការទាំងថ្នាក់ជាតិ និងក្រោមជាតិ និង | ក្រសួងកិច្ចការនារី<br>ក្រសួងមុខងារសាធារណៈ<br>ក្រសួង-ស្ថាប័ន រដ្ឋសភា<br>ព្រឹទ្ធសភា<br>ដៃគូពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ផ្សព្វផ្សាយឱ្យបានទូលំទូលាយ | | | | | | | | |
| | ចំនួនកិច្ចប្រជុំ សិក្ខាសាលា របស់បណ្តាញស្ត្រីជាអ្នកដឹកនាំនៅក្នុងវិស័យសាធារណៈ និងនយោបាយដែលបានរៀបចំ (បែងចែកតាមបណ្តាញនីមួយៗ) និងស្ថិតនៅក្រោមការគាំទ្របច្ចេក ទេសពីក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារី | រៀបចំគំនិតផ្តួចផ្តើមនានា និងពង្រឹងដំណើរការរបស់បណ្តាញស្ត្រីជាអ្នកដឹកនាំក្នុងវិស័យនយោបាយ និងសាធារណៈ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈកិច្ចសហការជាមួយក្រសួង-ស្ថាប័ន និងដៃគូពាក់ព័ន្ធ | ក្រសួងកិច្ចការនារី<br>ស្ថាប័ននីតិប្បញ្ញត្តិ<br>ក្រសួង-ស្ថាប័ន<br>ដៃគូពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៣. ពង្រីកការយល់ដឹង និងការផ្លាស់ប្តូរឥរិយាបថ របស់សាធារណៈជន រួមទាំងយុវវ័យ ដៃគូពាក់ព័ន្ធ អំពីការលើកកម្ពស់សមភាព និងសមធម៌យេនឌ័រ ជាពិសេសការចូលរួមរបស់ស្ត្រីនៅក្នុងកិច្ចអភិវឌ្ឍន៍ ភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច | ចំនួនវេទិកា យុទ្ធនាការ សិក្ខាសាលា ដែលបានរៀបចំ | រៀបចំយុទ្ធនាការ វេទិកា (វេទិកាសាធារណៈ វេទិកាតុមូល វេទិកាជជែកពិភាក្សា) និងកម្មវិធីផ្សព្វផ្សាយអំពីការលើកកម្ពស់សមភាពយេនឌ័រ ការចូលរួមរបស់ស្ត្រីក្នុងកិច្ចអភិវឌ្ឍ ភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច នៅថ្នាក់ជាតិនិងក្រោមជាតិ | ក្រសួងកិច្ចការនារី<br>ក្រសួងព័ត៌មាន<br>ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ<br>ក្រសួងមហាផ្ទៃ<br>គជអប<br>ក្រសួងអប់រំ យុវជន និងកីឡា<br>ដៃគូពាក់ព័ន្ធ<br>និងសង្គមស៊ីវិល | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនឯកសារព័ត៌មាន អប់រំ និងទំនាក់ទំនង(IEC) ដែលបានផ្សព្វផ្សាយតាមបណ្តាញផ្សព្វផ្សាយរបស់ក្រសួងកិច្ចការនារី | រៀបចំ និងផ្សព្វផ្សាយឯកសារ និងកម្មវិធីព័ត៌មាន អប់រំ និងទំនាក់ទំនង (IEC) តាមប្រព័ន្ធបច្ចេកវិទ្យាផ្សព្វផ្សាយ និងបណ្តាញទំនាក់ទំនងសង្គម ស្តីពីភាពជាអ្នកដឹកនាំស្ត្រីនិងការគាំទ្រអំពីសមធម៌យេនឌ័រ | ក្រសួងអប់រំ យុវជននិងកីឡា<br>វិទ្យាស្ថានសិក្សាស្រាវជ្រាវ<br>និងបណ្តុះបណ្តាលនានា<br>(សាធារណៈ និងឯកជន)<br>សាកលវិទ្យាល័យ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៤. លើកកម្ពស់ការចូលរួមរបស់យុវជន និងស្ត្រីវ័យក្មេង | ចំនួនកម្មវិធីភាពជាអ្នកដឹកនាំសម្រាប់យុវជន និងស្ត្រីវ័យ | រៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាព និងអនុវត្តន៍គំនិតផ្តួចផ្តើមនានា ក្នុងការ | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ក្នុងភាពជាអ្នកដឹកនាំ និង អភិបាលកិច្ច ដែលឆ្លើយតប នឹងយេនឌ័រ | ក្មេង ដែលបានអនុវត្ត ក្រោម កិច្ចសម្របសម្រួល ដោយ ក្រសួងកិច្ចការនារី<br>ចំនួនយុវជន និងស្ត្រីវ័យក្មេង ដែលចូលរួមក្នុងកម្មវិធីអភិវឌ្ឍ ភាពជាអ្នកដឹកនាំ និងយេនឌ័រ ក្រោមកិច្ចសម្របសម្រួល ដោយក្រសួងកិច្ចការនារី | អភិវឌ្ឍភាពជាអ្នកដឹកនាំ អភិបាលកិច្ច ដែលឆ្លើយតបយេនឌ័រដល់យុវជន និងស្ត្រីវ័យក្មេង (វគ្គបណ្តុះបណ្តាល ការចុះកម្មសិក្សា ការបោះជំរុំ ទស្សន កិច្ចសិក្សា និងតាមមធ្យោបាយ បច្ចេកវិទ្យានានា) | ក្រសួងអប់រំយុវជននិងកីឡា<br>សាកលវិទ្យាល័យ វិទ្យាស្ថានស្រាវជ្រាវ<br>និងដៃគូពាក់ព័ន្ធ និងសង្គមស៊ីវិល | | | | | | | |
| | ចំនួនយុវជន និងស្ត្រីវ័យក្មេង ដែលបានចូលរួមការងារស្ម័គ្រ ចិត្ត ហាត់ការ និងដែលបាន បង្ហាញពីសក្តានុពល ក្នុងការ លើកកម្ពស់សមភាពយេនឌ័រ និងភាពជាអ្នកដឹកនាំ ក្នុងកម្ម វិធីរបស់ក្រសួងកិច្ចការនារី | សម្របសម្រួល និងអនុវត្តកម្មវិធីផ្តល់ ឱកាសដល់យុវជន និងស្ត្រីវ័យក្មេង ចូលរួមធ្វើការស្ម័គ្រចិត្ត និងបង្ហាញពី សក្តានុពល ក្នុងការលើកកម្ពស់ សមភាពយេនឌ័រ និងភាពជាអ្នក ដឹកនាំនៅតាមមូលដ្ឋាន និងស្ថាប័ន | ក្រសួងកិច្ចការនារី ក្រសួង-ស្ថាប័ន ដៃគូពាក់ព័ន្ធ និងសង្គមស៊ីវិល | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនយុទ្ធនាការ/វេទិកាចែក រំលែកបទពិសោធន៍ | យុទ្ធនាការ វេទិកាចែករំលែកបទ ពិសោធន៍ក្នុងភាពជាអ្នកដឹកនាំ និង សមភាពយេនឌ័ររវាងយុវជនជំនាន់ មុន នាបច្ចុប្បន្ន និងជំនាន់ក្រោយ | ក្រសួងកិច្ចការនារី ក្រសួង-ស្ថាប័ន សាកលវិទ្យាល័យ ដៃគូពាក់ព័ន្ធ និងសង្គមស៊ីវិល | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

## យុទ្ធសាស្ត្រទី៦៖ ការបញ្ជ្រាបយេនឌ័រ ក្នុងការប្រែប្រួលអាកាសធាតុ

**គោលបំណង៖** លើកកម្ពស់សមភាពយេនឌ័រ ក្នុងដំណើរការតាក់តែង និងអនុវត្តគោលនយោបាយ និងកម្មវិធីជាតិពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ជាតិ និងក្រោមជាតិ ជាពិសេសក្នុងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានមកលើស្ត្រី កុមារ និងក្រុមជនងាយរងគ្រោះ។

| យុទ្ធសាស្ត្រ | សូចនាករ | សកម្មភាពគន្លឹះ | ដៃគូពាក់ព័ន្ធ | ពេលវេលា (២០១៩-២០២៣) | | | | | ធនធាន | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១៩ | ២០ | ២១ | ២២ | ២៣ | ជាតិ | ដៃគូ |
| ១.ពង្រឹងសមត្ថភាពបច្ចេកទេស និងការគាំទ្រពីថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ការកសាងសមត្ថភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ | -ឯកសារបណ្តុះបណ្តាល ស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតងនិងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ បានរៀបចំនិងធ្វើបច្ចុប្បន្នភាព<br>-ចំនួនអ្នកទទួលផលផ្ទាល់ពីការអនុវត្តសកម្មភាពការកសាងសមត្ថភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតងនិងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ<br>-ចំនួនឯកសារ សម្ភារៈផ្សព្វផ្សាយដែលបានផលិត និងប្រើប្រាស់ ដោយបណ្តាញនិងដៃគូតាមរយៈប្រព័ន្ធផ្សព្វផ្សាយរបស់ក្រសួងកិច្ចការនារី | -រៀបចំឯកសារស្តីពីការវិភាគនិងបញ្ជ្រាបយេនឌ័រ ក្នុងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតងនិងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ (សម្រាប់អ្នកតាក់តែងគោលនយោបាយនិងសាធារណៈជន)<br>-អភិវឌ្ឍសមត្ថភាពពាក់ព័ន្ធយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតងនិងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ<br>-រៀបចំកម្មវិធីបង្កើនការយល់ដឹង និងផ្សព្វផ្សាយតាមប្រព័ន្ធបច្ចេកវិទ្យា និងមធ្យោបាយទំនើបលើការលើកកម្ពស់សមភាពយេនឌ័រក្នុងការឆ្លើយតបការប្រែប្រួល អាកាសធាតុ ការអភិវឌ្ឍបៃតង និងកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ | ក្រសួងកិច្ចការនារី<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍបៃតង<br>ក្រុមការងារបច្ចេកទេសការប្រែប្រួលអាកាសធាតុ<br>គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ<br>ក្រសួងបរិស្ថាន<br>ក្រសួងមហាផ្ទៃ<br>គ.ជ.អ.ប<br>រដ្ឋបាលថ្នាក់ក្រោមជាតិ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ២. បញ្ជ្រាបយេនឌ័រក្នុងដំណើរការតាក់តែងនិងអនុវត្តគោលនយោបាយ កម្មវិធី និង | គោលនយោបាយ កម្មវិធី និងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ | -សម្របសម្រួលនិងគាំទ្របច្ចេកទេសក្នុងការបញ្ចូលបញ្ហាយេនឌ័រទៅក្នុងដំណើរការរៀបចំ និងអនុវត្តគោល | ក្រសួងកិច្ចការនារី<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍបៃតង<br>ក្រុមការងារបច្ចេកទេសការ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ផែនការយុទ្ធសាស្ត្រពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ រួមទាំងតំបន់ជុំវិញបឹងទន្លេសាប និងទន្លេមេគង្គមានភាពប្រសើរឡើង | ការអភិវឌ្ឍបៃតង និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ រួមទាំងតំបន់ជុំវិញទន្លេសាប និងទន្លេមេគង្គដែលឆ្លើយតបនឹងយេនឌ័រ | នយោបាយ កម្មវិធី ផែនការយុទ្ធសាស្ត្រវិស័យពាក់ព័ន្ធអាទិភាព<br>-សហការជាមួយដៃគូអភិវឌ្ឍន៍បង្កើតសូចនាករ ឧបករណ៍ត្រួតពិនិត្យ តាមដាន និងវាយតម្លៃដែលឆ្លើយតបនឹងយេនឌ័រ នៅក្នុងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ | ប្រែប្រួលអាកាសធាតុ<br>អាកាសធាតុ ក្រសួងបរិស្ថាន<br>គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | | | | | | | |
| ៣. គាំទ្រ និងបង្កើតគំនិតផ្តួចផ្តើមនានា ក្នុងការឆ្លើយតបនឹងតម្រូវការជាក់លាក់របស់ស្ត្រី និងក្រុមស្ត្រី ក្មេងស្រីដែលងាយរងគ្រោះ ក្នុងកម្មវិធីប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ | ចំនួនកម្មវិធីជាក់លាក់ ដែលឆ្លើយតបនឹងតម្រូវការស្ត្រី និងក្រុមងាយរងគ្រោះ បានដោះស្រាយនៅក្នុងដំណើរការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ (កិច្ចការដែលស្ថិតនៅក្រោមការសម្របសម្រួល និងដឹកនាំដោយក្រសួងកិច្ចការនារី) | -សិក្សាស្រាវជ្រាវស្វែងរកពីតម្រូវការជាក់លាក់របស់ស្ត្រីនិងក្រុមងាយរងគ្រោះ និងរៀបចំអនុសាសន៍ឆ្លើយតប<br>-គាំទ្រកម្មវិធី គម្រោងគំនិតផ្តួចផ្តើមថ្មីៗ ដែលឆ្លើយតបតម្រូវការជាក់ស្តែងសម្រាប់ស្ត្រីនិងក្រុមងាយរងគ្រោះត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីគ្រប់គ្រងនិងឆ្លើយតបគ្រោះមហន្តរាយ កម្មវិធីប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង | ក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារី<br>គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ<br>ក្រុមការងារបច្ចេកទេសការប្រែប្រួលអាកាសធាតុ<br>ក្រសួងវិស័យពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៤. រៀបចំប្រព័ន្ធគ្រប់គ្រងចំណេះដឹង និងចែករំលែកព័ត៌មាននិងការសិក្សាស្រាវជ្រាវថ្មីៗ ស្តីពីផលប៉ះពាល់យេនឌ័រដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ | ចំនួនសិក្សាស្រាវជ្រាវស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ដែលបានរៀបចំ និងចែករំលែកដោយកកន និងដៃគូអភិវឌ្ឍន៍ | -ភាពជាដៃគូក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទថ្មីៗពាក់ព័ន្ធយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតងនិងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ<br>-រៀបចំយុទ្ធសាស្ត្រ និងវិធីសាស្ត្រ ក្នុងការផលិត ចែករំលែកព័ត៌មានឱ្យបាន | ក្រសួងកិច្ចការនារី<br>គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍបៃតង<br>ក្រុមការងារបច្ចេកទេសការប្រែប្រួលអាកាសធាតុ<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ទូលំទូលាយ ស្របតាមបច្ចេកវិទ្យាទំនើប និងដល់ដៃអ្នកប្រើប្រាស់ | ក្រសួងបរិស្ថាន CDRI, CARDI, RUPPដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ អង្គការសង្គមស៊ីវិល | | | | | | | |

## យុទ្ធសាស្ត្រគាំទ្រស្ថាប័នៈ ការពង្រឹងសមត្ថភាព និងប្រសិទ្ធភាពស្ថាប័ន

**គោលបំណង៖** លើកកម្ពស់សមត្ថភាពរបស់ក្រសួងកិច្ចការនារី និងអង្គភាពចំណុះ ក្នុងការពង្រឹងភាពស្អាតស្អំ លើរដ្ឋបាលសាធារណៈ និងពង្រឹងប្រសិទ្ធភាពក្នុងការពិនិត្យតាមដាន និងវាយតម្លៃ ក្នុងការអនុវត្តការងារ ព្រមទាំងយន្តការគ្រប់គ្រងនិងផ្សព្វផ្សាយព័ត៌មានឱ្យឆ្លើយតបយេនឌ័រ និងបរិយាបន្ន ។

| យុទ្ធសាស្ត្រ | សូចនាករ | សកម្មភាពគន្លឹះ | ដៃគូពាក់ព័ន្ធ | ពេលវេលា (២០១៩-២០២៣) | | | | | ធនធាន | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១៩ | ២០ | ២១ | ២២ | ២៣ | ជាតិ | ដៃគូ |
| **វិចារណកម្មមុខងារ និងភារកិច្ចនិងការអនុវត្តការងារផ្អែកលើលទ្ធផល** | | | | | | | | | | |
| ១. វិចារណកម្មមុខងារ និងភារកិច្ច និងការអនុវត្តការងារផ្អែកលើលទ្ធផល | មន្ត្រីត្រូវបានតែងតាំងនិងសម្រួលភារកិច្ច ស្របតាមជំនាញអតីតភាពការងារ និងកន្លែងទំនេរ | ដំណើរការប្រព័ន្ធវាយតម្លៃ និងធ្វើសំណើសុំតម្លើងឋានៈ និងសម្រួលភារកិច្ចទៅតាមនិតិវិធី និងឋានានុក្រម អនុវត្តតាមលិខិតបទដ្ឋានគតិយុទ្ធ ជាធរមាន | នាយកដ្ឋានរដ្ឋបាល បុគ្គលិក ក្រសួងកិច្ចការនារី ក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ✓ | ✓ | ✓ | ✓ | ✓ | | |
| | ការពិពណ៌នាមុខតំណែង (ថ្នាក់ជាតិ និងក្រោមជាតិ) ត្រូវបានដាក់ឱ្យអនុវត្តន៍ | រៀបចំពិពណ៌នាមុខតំណែងភារកិច្ចរបស់អង្គភាពចំណុះក្រសួង និងតាមមុខតំណែងនីមួយៗ | អន្តរនាយកដ្ឋាន | ✓ | ✓ | ✓ | | | | |
| | អនុក្រឹត្យស្ដីពីការរៀបចំការនិងប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារីត្រូវបានធ្វើវិសោធកម្ម | រៀបចំវិសោធកម្ម និងផ្សព្វផ្សាយ អនុក្រឹត្យ ស្ដីពីការរៀបចំការនិងប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី | អន្តរនាយកដ្ឋាន | ✓ | ✓ | | | | | |
| | របាយការណ៍វឌ្ឍនភាព សេចក្ដីណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងកិច្ចការនារី ផ្ដោតលើការពង្រឹងភាពជាម្ចាស់ ការទទួលខុសត្រូវ និងបន្ទាត់គណនេយ្យភាពច្បាស់លាស់របស់អង្គភាពនីមួយៗ | ពង្រឹងប្រព័ន្ធមុខងារ និងដំណើរការធ្វើអធិការកិច្ច សវនកម្ម ការអនុវត្តវិធានការ និងសេចក្ដីណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងកិច្ចការនារី ក្នុងស្មារតីពង្រឹងភាពជាម្ចាស់ ការទទួលខុសត្រូវ និងបន្ទាត់គណនេយ្យភាពច្បាស់លាស់របស់អង្គភាពនីមួយៗ | អគ្គាធិការដ្ឋាន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ២. អភិវឌ្ឍធនធានមនុស្ស និងនវានុវត្តមុខងាររបស់ស្ថាប័ន និងអង្គភាពចំណុះ | -សមិទ្ធិផលរបស់ក្រសួង ប្រធានបទថ្មីៗ ពាក់ព័ន្ធនឹងការវិវត្តន៍ថ្មីរបស់សង្គម និងជាសាកល បានដាក់បញ្ចូលក្នុងកិច្ចប្រជុំផ្ទៃក្នុងក្រសួង<br>-ចំនួនមន្ត្រីថ្នាក់ជាតិ ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍ ស្ថាប័នពាក់ព័ន្ធបានចូលរួមក្នុងកិច្ចប្រចាំឆ្នាំរបស់ក្រសួងកិច្ចការនារី | រៀបចំកិច្ចប្រជុំផ្ទៃក្នុងក្រសួង និងសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ដែលមានការដាក់បញ្ចូលនូវប្រធានបទថ្មីៗ ដែលមានបច្ចុប្បន្នភាពពាក់ព័ន្ធការវិវត្តថ្មីៗរបស់សង្គម | អន្តរនាយកដ្ឋាន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | មន្ត្រីទទួលបន្ទុករដ្ឋបាល និងមន្ត្រីក្របខណ្ឌថ្មីទាំងថ្នាក់ជាតិ និងក្រោមជាតិ ត្រូវបានអភិវឌ្ឍសមត្ថភាពលើការងារ គ្រប់គ្រងរដ្ឋបាល | អភិវឌ្ឍន៍សមត្ថភាព និងជំនាញគ្រប់គ្រងរដ្ឋបាល ច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល សហលក្ខន្តិកៈដោយឡែក ច្បាប់ លិខិតបទដ្ឋានគតិយុត្តិ ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល | នាយកដ្ឋានរដ្ឋបាល បុគ្គលិក | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | -ក្រុមអង្គភាពអភិវឌ្ឍន៍ធនធានមនុស្ស ក្រសួងកិច្ចការនារី បានបង្កើន ក្រោមក្របខណ្ឌ ក្រុមការងារកំណែទម្រង់រដ្ឋបាលសាធារណៈ<br>-ប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងព័ត៌មានមន្ត្រីរាជការ និងអង្គភាពចំណុះក្រសួងកិច្ចការនារី ដែលបានទទួលកម្មវិធីអភិវឌ្ឍសមត្ថភាពស្របតាមភារកិច្ចរបស់ខ្លួន<br>-ចំនួនវិធានការណ៍ និងកម្មវិធីអភិវឌ្ឍន៍សមត្ថភាព ដែលស្ថិត | -រៀបចំបង្កើតអង្គភាពអភិវឌ្ឍន៍ធនធានមនុស្ស សម្រាប់មន្ត្រីក្រសួងកិច្ចការនារី និងផ្តល់ការអភិវឌ្ឍសមត្ថភាព ឱ្យស្របតាមមុខងាររបស់ស្ថាប័ន និងក្នុងនាមជាអ្នកជំនាញឯកទេស វិភាគ និងបញ្ជ្រាបយេនឌ័រ<br>-សម្របសម្រួល និងគ្រប់គ្រងកម្មវិធីអភិវឌ្ឍន៍សមត្ថភាពមន្ត្រី និងក្រសួងកិច្ចការនារី<br>-រៀបចំ និងដំណើរការប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ និងអង្គភាពដែលទទួលបានកម្មវិធីអភិវឌ្ឍន៍សមត្ថភាពលើការអនុវត្តភារកិច្ចរបស់ខ្លួន | ក្រុមការងារកំណែទម្រង់រដ្ឋបាលសាធារណៈ ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | នៅក្រោមការសម្របសម្រួលរបស់អង្គភាពអភិវឌ្ឍន៍ធនធានមនុស្ស | អភិវឌ្ឍសមត្ថភាពមន្ត្រីថ្មីនូវវគ្គជាកាតព្វកិច្ចសម្រាប់មន្ត្រីក្រសួងកិច្ចការនារី និងអភិវឌ្ឍភាពជាអ្នកដឹកនាំ ដល់ថ្នាក់ដឹកនាំកម្រិតគ្រប់គ្រង | | | | | | | | |
| | ចំនួនកម្មវិធីថ្មីៗ អនុវត្តដោយក្រុមប្រឹក្សាអភិវឌ្ឍយុវជនក្រសួងកិច្ចការនារី | បង្កើន និងដំណើរការក្រុមប្រឹក្សាអភិវឌ្ឍន៍យុវជនក្រសួងកិច្ចការនារី ក្នុងការលើកកម្ពស់យុវជន ក្នុងការចូលរួមក្នុងស្ថាប័ន និងការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ | ក្រុមបណ្តាញមន្ត្រីវ័យក្មេង ក្រុមប្រឹក្សាអភិវឌ្ឍន៍យុវជនក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៣. ពង្រឹកការអនុវត្តកម្មវិធីតុល្យភាពជីវិត គ្រួសារនិងការងារ និងបរិយាកាសមេត្រីភាពឆ្លើយតបនឹងយេនឌ័រនៅកន្លែងការងារ ក្នុងស្ថាប័ន និងអង្គភាពចំណុះ | ចំនួនទារក និងកុមារប្រចាំឆ្នាំ ដែលបានទទួលសេវាពីកម្មវិធីទារកដ្ឋាន<br><br>ចំនួនវិធានការថ្មីៗ ដែលឆ្លើយតបនឹងការគិតគូរដល់តុល្យភាពជីវិត គ្រួសារនិងការងារនៅក្នុងស្ថាប័ន | អភិវឌ្ឍកម្មវិធីទារកដ្ឋាន ក្នុងការមើលថែទាំទារកនិងកុមារតូចៗ សម្រាប់ជួយសម្រាលបន្ទុកដល់មន្ត្រី ដើម្បីមានឱកាសនិងពេលវេលាក្នុងការបំពេញតួនាទីនិងភារកិច្ចឱ្យកាន់តែមានប្រសិទ្ធភាព | នាយកដ្ឋានរដ្ឋបាល បុគ្គលិក នាយកដ្ឋានស្ត្រីនិងការអប់រំ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | | បណ្តុះបណ្តាល និងដាក់វិធានការ ក្នុងការទប់ស្កាត់ផ្នត់គំនិតអវិជ្ជមានពាក់ព័ន្ធនឹងយេនឌ័រ ក្នុងស្ថាប័ន | នាយកដ្ឋានរដ្ឋបាល បុគ្គលិក | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | | កម្មវិធីលើកទឹកចិត្ត និងភ្ជាប់ទំនាក់ទំនងជាមួយមន្ត្រីចូលនិវត្តន៍ | នាយកដ្ឋានរដ្ឋបាល បុគ្គលិក ក្រុមបណ្តាញមន្ត្រីវ័យក្មេង អង្គភាពពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | | រៀបចំនិងអនុវត្តវិធានការថ្មីៗ ដែលឆ្លើយតបនឹងការគិតគូរដល់តុល្យភាពជីវិត គ្រួសារនិងការងារនៅក្នុងស្ថាប័ន | នាយកដ្ឋានរដ្ឋបាល បុគ្គលិក អន្តរនាយកដ្ឋាន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៤.ពង្រឹងប្រព័ន្ធរៀបចំផែនការ ស្ថិតិ តាមដាន និង | ប្រព័ន្ធរៀបចំផែនការ ស្ថិតិ តាមដាន និងវាយតម្លៃផ្អែកលើលទ្ធ | រៀបចំ និងដាក់ឱ្យដំណើរការប្រព័ន្ធផែនការអនុវត្ត ស្ថិតិ និងពិនិត្យតាម | ក្រសួង/មន្ទីរកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| វាយតម្លៃផ្អែកលើលទ្ធផលការងារ | ផលការងារត្រូវបានពង្រឹងប្រកបដោយគុណភាពនិងប្រសិទ្ធភាព | ដាននិងវាយតម្លៃ ផ្អែកលើលទ្ធផលដែលមានគុណភាព នៃការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ | | | | | | | | |
| | | បង្កើត និងដំណើរការក្រុមការងារតាមដាន និងវាយ តម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ | ក្រសួង/មន្ទីរកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ជាតុចូលការលើកកម្ពស់សមភាពយេនឌ័រ ត្រូវបានបញ្ចូលក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ កម្មវិធី និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា | រៀបចំធាតុចូល និងសមិទ្ធផលទាក់ទងការលើកកម្ពស់សមភាពយេនឌ័រនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ( NSDP 2019-2023 ) ផែនការសកម្មភាព គោលនយោបាយប្រជាជន និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា | ក្រសួងកិច្ចការនារី និងក្រសួងពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | | រៀបចំកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិលទាក់ទងការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី | ក្រសួងកិច្ចការនារី និងក្រសួងពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | សមត្ថភាពមន្ត្រីកិច្ចការនារីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការ ស្ថិតិ តាមដានត្រួតពិនិត្យ និងវាយតម្លៃនិងផ្តល់អនុសាសន៍ ក្នុងគោលនយោបាយ ផែនការ កម្មវិធីឆ្លើយតបយេនឌ័រមានការកើនឡើង | ពង្រឹងសមត្ថភាពមន្ត្រីកិច្ចការនារី ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិស្តីពីការរៀបចំផែនការ ស្ថិតិ និងការត្រួតពិនិត្យនិងវាយតម្លៃឆ្លើយតបយេនឌ័រ (រួមទាំងការប្រមូល វិភាគ ចងក្រង ផលិត ផ្សព្វផ្សាយ និងការតាក់តែងគោលនយោបាយ | ក្រសួង/មន្ទីរកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ស្ថិតិយេនឌ័រសំខាន់ៗ ត្រូវបានប្រមូល ចងក្រង បោះពុម្ព និងផ្សព្វផ្សាយ | ធ្វើបច្ចុប្បន្នភាពខិតប័ណ្ណ និងសៀវភៅស្ថិតិយេនឌ័រសំខាន់ៗនៅកម្ពុជា និងផ្សព្វផ្សាយ | ក្រសួង/មន្ទីរកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ការអង្កេតនានាឆ្លើយតបនឹងយេនឌ័រ | សិក្សា និងចងក្រងនូវអង្កេតជាតិនានាដែលឆ្លើយតបនឹងយេនឌ័រ<br>បញ្ចូលទស្សនៈយេនឌ័រទៅក្នុងកម្រងសំណួរនៃការអង្កេតនានា | ក្រសួងកិច្ចការនារី<br>ក្រសួងផែនការ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនឯកសារនិងការសិក្សាស្រាវជ្រាវថ្មីៗដែលអាចបម្រើដល់មហាជនក្នុងមណ្ឌលព័ត៌មាននិងបណ្ណាល័យនានាដែលជាជំនួយរបស់ក្រសួង | ធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងនិងចែករំលែកព័ត៌មាន ការសិក្សាពាក់ព័ន្ធនឹងយេនឌ័រនិងស្ថានភាពស្ត្រីក្នុងមណ្ឌលព័ត៌មានក្រសួងកិច្ចការនារីនិងភាពជាដៃគូជាមួយវិទ្យាស្ថានស្រាវជ្រាវនិងគ្រឹះស្ថានសិក្សានានា | ក្រសួងកិច្ចការនារី<br>វិទ្យាស្ថានស្រាវជ្រាវន<br>គ្រឹះស្ថានសិក្សាអប់រំ ពីដៃគូនានា | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៥. ពង្រឹងយន្តការសម្របសម្រួល ប្រាស្រ័យទាក់ទង និងគ្រប់គ្រងព័ត៌មាន ផ្សព្វផ្សាយតាមប្រព័ន្ធទំនើប និងស្របតាមបរិបទសង្គម | ចំនួនប្រព័ន្ធផ្ទៃក្នុង ក្នុងការគ្រប់គ្រង និងចែករំលែកព័ត៌មានរបស់ក្រសួងកិច្ចការនារី បានរៀបចំ និងកំពុងដំណើរការ | អភិវឌ្ឍ និងដំណើរការប្រព័ន្ធផ្ទៃក្នុងការគ្រប់គ្រង និងចែករំលែកព័ត៌មានតាមប្រព័ន្ធបច្ចេកវិទ្យាទំនើបរបស់ក្រសួងកិច្ចការនារីនៅថ្នាក់ជាតិ និងក្រោមជាតិ | នាយកដ្ឋានព័ត៌មាន<br>នាយកដ្ឋានរដ្ឋបាល បុគ្គលិក<br>នាយកដ្ឋានផែនការនិងស្ថិតិ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | -ចំនួនសមាជិកទំព័របណ្តាញសង្គមក្រសួងកិច្ចការនារី មានកើនឡើង | -ពង្រឹងសមត្ថភាព និងដំណើរការក្រុមការងារអន្តរនាយកដ្ឋានការងារគ្រប់គ្រងបណ្តាញសង្គមក្រសួងកិច្ចការនារី<br>-ពង្រឹងគ្រប់គ្រង និងអភិវឌ្ឍន៍ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់ក្រសួងកិច្ចការនារី ជាពិសេសតាមរយៈប្រព័ន្ធបច្ចេកវិទ្យាឌីជីថល និងមធ្យោបាយទំនើប | នាយកដ្ឋានព័ត៌មាន<br>នាយកដ្ឋានរដ្ឋបាល បុគ្គលិក<br>ក្រុមអន្តរនាយកដ្ឋានការងារបណ្តាញសង្គម | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | -ចំនួនសម្ភារៈ និងកម្មវិធីផ្សព្វផ្សាយ ដោយផ្អែកលើគោលនយោបាយជាតិ ស្តីពីសមភាពយេនឌ័រ និងផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ | ផលិតព័ត៌មាន និងសម្ភារៈផ្សព្វផ្សាយ ដោយផ្អែកលើគោលនយោបាយជាតិ ស្តីពីសមភាពយេនឌ័រ និងផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ តាមប្រព័ន្ធបច្ចេកវិទ្យា និងមធ្យោបាយ ដែលឆ្លើយតបតម្រូវការសង្គម | នាយកដ្ឋានព័ត៌មាន<br>ក្រុមអន្តរនាយកដ្ឋានការងារបណ្តាញសង្គម<br>ដៃគូ ឬស្ថាប័ន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | -ចំនួនព្រឹត្តិការណ៍ និងសកម្មភាពជួបពិភាក្សាជាមួយនឹងបណ្តាញអ្នកសារព័ត៌មាន ក្នុងការពិភាក្សាលើការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងលើកកម្ពស់សមភាពយេនឌ័រ<br>-ចំនួនអ្នកចូលរួមក្នុងកម្មវិធីអភិវឌ្ឍសមត្ថភាពស្តីពីយេនឌ័រជាមួយអ្នកសារព័ត៌មាន ដែលស្ថិតនៅក្រោមក្របខណ្ឌរបស់ក្រសួងកិច្ចការនារី | ពង្រឹងទំនាក់ទំនង និងអភិវឌ្ឍសមត្ថភាពដល់បណ្តាញសារព័ត៌មាន និងគ្រឹះស្ថានបណ្តុះបណ្តាលអ្នកផ្សព្វផ្សាយ និងព័ត៌មានក្នុងការលើកកម្ពស់សមភាពយេនឌ័រ | នាយកដ្ឋានព័ត៌មាន<br>ក្រុមអន្តរនាយកដ្ឋានការងារបណ្តាញសង្គម<br>ក្លឹបអ្នកសារសែត<br>ដៃគូ ឬស្ថាប័ន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលធ្វើឱ្យប៉ះពាល់ដល់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ បានរកឃើញក្នុងសារព័ត៌មាន ដោយក្រុមការងារក្រសួងកិច្ចការនារី និងចំនួនដែលបានឆ្លើយតបទាន់ពេលវេលា | តាមដានព័ត៌មានប្រចាំ តាមរយៈប្រព័ន្ធផ្សព្វផ្សាយគ្រប់រូបភាពលើករណីអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដែលធ្វើឱ្យប៉ះពាល់ដល់សីលធម៌សង្គមនិងតម្លៃស្ត្រី និងលើកកម្ពស់ការអនុវត្តក្រមប្រតិបត្តិរាយការណ៍ករណីអំពើហិង្សាលើស្ត្រី និងឆ្លើយតបឱ្យបានសមស្របទាន់ពេលវេលា | នាយកដ្ឋានព័ត៌មាន<br>នាយកដ្ឋានការពារផ្លូវច្បាប់<br>គណៈកម្មាការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ<br>ក្រសួងព័ត៌មាន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៦. ពង្រឹងយន្តការក្នុងការពង្រីកកិច្ចសហប្រតិបត្តិការ | ចំណេះដឹងរបស់មន្ត្រីរាជការកិច្ចការនារីស្តីពីការទំនាក់ទំនង | ពង្រឹងសមត្ថភាពមន្ត្រីកិច្ចការនារី ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្តីពីការងារ | ក្រសួង មន្ទីរកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ថ្នាក់ជាតិ ថ្នាក់តំបន់និងសកលនិងភាពជាដៃគូរជាមួយវិស័យឯកជន ដើម្បីលើកកម្ពស់និងកិច្ចការពារសិទ្ធិស្ត្រីនិងកុមារ។ | អន្តរជាតិកើនឡើង | ស្ត្រីនិងអាស៊ាន និងសារៈសំខាន់ នៃការធ្វើលិខិតគាំទ្រ ដើម្បីចុះកិច្ចព្រមព្រៀងជាមួយដៃគូអភិវឌ្ឍន៍ | | | | | | | | |
| | | អភិវឌ្ឍសមត្ថភាពស្តីពីទំនាក់ទំនងអន្តរជាតិ និងខ្លឹមសារលិខិតបទដ្ឋានគតិយុត្តិអន្តរជាតិសំខាន់ៗ | ក្រសួង មន្ទីរកិច្ចការនារី | √ | √ | √ | √ | √ | √ | √ |
| | អនុស្សរណៈនៃការយល់យោគគ្នារវាងក្រសួងកិច្ចការនារី ជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងដៃគូពាក់ព័ន្ធ ប្រកបដោយប្រសិទ្ធភាព ក្រោមក្របខណ្ឌនារីរតនៈទី៥ | សម្របសម្រួល ក្នុងការរៀបចំឯកសារស្នើសុំចុះអនុស្សរណៈរបស់អង្គការដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិ និងវិស័យឯកជនជាមួយក្រសួងកិច្ចការនារី | ក្រសួង មន្ទីរកិច្ចការនារី អង្គការពាក់ព័ន្ធ វិស័យឯកជន | √ | √ | √ | √ | √ | √ | √ |
| | | ចុះតាមដាន និងវាយតម្លៃលើការអនុវត្តអនុស្សរណៈ ដែលបានចុះកិច្ចព្រមព្រៀងរវាងក្រសួងកិច្ចការនារី និងដៃគូពាក់ព័ន្ធ | ក្រសួង មន្ទីរកិច្ចការនារី អង្គការពាក់ព័ន្ធ វិស័យឯកជន | √ | √ | √ | √ | √ | √ | √ |
| | កិច្ចសហប្រតិបត្តិការថ្នាក់ជាតិ ថ្នាក់តំបន់និងសកល ក្នុងការលើកកម្ពស់ស្ថានភាព និងការពារសិទ្ធិស្ត្រីនិងកុមារមានភាពប្រសើរជាលំដាប់។ | រៀបចំ និងចូលរួមអនុវត្តតាមផែនការយុទ្ធសាស្ត្ររបស់គណៈកម្មាធិការអាស៊ានស្តីពីស្ត្រី (ACW) និងគណៈកម្មការអាស៊ានស្តីពីការលើកកម្ពស់និងការពារសិទ្ធិស្ត្រីនិងកុមារ (ACWC) | ក្រសួងកិច្ចការនារី ប្រទេសក្នុងតំបន់ និងសកល | √ | √ | √ | √ | √ | √ | √ |
| | | ពង្រឹងកិច្ចសហការរបស់នាយកដ្ឋានជំនាញក្នុងការផ្តល់ធាតុចូលលើឯកសារអន្តរជាតិពាក់ព័ន្ធកិច្ចការនារី | អន្តរនាយកដ្ឋាន | √ | √ | √ | √ | √ | √ | √ |
| | | ពង្រឹងកិច្ចសហការរៀបចំរបាយការណ៍ជាតិពាក់ព័ន្ធកិច្ចការនារី និងសមភាពយេនឌ័រ ស្របតាមកាតព្វកិច្ច | អន្តរនាយកដ្ឋាន | √ | √ | √ | √ | √ | √ | √ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | របស់រដ្ឋនិងចែករំលែកក្នុងព្រឹត្តិការណ៍និងកិច្ចប្រជុំអន្តរជាតិពាក់ព័ន្ធ | | | | | | | | |
| ៧. ពង្រឹងសមត្ថភាពនិងប្រសិទ្ធភាពស្ថាប័នក្នុងការឆ្លើយតបប្រកបដោយបរិយាបន្ន ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ | -ក្រុមការងារទទួលបន្ទុកឆ្លើយតបក្រុមងាយរងគ្រោះជាស្ត្រី និងក្មេងស្រីប្រកបដោយបរិយាបន្ន បានបង្កើត និងប្រជុំជាទៀតទាត់<br>-ក្របខណ្ឌយុទ្ធសាស្ត្រ និងឧបករណ៍ ក្នុងការឆ្លើយតបបញ្ហាបរិយាប័ន្នរបស់ក្រុមស្ត្រី និងក្មេងស្រីងាយរងគ្រោះ នៅតាមអង្គភាព និងនាយកដ្ឋានក្រសួងកិច្ចការនារី | -បង្កើត និងដំណើរការក្រុមការងារទទួលបន្ទុកឆ្លើយតបក្រុមងាយរងគ្រោះជាស្ត្រី និងក្មេងស្រីប្រកបដោយបរិយាបន្ន<br>-រៀបចំ និងជំរុញការអនុវត្តក្របខណ្ឌយុទ្ធសាស្ត្ររបស់ក្រុមការងារ និងឧបករណ៍ឆ្លើយតបប្រកបដោយបរិយាប័ន្ននៅតាមអង្គភាព និងនាយកដ្ឋានក្រសួងកិច្ចការនារី | ក្រុមការងារ ទទួលបន្ទុកឆ្លើយតបក្រុមងាយរងគ្រោះជាស្ត្រី និងក្មេងស្រីប្រកបដោយបរិយាបន្ន | √ | √ | √ | √ | √ | √ | √ |
| | ចំនួនកើនឡើងនៃមន្ត្រីរាជការជាស្ត្រី ដែលមានពិការភាព | ជំរុញការអនុវត្តគោលការណ៍នានាក្នុងការជ្រើសរើសនិងគាំទ្រដល់ការជ្រើសរើសមន្ត្រីដែលមានពិការភាព | ក្រុមការងារសកម្មភាពជនពិការ ក្រសួងកិច្ចការនារី | √ | √ | √ | √ | √ | √ | √ |
| | ចំនួនវិធានការដាក់លាក់ដែលឆ្លើយតបការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពពាក់ព័ន្ធយេនឌ័ររបស់ក្រសួងកិច្ចការនារី | រៀបចំ និងដំណើរការយន្តការ និងឧបករណ៍ ក្នុងការបញ្ជូលបញ្ហាពិការភាពទៅក្នុងការងាររបស់អង្គភាព និងនាយកដ្ឋានជំនាញ | ក្រុមការងារសកម្មភាពជនពិការ ក្រសួងកិច្ចការនារី | √ | √ | √ | √ | √ | √ | √ |
| | ចំនួនកម្មវិធីអភិវឌ្ឍសមត្ថភាពស្តីពីយេនឌ័រ និងបញ្ហាពិការដល់មន្ត្រីក្រសួងកិច្ចការនារី និងដៃគូ ក្នុងលទ្ធភាពដើម្បីឈានទៅអនុវត្តយុទ្ធសាស្ត្រលើកកម្ពស់សមភាពយេនឌ័រនិង | អភិវឌ្ឍសមត្ថភាពស្តីពីយេនឌ័រ និងបញ្ហាពិការ ដល់មន្ត្រីក្រសួងកិច្ចការនារី និងដៃគូពាក់ព័ន្ធ ក្នុងលទ្ធភាពដើម្បីឈានទៅអនុវត្តយុទ្ធសាស្ត្រលើកកម្ពស់សមភាពយេនឌ័រក្នុងពិការភាពនិងភាពអង់អាចរបស់ស្ត្រី និង | ក្រុមការងារសកម្មភាពជនពិការ ក្រសួងកិច្ចការនារី | √ | √ | √ | √ | √ | √ | √ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ភាពអង់អាចរបស់ស្ត្រី និងក្មេងស្រីមានភាពពិការ | ក្មេងស្រីមានភាពពិការ | | | | | | | | |
| ៨. អនុវត្តកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាល ក្នុងការបង្កើនប្រសិទ្ធភាពការងាររបស់ស្ថាប័ន | មន្ត្រីថ្នាក់ជាតិ និងក្រោមជាតិត្រូវបានតម្លើងថ្នាក់និងឋានន្តរស័ក្តិ | រៀបចំវាយតម្លៃ និងដាក់ឱ្យមន្ត្រីឡើងឋានន្តរស័ក្តិ ថ្នាក់តាមវេន អតីតភាពការងារ កម្រិតសញ្ញាបត្រ និងគ្រឿងឥស្សរិយយស | អន្តរនាយកដ្ឋាន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានប្រកាសដាក់ឱ្យចូលនិវត្តន៍ | រៀបចំលិខិតបញ្ជាក់អតីតភាពប្រវត្តិការងារ និងប្រកាសដាក់ឱ្យមន្ត្រីថ្នាក់ជាតិ និងក្រោមជាតិ ចូលនិវត្តន៍ទៅតាមអតីតភាពការងារដែលត្រូវចូលនិវត្តន៍ និងតាមការស្មគ្រ័ចិត្ត | អន្តរនាយកដ្ឋាន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | មន្ត្រីថ្មីត្រូវបានចូលបំរើការងារក្នុងក្របខណ្ឌក្រសួងកិច្ចការនារី | រៀបចំផែនការជ្រើសរើសមន្ត្រី និងដំណើរការជ្រើសរើសនិស្សិត មន្ត្រីជាប់កិច្ចសន្យា និងមន្ត្រីរាជការឱ្យចូលបំរើការងារក្របខណ្ឌក្រសួងកិច្ចការនារី | នាយកដ្ឋានរដ្ឋបាល បុគ្គលិក | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | ចំនួនមន្ត្រីនិងប្រភេទមុខងាររបស់ក្រសួងកិច្ចការនារី ដែលបានផ្ទេរនិងអនុវត្ត ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយប្រសិទ្ធភាព ក្រោមក្របខណ្ឌការងាររបស់កម្មវិធីវិមជ្ឈការនិងវិសហមជ្ឈការ | រៀបចំគោលការណ៍ និងអនុវត្តវិធានការ គាំទ្រដល់ការផ្ទេរមុខងាររបស់ក្រសួងកិច្ចការនារី ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រោមក្របខណ្ឌការងារវិមជ្ឈការនិងវិសហមជ្ឈការ | អន្តរនាយកដ្ឋាន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ផែនការសកម្មភាពរួមដំណាក់កាលទី៣ និងទី៤ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | កិច្ចប្រជុំសម្របសម្រួលរៀបចំជាមួយក្រុមការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងនាយកដ្ឋានពាក់ព័ន្ធ ដើម្បីរៀបចំផែនការសកម្ម | ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងកិច្ចការនារី អង្គភាពថវិកា នៃក្រសួងកិច្ច | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | របាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ | ភាពរួមដំណាក់កាលទី៣ និងទី៤ | ការនារី | | | | | | | |
| | ចំនួនមន្ត្រីដែលមានសមត្ថភាពរៀបចំថវិកាឆ្លើយតបនឹងផែនការយុទ្ធសាស្ត្រនារីរតនៈ | សហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីក្រសួងកិច្ចការនារី ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការរៀបចំថវិកា ស្របតាមគោលនយោបាយ និងឆ្លើយតបនឹងយេនឌ័រ | ក្រសួងកិច្ចការនារី<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនមន្ត្រីដែលមានចំណេះដឹង និងប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) បានល្អ | ចូលរួមក្នុងកម្មវិធីអភិវឌ្ឍសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីប្រព័ន្ធព័ត៌មានវិទ្យា ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) | នាយកដ្ឋានហិរញ្ញវត្ថុនិងផ្គត់ផ្គង់<br>អង្គភាពលទ្ធកម្ម | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |

# ផ្នែកទី៦

## ធនធានហិរញ្ញវត្ថុ

ការអនុវត្តផែន**ការយុទ្ធសាស្ត្រនារីរតនៈទី៥** ពឹងផ្អែកលើធនធានពីរសំខាន់ៗ គឺថវិការដ្ឋ និងការចូលរួមចំណែកពីដៃគូពាក់ព័ន្ធ ។

តម្លៃប៉ាន់ស្មានតម្រូវការជាក់ស្តែង ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ នឹងមានកំណត់នៅក្នុងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំ និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់ក្រសួងកិច្ចការនារី ។ ដោយការងារលើកកម្ពស់សមភាពយេនឌ័រ គឺជារបៀបវារៈអន្តរវិស័យរបស់រាជរដ្ឋាភិបាល ការប៉ាន់ប្រមាណតម្រូវការធនធានសរុប សម្រាប់អនុវត្តន៍ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ មិនបានរាប់បញ្ចូលនូវថវិកាដែលឆ្លើយតបយេនឌ័រតាមវិស័យពាក់ព័ន្ធ។

ការប៉ាន់ស្មាននេះបានធ្វើឡើង តាមវិស័យនិងកម្មវិធីជាយុទ្ធសាស្ត្រនីមួយៗ ដូចខាងក្រោម៖

| ក្របខណ្ឌយុទ្ធសាស្ត្រនីមួយៗ | ប្រភពមូលនិធិ[3] |
|---|---|
| **ការបញ្ជ្រាបយេនឌ័រ** | ថវិកាជាតិ, UNDP, UNW, Sida, JICA, DFAT, UNFPA និងដៃគូផ្សេងទៀត |
| ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី | ថវិកាជាតិ រួមជាមួយ, UNDP, JICA, UN-ESCAP, Oxfam, WEDU, APHEDA និងដៃគូផ្សេងទៀត |
| ការអប់រំស្ត្រីនិងក្មេងស្រី | ថវិកាជាតិ រួមជាមួយ UNICEF, UNSCO, ACTION AID, SAVE THE CHILDREN, World Bank, PLAN INTERNATIONAL, UNDP និងដៃគូផ្សេងទៀត |
| ការលើកកម្ពស់សុខភាពសម្រាប់ស្ត្រីនិងកុមារី | ថវិកាជាតិ រួមជាមួយ Fred Hollow Foundation, Global Fund, UNFPA, UN Women និងដៃគូផ្សេងទៀត |
| កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងកុមារី | ថវិកាជាតិ រួមជាមួយ UN Women, UNFPA, UNICEF DFAT, Care International និងដៃគូផ្សេងទៀត |
| ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេច | ថវិកាជាតិ រួមជាមួយនឹង UNDP, UNFPA, Oxfam, SIDA, UN Women និងដៃគូផ្សេងទៀត |
| ការបញ្ជ្រាបយេនឌ័រ ក្នុងកម្មវិធីប្រែប្រួលអាកាសធាតុ | ថវិការដ្ឋ រួមជាមួយនឹង ADB, EU, SIDA, UNDP, GEF, UN Women, FAO និងដៃគូផ្សេងទៀត |
| ការពង្រឹងស្ថាប័ននិងសមត្ថភាព | ថវិកាជាតិ រួមជាមួយដៃគូអភិវឌ្ឍ ទាំងអស់ដែលគាំទ្រដល់ក្រសួងកិច្ចការនារី ជាពិសេស UNDP, SIDA, UNFPA, UN Women, JICA, GIZ |

[3] នៅក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ក្រុមការងាររៀបចំបានទទួលព័ត៌មានអំពីប្រភពធនធានដែលមានសក្តានុពល តាមវិស័យ និងកម្មវិធីនីមួយៗ ។ ក្រសួងកិច្ចការនារី នឹងបន្តស្វែងរកការគាំទ្រពីប្រភពផ្សេងទៀត នៅក្នុងពេលដំណើរការអនុវត្ត ។

# ផ្នែកទី៧

# ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ

## ការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ

ដោយផ្អែកលើផែនការយុទ្ធសាស្ត្រ**នារីរតនៈទី៥** ក្នុងការចូលរួម និងសម្របសម្រួលក្នុងការអនុវត្ត **គោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ** ក្រសួងកិច្ចការនារី ក្នុងភាពជាដៃគូ ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធនិងដៃគូអភិវឌ្ឍន៍ នឹងរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ ដោយស្របតាមអណត្តិ និងភារកិច្ចដែលកំណត់ដោយច្បាប់។ កិច្ចការនេះនឹងដំណើរការតាមរយៈភាពជាដៃគូ ក្នុងក្របខណ្ឌក្រុមការងារបច្ចេកទេសយេនឌ័រ និងដៃគូពាក់ព័ន្ធ ដោយមាននាយកដ្ឋានផែនការនិងស្ថិតិ ក្រសួងកិច្ចការនារីជាសេនាធិការ ។ ការរៀបចំនិងពិនិត្យឡើងវិញនូវផែនការសកម្មភាពប្រចាំឆ្នាំ ធ្វើឡើងនៅអំឡុងចុងនិងដើមឆ្នាំនីមួយៗ ដោយផ្អែកលើផែនការយុទ្ធសាស្ត្រនេះ ជាមួយគោលនយោបាយ និងកម្មវិធីនានា និងស្របតាមស្ថានភាពជាក់ស្តែង។ ម្យ៉ាងវិញទៀត ក្រសួងកិច្ចការនារី នឹងដើរតួជាអ្នកសម្របសម្រួលក្នុងដំណើរការនេះ តាមរយៈការរៀបចំកិច្ចប្រជុំបូកសរុបប្រចាំឆ្នាំ និងលើកផែនការបន្ត ។

## ការត្រួតពិនិត្យ និងតាមដាន

ដោយផ្អែកលើសូចនាករដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រនេះ ផែនការសកម្មភាពប្រចាំឆ្នាំ និងរបាយការណ៍ប្រចាំឆ្នាំ ក្រសួងកិច្ចការនារី ក្នុងភាពជាដៃគូជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ នឹងធ្វើការត្រួតពិនិត្យឡើងវិញនូវការរីកចម្រើន ក្នុងរយៈពេលខ្លី និងមធ្យម។

ក្រសួងកិច្ចការនារី ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងក្រុមការងារបច្ចេកទេសយេនឌ័រ នឹងសម្របសម្រួល ក្នុងការរៀបចំរបាយការណ៍រីកចម្រើនលើការលើកកម្ពស់សមភាពយេនឌ័រ និងការបញ្ជ្រាបយេនឌ័រជាប្រចាំ ដើម្បីចែករំលែកដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងថ្នាក់ក្រោមជាតិ ព្រមទាំងដៃគូអភិវឌ្ឍន៍។ ដូចនេះ ការត្រួតពិនិត្យ និងតាមដាននូវការរីកចម្រើនលើការអនុវត្តយុទ្ធសាស្ត្រ**នារីរតនៈទី៥** ក៏ត្រូវផ្សារភ្ជាប់នៅក្នុងរបាយការណ៍ទាំងនោះផងដែរ ។

## ការវាយតម្លៃ

ដើម្បីពិនិត្យលើប្រសិទ្ធភាព និងភាពសក្តិសិទ្ធិនៃការអនុវត្ត**ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥** ក្រសួងកិច្ចការនារីនិងដៃគូពាក់ព័ន្ធនឹងរៀបចំការវាយតម្លៃពាក់កណ្តាលអាណត្តិ និងសន្និបាតជាតិបូកសរុបលទ្ធផលការអនុវត្ត**ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥**។ រាល់ដៃគូពាក់ព័ន្ធនឹងចូលរួមយ៉ាងទូលំទូលាយក្នុងការវាយតម្លៃលទ្ធផលការងារទាំងនេះ និងលើកទិសដៅបន្ត។

សន្និបាតជាតិបូកសរុបលទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រ**នារីរតនៈទី៥** នឹងរៀបចំឡើងនៅពេលបញ្ចប់អាណត្តិនៃផែនការយុទ្ធសាស្ត្រ**នារីរតនៈទី៥** តាមរយៈការចូលរួមពីភ្នាក់ងារអនុវត្ត និងដៃគូពាក់ព័ន្ធ ដើម្បីបូកសរុបអំពីលទ្ធផលដែលបានអនុវត្ត និងជាមួយនូវផលប៉ះពាល់ជាវិជ្ជមាននៃផែនការយុទ្ធសាស្ត្រនេះ។ ចំណុចសំខាន់ដែលអាចផ្ទៀងផ្ទាត់អំពីលទ្ធផលនៃការសម្រេចនេះ តាមរយៈការធ្វើបច្ចុប្បន្នកម្មនៃការ ប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា និងពិនិត្យលើការសម្រេចនូវចំណុចដៅ នៃសូចនាករសំខាន់ៗដែលពាក់ព័ន្ធនឹងការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ។

*ក្រសួងកិច្ចការនារី* នឹងបង្កើតក្រុមការងារតាមដាននិងវាយតម្លៃ និងរៀបចំក្របខណ្ឌតាមដាន និងវាយតម្លៃនៃ**ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥** ដែលមានគូសបញ្ជាក់អំពីតួនាទីរបស់ក្រសួងកិច្ចការនារី និងក្រសួង-ស្ថាប័នពាក់ព័ន្ធ។ នៅក្នុងន័យនេះ តាមការរៀបចំនិងដាក់ឱ្យដំណើរការក្របខណ្ឌតាមដាន និងវាយតម្លៃ គឺជាអភិក្រមនិងកិច្ចការចាំបាច់មួយរបស់**នារីរតនៈទី៥** ក្នុងការពង្រឹងស្ថាប័នរបស់ក្រសួងកិច្ចការនារី ក្នុងការរៀបចំប្រព័ន្ធ និងដំណើរការប្រព័ន្ធតាមដាន និងវាយតម្លៃ ជាពិសេសលើការគ្រប់គ្រងការងារ ដែលផ្អែកតាមលទ្ធផល។ ការសិក្សា និងរៀបចំឱ្យទិន្នន័យមូលដ្ឋាន និងការកំណត់ចំណុចដៅជាក់លាក់សម្រាប់សូចនាករ ដែលមាននៅក្នុងតារាងផែនការសកម្មភាព៥ឆ្នាំ (២០១៩-២០២៣) របស់ក្រសួងកិច្ចការនារី ក៏ត្រូវគិតគូរនិងដាក់បញ្ចូលក្នុងក្របខណ្ឌ។ ក្នុងករណីចាំបាច់ សូចនាករនៅក្នុងតារាងសកម្មភាពនេះ ក៏អាចនឹងកែសម្រួល ឬកំណត់ថ្មី តាមលទ្ធភាពសមស្រប ។

ជាមួយគ្នានេះ ដើម្បីឱ្យស៊ីចង្វាក់គ្នាជាមួយនឹងការចង្អុលបង្ហាញ ក្នុងការអនុវត្តគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ ដែលនឹងអនុម័តនាពេលខាងមុខនេះ ក្រសួងកិច្ចការនារី ត្រូវសហការជាមួយនឹងអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្នុងការរៀបចំនិងអនុវត្តការងារតាមដាន និងវាយតម្លៃរបស់គោលនយោបាយជាតិ និងចូលរួមជាមួយក្រសួង-ស្ថាប័ន ក្នុងការពង្រឹងសមត្ថភាព និងប្រព័ន្ធតាមដានតាមវិស័យ ឱ្យឆ្លើយតបនឹងគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ ព្រមទាំងសូចនាករជាតិ និងតាមវិស័យសំខាន់ៗ។

ការអនុវត្ត**ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥** នឹងចូលរួមក្នុងសម្រេចតាមសូចនាករជាតិ សំខាន់ៗ ក៏ដូចមានកំណត់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា និងសូចនាករ តាមវិស័យសំខាន់ៗ ដូចខាងក្រោម៖

## សូចនាករតាមដានត្រួតពិនិត្យសំខាន់ៗ ២០១៩-២០២៣

| | សូចនាករជាតិ និងតាមវិស័យគន្លឹះៗ | ឯកតា | ស្ថានភាព | ចំណុចដៅ | | | | | ប្រភពទិន្នន័យ និងព័ត៌មាន |
|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| **ការបញ្ជ្រាបយេនឌ័រ** | | | | | | | | | |
| ១. | គោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ បានអនុម័ត ដោយរាជរដ្ឋាភិបាល | ចំនួន | ០ | | ១ | | | | ទីស្តីការគណៈរដ្ឋមន្ត្រី |
| ២. | ចំនួនច្បាប់ គោលនយោបាយ និងក្របខណ្ឌគតិយុត្តសម្រាប់លើកកម្ពស់ការអនុវត្ត និងតាមដានត្រួតពិនិត្យការលើកកម្ពស់សមភាពយេនឌ័រ និងការមិនរើសអើងភេទ | ចំនួន | ៥០ | | | | | ៥៥ | គោលដៅអភិវឌ្ឍប្រកបដោយ ចីរភាព |
| ៣. | ឯកសារប៉ាន់ប្រមាណយេនឌ័រតាមវិស័យបានរៀបចំ និងផ្សព្វផ្សាយ | ចំនួន | ៣ | | ៤ | | | | ក្រសួងកិច្ចការនារី |
| ៤. | ក្រសួង-ស្ថាប័នដែលមានប្រព័ន្ធតាមដាននិងវិភាជន៍ថវិកាសម្រាប់លើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី | ចំនួន | ០ | ៣ | ៤ | ៤ | ៥ | ៥ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី |
| ៥. | ក្រសួង-ស្ថាប័នដែលបានអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ | ចំនួន | ៨ | ៨ | ៩ | ១០ | ១១ | ១២ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី |
| ៦. | កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ដែលមានកំណត់សមាសភាព និងសូចនាករជាក់លាក់ដែលឆ្លើយតបនឹងយេនឌ័រ | ចំនួន | ០ | | ១ | | | | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី |
| ៧. | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលបានកំណត់សមាសភាព និងសូចនាករជាក់លាក់ដែលឆ្លើយតបយេនឌ័រ | ចំនួន | ១ | ១ | | ២ | | | គ.ជ.អ.ប |
| ៨. | ចំនួនសវនកម្មយេនឌ័រ តាមវិស័យ | ចំនួន | ២ | ៣ | ៤ | ៥ | ៦ | ៧ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី |

| សូចនាករជាតិ និងតាមវិស័យគន្លឹះៗ | | ឯកតា | ស្ថានភាព | ចំណុចដៅ | | | | | ប្រភពទិន្នន័យ និងព័ត៌មាន |
|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| **ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី** | | | | | | | | | |
| ១. | អត្រាស្ត្រីដែលមានការងារធ្វើ អាយុពី១៥-៦៤ឆ្នាំ | ភាគរយ | ៧៩,៩ (២០១៧) | ៨២,០ | ៨៤,០ | ៨៥,០ | ៨៧,០ | ៩០ | អង្កេតសេដ្ឋកិច្ច សង្គមកិច្ច កម្ពុជា |
| ២. | ចំណែករបស់ស្ត្រី ចូលរួមក្នុងការងារមានប្រាក់កម្រៃ អាយុពី១៥-៦៤ឆ្នាំ | | | | | | | | អង្កេតសេដ្ឋកិច្ច សង្គមកិច្ច កម្ពុជា |
| | *កសិកម្ម* | ភាគរយ | ៣៥,០ (២០១៧) | ៣៧,០ | ៣៩,០ | ៤១,០ | ៤៣,០ | ៤៥,០ | |
| | *ឧស្សាហកម្ម* | ភាគរយ | ២៧,៣ (២០១៧) | ៣៩,០ | ៣០,០ | ៣១,០ | ៣៣,០ | ៣៥,០ | |
| | *សេវាកម្ម)* | ភាគរយ | ៣៧,៦ (២០១៧) | ៣៨,០ | ៣៩,០ | ៤១,០ | ៤៣,០ | ៤៥,០ | |
| ៣. | ចំនួនវិធានការផ្លូវច្បាប់ និងគោលនយោបាយដែល ដោះស្រាយ និងទទួលស្គាល់នូវតុល្យភាពជីវិត និងការងារ (ការផ្ទះ និងការថែទាំដែលមិនមានកម្រៃ) និងលើកកម្ពស់ការទទួលបាន កាន់តែច្រើននូវការងារសមរម្យសម្រាប់ស្ត្រី | ចំនួន | ៥ (២០១៦) | | | | | ៩ | គោលដៅអភិវឌ្ឍប្រកបដោយ ចីរភាព |
| ៤. | កម្មវិធីស្តីពីការអភិវឌ្ឍសហគ្រិនភាពដល់ស្ត្រី បានតាក់តែង និងទទួលបានថវិកាជាតិនិងធនធានពីដៃគូអភិវឌ្ឍន៍សម្រាប់អនុវត្ត | ចំនួន | ០ | | | ១ | | | ក្រសួងកិច្ចការនារី |
| ៥. | បណ្តាញសហគ្រិនស្ត្រីនៅកម្ពុជាត្រូវបានបង្កើត និងដំណើរការ | ចំនួន | ០ | | ១ | | | | ក្រសួងកិច្ចការនារី |
| ៦. | មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី ដែលបានធ្វើពិពិធកម្មមុខងារ ត្រូវបានធ្វើឱ្យប្រសើរឡើង | ចំនួន | ៥ | ៥ | ៦ | ៧ | ៧ | ៧ | ក្រសួងកិច្ចការនារី |
| ៧. | លទ្ធភាពទទួលសេវាកម្មហិរញ្ញវត្ថុផ្លូវការរបស់ស្ត្រី | ភាគរយ | ៦០ | | | | | ៦៥ | ធនាគារជាតិ |

| សូចនាករជាតិ និងតាមវិស័យគន្លឹះៗ | | ឯកតា | ស្ថានភាព | ចំណុចដៅ | | | | | ប្រភពទិន្នន័យ និងព័ត៌មាន |
|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| | កើនឡើង | | | | | | | | នៃកម្ពុជា |
| **ការអប់រំរបស់ស្ត្រី និងក្មេងស្រី** | | | | | | | | | |
| ១. | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | ភាគរយ | ៤២,៥ | ៤៧,៧ | ៤៨,៩ | ៥០,២ | ៥១,៤ | ៥២,៦ | ក្រសួងអប់រំ យុវជន និងកីឡា |
| | *ប្រុស* | | ៤២,៣ | ៤៣,៨ | ៤៥,៤ | ៤៦,៩ | ៤៨,៥ | ៥០,០ | |
| | *ស្រី* | | ៥១,១ | ៥២,៥ | ៥៣,៣ | ៥៤,៣ | ៥៥,៣ | ៥៦,៣ | |
| ២. | អត្រារួមនៃការសិក្សានៅឧត្តមសិក្សា (១៨-២២ឆ្នាំ) | ភាគរយ | ១១,៦ | ១២,៤ | ១៣,៣ | ១៤,២ | ១៥,១ | ១៦,០ | ក្រសួងអប់រំ យុវជន និងកីឡា |
| | *ប្រុស* | ភាគរយ | ១៣,៣ | ១៤,៣ | ១៥,៥ | ១៦,៦ | ១៧,៨ | ១៨,៩ | |
| | *ស្រី* | ភាគរយ | ១១,៣ | ១១,៦ | ១១,៩ | ១២,៣ | ១២,៧ | ១៣,០ | |
| ៣. | ភាគរយនិស្សិតចុះឈ្មោះចូលរៀនក្នុងកម្មវិធីបណ្តុះ បណ្តាលផ្នែកស្ទែម | ភាគរយ | ២៧,១ | ២៨,០ | ២៩,០ | ៣០,០ | ៣១,០ | ៣២,០ | ក្រសួងអប់រំ យុវជន និងកីឡា |
| | *ប្រុស* | | ៣៦,៧ | ៣៧,១ | ៣៧,៥ | ៣៧,៨ | ៣៨,២ | ៣៨,៦ | |
| | *ស្រី* | | ១៧,៤ | ១៨,៤ | ១៩,៤ | ២០,៥ | ២១,៥ | ២២,៥ | |
| ៤. | ចំនួនសិស្សក្នុងការអប់រំបច្ចេកទេស | ចំនួន | ១ ៤៧១ | ១ ៧៧៧ | ២ ០៨៣ | ២ ៣៨៨ | ២ ៦៩៤ | ៣ ០០០ | ក្រសួងអប់រំ យុវជន និងកីឡា |
| | *ចំនួនសិស្សស្រី* | ចំនួន | ៥២៦ | ៥៤៥ | ៥៦៤ | ៥៨៣ | ៦០២ | ៦២១ | |
| **សុខភាពស្ត្រី និងក្មេងស្រី** | | | | | | | | | |
| ១. | អត្រាមរណភាពមាតា ក្នុង១០០ពាន់ទារកកើតរស់ | ក្នុងទារកកើតរស់ ១០០ ពាន់នាក់ | ១៧០ | | ១៣០ | | | ១០០ (គោលដៅឆ្នាំ២០២៥) | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| ២. | សមាមាត្រនៃស្ត្រីក្នុងវ័យបន្តពូជ (១៥-៤៩ឆ្នាំ) | ភាគរយ | | | ៦២ | | | ៦៥ | ផែនការយុទ្ធសាស្ត្រ |

| សូចនាករជាតិ និងតាមវិស័យគន្លឹះៗ | | ឯកតា | ស្ថានភាព | ចំណុចដៅ | | | | | ប្រភពទិន្នន័យ និងព័ត៌មាន |
|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| | ដែលត្រូវការសេវាផែនការគ្រួសារបានពេញចិត្ត នឹង មធ្យោបាយពន្យារកំណើតទំនើប | | | | | | | (គោលដៅឆ្នាំ២០២៥) | អភិវឌ្ឍន៍ជាតិ |
| ៣. | ស្ត្រីវ័យជំទង់អាយុ ១៥-១៩ ឆ្នាំមានគភ៌ | ភាគរយ | | | ៨ | | | | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| ៤. | ស្ត្រី អាយុពី៣០-៤៩ឆ្នាំ ដែលបានទទួលការស្រាវជ្រាវរកជំងឺមហារីកមាត់ស្បូនយ៉ាងតិច១លើក | ភាគរយ | | ៤ | ៦ | ៨ | ១០ | ១២ | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| ៥. | ច្បាប់ គោលនយោបាយ ផែនការនិងលិខិតបទដ្ឋាន គតិយុត្តដែលធានាឱ្យស្ត្រីគ្រប់រូប មានលទ្ធភាពទទួលបានព័ត៌មានការអប់រំនិងសេវាសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ | ចំនួន | ១០ (២០១៦) | | | | ១៥ | | គោលដៅអភិវឌ្ឍប្រកបដោយ ចីរភាព |
| **កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី** ( សូចនាករផ្សេងៗទៀត មានកំណត់នៅក្នុងផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០១៩-២០២៣ ដែលនឹងអនុម័តដោយរាជរដ្ឋាភិបាល ) | | | | | | | | | |
| ១. | ផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី បានធ្វើបច្ចុប្បន្នភាព និងអនុម័ត | ចំនួន | ២ | | ៣ | | | | ក្រសួងកិច្ចការនារី |
| ២. | សមាមាត្ររបស់ស្ត្រីនិងក្មេងស្រី មានអាយុ១៥ឆ្នាំឡើងដែលធ្លាប់ទទួលរងនូវអំពើហិង្សាលើរាងកាយ ផ្លូវចិត្ត ឬអតីត ក្នុងរយៈពេល១២ខែចុងក្រោយ បែងចែកតាមទម្រង់នៃអំពើហិង្សានិងតាមអាយុ | ភាគរយ | ៣០,០ (២០១៦) | | | | | ២៨,០ | គោលដៅអភិវឌ្ឍប្រកបដោយចីរភាព |
| ៣. | សមាមាត្ររបស់ស្ត្រីនិងក្មេងស្រី ដែលមានអាយុ១៥ឆ្នាំឡើង ដែលធ្លាប់ទទួលរងអំពើហិង្សាលើផ្លូវភេទ ពីអ្នកមិនមែនជាដៃគូក្នុងរយៈពេល១២ខែចុងក្រោយ បែងចែកតាមភេទ | ភាគរយ | ០,១ (២០១៦) | | | ០,០៨ | | | គោលដៅអភិវឌ្ឍប្រកបដោយចីរភាព |

| | សូចនាករជាតិ និងតាមវិស័យគន្លឹះៗ | ឯកតា | ស្ថានភាព | ចំណុចដៅ | | | | | ប្រភពទិន្នន័យ និងព័ត៌មាន |
|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| ៤. | សមាមាត្ររបស់ស្ត្រី អាយុពី២០-២៤ឆ្នាំ ដែលរៀបការ ឬរស់នៅជាមួយគ្នាមុន អាយុ១៨ឆ្នាំ | ភាគរយ | ១,៩ (២០១៦) | | | | | ១,៧ | គោលដៅអភិវឌ្ឍប្រកបដោយចីរភាព |
| ៥. | ចំនួនមណ្ឌលសេវាចម្រុះសម្រាប់ស្ត្រី និងក្មេងស្រីដែលរងគ្រោះដោយអំពើហិង្សាគ្រប់ទម្រង់ ដើម្បីសម្រួលការផ្តល់សេវា ផ្នែកច្បាប់ សេវាសង្គមកិច្ច សេវាសុខភាព និងសេវាផ្សេងៗ ជូនជនរងគ្រោះ | ចំនួន | ០ | ១ | ២ | ៣ | ៤ | ៥ | ក្រសួងកិច្ចការនារី |
| **ស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈ និងនយោបាយ** | | | | | | | | | |
| ១. | ភាគរយអាសនៈរបស់ស្ត្រី ក្នុងស្ថាប័ននីតិប្បញ្ញត្តិ | | ២៥ | ២៥ | | | | ៣០ | ក្រសួងកិច្ចការនារី |
| ២. | សមាមាត្រស្ត្រីជារដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ | ភាគរយ | ២១ | ២១ | | | | ២៦ | ទីស្តីការគណៈរដ្ឋមន្ត្រី |
| ៣. | ភាគរយស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ | ភាគរយ | ១៦.៧ | ១៦.៧ | | | | **២៥** | គ.ជ.ប |
| ៤. | ស្ត្រីជាអ្នកគ្រប់គ្រងក្នុងវិស័យសាធារណៈ ថ្នាក់ជាតិ និងក្រោមជាតិ (អគ្គនាយក ប្រធាននាយកដ្ឋាន ប្រធានការិយាល័យ និងប្រធានមន្ទីរ) | ភាគរយ | ១៤ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ក្រសួងមុខងារសាធារណៈ |
| ៥. | ភាគរយស្ត្រីថ្នាក់ដឹកនាំនៅថ្នាក់ក្រុង ស្រុក ខណ្ឌកាន់មុខតំណែងគ្រប់គ្រង | | ២៥ | ២៧ | ២៨ | ២៩ | ៣០ | ៣២ | ក្រសួងមហាផ្ទៃ |
| ៦. | មន្ត្រីរាជការជាស្ត្រី ក្របខណ្ឌមុខងារសាធារណៈ | ភាគរយ | ៤១ | ៤៤ | ៤៥ | ៤៦ | ៤៧ | ៤៨ | ក្រសួងមុខងារសាធារណៈ |

# សទ្ទានុក្រម

| | |
|---|---|
| **សមភាពយេនឌ័រ** | សំដៅដល់គោលការណ៍គ្មានការរើសអើងទៅលើភេទណាមួយ និងគោលដៅដើម្បីឱ្យបុរស-ស្ត្រី កូនប្រុស-កូនស្រី មានឱកាស តម្លៃ ធនធាននិងផលប្រយោជន៍ដូចៗគ្នា ដោយពិតប្រាកដនៅក្នុងគ្រួសារ សហគមន៍ ស្ថាប័ន និងសង្គម |
| **សមធម៌យេនឌ័រ** | សំដៅដល់គោលការណ៍ យុទ្ធសាស្ត្រ មធ្យោបាយ ឬវិធានការវិជ្ជមានដែលបង្កលក្ខណៈ ឬផ្តល់ឱកាសដល់បុគ្គល ឬក្រុមណាមួយនៃបុរស-ស្ត្រី ក្នុងការកាត់បន្ថយគម្លាត និងដើម្បីឈានទៅសម្រេចសមភាពយេនឌ័រ យ៉ាងពិតប្រាកដ |
| **វិសមភាពយេនឌ័រ** | សំដៅដល់ផ្នត់គំនិត និងឥរិយាបថរើសអើងទៅលើភេទណាមួយ និងបញ្ហាឬគម្លាតរវាងបុរស-ស្ត្រី កូនប្រុស-កូនស្រី ដែលកើតមានក្នុងសង្គម សហគមន៍ ស្ថាប័ន និងគ្រួសារ |
| **ការបញ្ជ្រាបយេនឌ័រ** | យុទ្ធសាស្ត្រ និងវិធានការឆ្លើយតបនឹងវិសមភាពយេនឌ័រ ក្នុងគោលនយោបាយតាមវិស័យ កម្មវិធី លិខិតបទដ្ឋានគតិយុត្ត ស្ថាប័ននិងគ្រួសារ។ល។ |
| **ការបង្កើនភាពអង់អាចដល់ស្ត្រី** | សំដៅដល់វិធានការដើម្បីបង្កើនសមត្ថភាព អភិវឌ្ឍន៍សក្តានុពល និងការការពារផលប្រយោជន៍ដល់ស្ត្រី |
| **បរិយាបន្ន** | សំដៅដល់ការដាក់បញ្ចូល ការយកចិត្តទុកដាក់ និងឆ្លើយតបដល់គ្រប់ក្រុមគោលដៅ នៅក្នុងសង្គម ស្ថាប័ន និងគ្រួសារ ដោយសំដៅ «មិនឱ្យអ្នកណាម្នាក់នៅឯកោ» លើក្រុមគោលដៅដែលងាយរងគ្រោះ និងបាត់បង់ឱកាសនានានៅក្នុងសង្គម ដូចជាជនពិការ ក្រុមស្រឡាញ់ភេទដូចគ្នា (LGBTIQ) ជនជាតិដើមភាគតិច កុមារ ស្ត្រីជនចាស់ជរាជាដើម |
| **វិភាគបញ្ហាយេនឌ័រ** | សំដៅដល់ការវិភាគឱ្យឃើញនូវឫសគល់ និងផលប៉ះពាល់នៃវិសមភាពយេនឌ័រ ដែលមានក្នុងសង្គម តាមវិស័យ និងអង្គភាព |

**ផលប៉ះពាល់យេនឌ័រតាមវិស័យ** សំដៅដល់ប្រភេទ និងទំហំនៃផលប៉ះពាល់ជាអវិជ្ជមាន ដែលកើតឡើងពីវិសមភាពយេនឌ័រលើសង្គម ស្ថាប័ន តាមវិស័យ និងនៅក្នុងគ្រួសារ

**អំពើហិង្សាទាក់ទងនឹងយេនឌ័រ** សំដៅដល់ការរំលោភបំពានទៅលើភេទណាមួយ ដែលគេគិតថាទន់ខ្សោយជាងខ្លួនហើយដែលនាំឱ្យមាន ឬក៏ទំនងជានាំឱ្យមានសេចក្តីអន្តរាយ លើរូបកាយផ្លូវភេទ ផ្លូវចិត្ត ឬខាងសេដ្ឋកិច្ច ដោយផ្អែកលើយេនឌ័រ នៃបុគ្គលណាមួយ។

**វិធានការតុល្យភាពជីវិត** សំដៅដល់វិធានការរបស់ស្ថាប័ន និងរដ្ឋ ក្នុងការគាំទ្រដល់បុគ្គលិក និងគ្រួសារ ក្នុងគោលដៅឱ្យមានតុល្យភាពនៃគុណភាពការងារ និងគុណភាពជីវិត ដែលក្នុងនោះមានដូចជាការគិតគូរនិងឆ្លើយតបការសម្រាកមាតុភាព និងបិតុភាព ការសម្រាកថែទាំគ្រួសារ ការរៀបចំកន្លែងថែទាំកុមារនៅកន្លែងធ្វើការ ការរៀបចំការងារដែលមានភាពបត់បែន។

**សវនកម្មយេនឌ័រ** ឧបករណ៍ និងវិធីសាស្ត្រ ក្នុងការពិនិត្យនិងប៉ាន់ប្រមាណ លើវឌ្ឍនភាព បញ្ហាប្រឈម គម្លាត កាលានុវត្តភាព និងអនុសាសន៍ ក្នុងការលើកកម្ពស់សមភាពយេនឌ័រក្នុងស្ថាប័ន ឬវិស័យណាមួយ តាមរយៈការប្រៀបធៀបរវាងការប្តេជ្ញាចិត្តនិងគោលនយោបាយរបស់ស្ថាប័ន ឬវិស័យ ជាមួយនឹងស្ថានភាពជាក់ស្តែង ។

**ការឆ្លើយតបយេនឌ័រ** សំដៅលើការយកចិត្តទុក ការគិតគូរ និងដោះស្រាយអំពីបញ្ហាវិសមភាពយេនឌ័រ នៅក្នុងគ្រប់ដំណាក់កាលនិងផ្នែកនៃដំណើរការ ឬកិច្ចការ ឬស្ថាប័នណាមួយ។ ឧទាហរណ៍ គោលនយោបាយ ដែលឆ្លើយតបយេនឌ័រសំដៅលើគោលនយោបាយ ដែលបានគិតគូរ និងដោះស្រាយបញ្ហាវិសមភាព យេនឌ័រនៅក្នុងដំណាក់កាលតាក់តែង តាមរយៈការវិភាគយេនឌ័រ និងមានវិធានការជាក់លាក់ក្នុងការឆ្លើយតបវិសមភាពយេនឌ័រ ក្នុងគោលនយោបាយនោះ។

# គំនូសបំព្រួញផែនការយុទ្ធសាស្ត្រនារីរតនៈទី៥

## ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ២០១៩-២០២៣

ដើម្បីសម្រេចសមភាពយេនឌ័រ និងភាពអង់អាចរបស់ស្ត្រីនិងក្មេងស្រីគ្រប់រូបនៅកម្ពុជា

**ការបញ្ជ្រាបយេនឌ័រ**

ក្របខណ្ឌច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធីជាតិ និងការផ្លាស់ប្តូរឥរិយាបថជាសាធារណៈ

| យុទ្ធសាស្ត្រទី ១ | យុទ្ធសាស្ត្រទី ២ | យុទ្ធសាស្ត្រទី ៣ | យុទ្ធសាស្ត្រទី ៤ | យុទ្ធសាស្ត្រទី ៥ | យុទ្ធសាស្ត្រទី ៦ |
|---|---|---|---|---|---|
| ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី | ការលើកកម្ពស់ការអប់រំរបស់ស្ត្រីនិងក្មេងស្រី | ការលើកកម្ពស់សុខភាពរបស់ស្ត្រីនិងក្មេងស្រី | កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី | ភាពជាអ្នកដឹកនាំរបស់ស្ត្រី ក្នុងវិស័យសាធារណៈនិងនយោបាយ | ការបញ្ជ្រាបយេនឌ័រក្នុងការប្រែប្រួលអាកាសធាតុ |

**ការពង្រឹងសមត្ថភាព និងអភិវឌ្ឍស្ថាប័ន**

ការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីវិមជ្ឈការនិងវិសហមជ្ឈការ ការធ្វើទំនើបកម្មស្ថាប័ន អភិវឌ្ឍន៍ធនធានមនុស្ស ប្រព័ន្ធតាមដាននិងវាយតម្លៃ ការគ្រប់គ្រងព័ត៌មាន និងកិច្ចសហប្រតិបត្តិការ

ឧបត្ថម្ភបោះពុម្ពដោយ៖

ក្រសួងកិច្ចការនារី
MINISTRY OF WOMEN'S AFFAIRS

**ក្រសួងកិច្ចការនារី**
ផ្លូវទ្រុងមាន់ ភូមិដំណាក់ធំ ៣ សង្កាត់ស្ទឹងមានជ័យ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ហ្វាក់: (+៨៥៥) ២៣ ៨៨០ ៧៣៧
អ៊ីម៉ែល:mwa@online.com.kh
វេបសាយ:www.mowa.gov.kh
ហ្វេសប៊ុក:www.facebook.com/mowa.gov.kh